ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

## បូកសរុបសកម្មភាព និងលទ្ធផលការងារ
## ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៤ និង ទិសដៅ ឆ្នាំ២០១៥



គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ

# អារម្ភកថា

*សម្តេច ឯកឧត្តម លោកជំទាវ*
*លោក លោកស្រី មន្ត្រីគ្រប់ក្រសួងស្ថាប័ន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ*
*លោក លោកស្រីដែលកំពុងធ្វើការងារយ៉ាងសកម្មក្នុងអង្គការដៃគូជាតិ និងអន្តរជាតិ*
*បងប្អូនជនរួមជាតិ ជាទីគោរព រាប់អាន*

គិតមកដល់ឆ្នាំ ២០១៤ គណៈកម្មាធិការជាតិ បានផលិតរបាយការណ៍ ស្តីពីសកម្មភាព និងលទ្ធផលនៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំឆ្នាំថ្នាក់ជាតិ បានប្រាំដងរួចមកហើយ ។ របាយការណ៍នេះបានបង្ហាញអំពីកិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តសកម្មភាព របស់បណ្តាក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អង្គភាពអនុវត្តច្បាប់ អង្គការដៃគូជាតិ និងអន្តរជាតិ ព្រមទាំងស្ថានទូតកម្ពុជាប្រចាំនៅក្នុងប្រទេសពាក់ព័ន្ធទាំងឡាយ និងធ្វើឲ្យសម្រេចបាននូវលទ្ធផលរួមគ្នាគួរឲ្យកត់សម្គាល់ ។ ទន្ទឹមនឹងនោះ យើងក៏បានរកឃើញនូវភាពប្រឈម និងឧបសគ្គមួយចំនួន ដែលនាំឲ្យរាំងស្ទះ ឬកាត់បន្ថយ ប្រសិទ្ធភាពនៃការអនុវត្តន៍ និងធ្វើឲ្យយើងមិនអាចសម្រេចគោលដៅគួរជាទីពេញចិត្តបាន ។

ទោះបីជាយ៉ាងណាក្តី ក៏លទ្ធផលទាំងនេះមិនអាចកាត់ផ្តាច់បានពីការចូលរួមយ៉ាងសកម្ម ប្រកបដោយការប្តេជ្ញាចិត្តខ្ពស់របស់ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន លោក លោកស្រីទាំងអស់ក្នុងការជំនះគ្រប់ឧបសគ្គ បង្ការទប់ស្កាត់នូវរាល់ល្បិចកលរបស់ជនល្មើសជួញដូរមនុស្ស ដែលបង្កនូវភាពរងគ្រោះដល់ប្រជាពលរដ្ឋ ទាំងបុរស ស្ត្រី យុវវ័យ និងកុមារកម្ពុជា នៅគ្រប់ទីកន្លែង ។ បញ្ហានៅត្រង់ថា ការយល់ឃើញ បទពិសោធន៍ការងារ និងស្ថានភាពនៃក្រុមគោលដៅ និងបទល្មើសមិនដូចគ្នា ហើយប្រតិបត្តិការក៏មិនបានសហការគ្នាគ្រប់គ្រាន់ ដែលនាំឲ្យមានចំណុចឆកល្វែង ធ្វើឲ្យបទល្មើសអាចកើតឡើងបាន និងធ្វើឲ្យជនល្មើសមួយចំនួនអាចរួចខ្លួន ហើយក៏មិនបានការពារជនងាយរងគ្រោះ និងសង្គ្រោះជនរងគ្រោះទាន់ពេលវេលា ថែមទៀត ។ នេះមិនមែនជាកំហុសអ្នកណាម្នាក់ ឬអង្គភាពណាមួយឡើយ តែគឺជាកង្វះខាតរួមរបស់យើងទាំងអស់គ្នា ដែលមិនមានកិច្ចសហការល្អប្រសើរ ហើយក៏មានចំណុចខ្វះចន្លោះក្នុងការអនុវត្តច្បាប់ ក៏ដូចជាក្នុងការគ្រប់គ្រងមនុស្ស ព្រមទាំងការគ្រប់គ្រងសភាពការណ៍បទល្មើស និងការគ្រប់គ្រងសកម្មភាពដែលបានអនុវត្តថែមទៀត ។

ឥឡូវនេះ យើងមានផែនការសកម្មភាព និងយុទ្ធសាស្ត្រជាតិ សម្រាប់រយៈពេលប្រាំឆ្នាំ ដែលកើតឡើងដោយការប្រមូលផ្តុំនូវគំនិត យោបល់ និងការឯកភាពគ្នាក្នុងចំណោមថ្នាក់ដឹកនាំនយោបាយ តាមបណ្តាក្រសួងស្ថាប័នជំនាញ មន្ត្រី បុគ្គលិកជាប្រតិបត្តិករគ្រប់កម្រិត ។ មិនតែប៉ុណ្ណោះ យើងក៏មានយន្តការជាតិថ្មី ដែលមានទ្រង់ទ្រាយធំទូលំទូលាយ និងមានកម្លាំងគ្រប់គ្រាន់សម្រាប់អនុវត្ត ព្រមទាំងបានគ្រោងទុកនូវធនធានមួយចំនួន រួមជាមួយនឹងការចូលរួមពីបណ្តាអង្គការអន្តរជាតិ ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការសង្គមស៊ីវិលជាច្រើន ។

ខ្ញុំសង្ឃឹមថា ទិសដៅឆ្នាំ២០១៥ ពិតជាអាចអនុវត្តបានជោគជ័យ ព្រោះយើងបានរកឃើញ និងទទួលស្គាល់នូវចំណុចខ្វះខាត មេរៀនជាបទពិសោធន៍ និងលើកទិសដៅកែលំអរួចហើយ ។ ចំណុចគន្លឹះគឺយើងត្រូវមានកិច្ចសហការជិតស្និទ្ធក្នុងការពិគ្រោះពិភាក្សា ផ្លាស់ប្តូរយោបល់គ្នា និងរកការឯកភាព

គ្នាអនុវត្តឲ្យមានលក្ខណៈជាប្រព័ន្ធ និងប្រទាក់ក្រឡាគ្នា ។ យើងមិនអាចមើលបំណាំគ្នា និងមិនអាចចង្អុលដាក់គ្នាទៅវិញទៅមកបានទេព្រោះ ជាភារកិច្ចរបស់យើងទាំងអស់គ្នា ។ គណៈកម្មាធិការជាតិមានភារកិច្ចរៀបចំកិច្ចប្រជុំទៀងទាត់ បីខែម្តង ដើម្បីធ្វើជាវេទិកាបញ្ចេញមតិ និងផ្លាស់ប្តូរព័ត៌មាន និងបទពិសោធន៍រវាងស្ថាប័នអនុវត្ត ហើយក៏អាចលើកជាសំណូមពរកែលំអ បំពេញបន្ថែម ឬបង្កើតវិធីដោះស្រាយថ្មីៗថែមទៀត បើសិនជាចាំបាច់ ។

ជាថ្មីម្តងទៀត ក្នុងនាមរាជរដ្ឋាភិបាល និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខ្ញុំសូមប្តេជ្ញាចិត្ត ចូលរួមគាំទ្រ ផ្តល់ជំនឿទុកចិត្ត និងសូមលើកទឹកចិត្តឲ្យបន្តកិច្ចខិតខំគ្រប់ក្រសួងស្ថាប័ន អង្គការដៃគូជាតិ អន្តរជាតិទាំងអស់ បន្តខិតខំប្រឹងប្រែង ដើម្បីធ្វើឲ្យសម្រេចគោលដៅដែលបានដាក់ចុះសម្រាប់ឆ្នាំ២០១៥ និងផែនការសកម្មភាពជាតិប្រយទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេលប្រាំឆ្នាំ ២០១៤-២០១៨ ឲ្យបានជាស្ថាពរ។

ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្តាអង្គការដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ជាពិសេសអង្គការដែលបានផ្តល់កិច្ចសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មាធិការជាតិ តាមរយៈអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងគណៈកម្មាធិការថ្នាក់ក្រោមជាតិ គ.រ.ប.ជ និង គ.ខ.ប.ជ ដោយបានចូលរួមឧបត្ថម្ភគាំទ្រ ទាំងកម្លាំងកាយ ចិត្ត ធនធាន ថវិកា បច្ចេកទេស និងសកម្មភាពផ្សេងៗក្នុងគោលដៅគាំទ្រដល់នយោបាយជាតិក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើកេងប្រវ័ញ្ចកម្លាំងពលកម្មនិងផ្លូវភេទ ព្រមទាំងបទល្មើសពាក់ព័ន្ធគ្រប់រូបភាព ដូចដែលបានរៀបរាប់ក្នុងរបាយការណ៍នេះស្រាប់ ។

ជាទីបញ្ចប់ ខ្ញុំសូមឧទ្ទិសបួងសួងដល់គុណព្រះរតនត្រ័យ បារមីវត្ថុសក្តិសិទ្ធិក្នុងលោក និងទេវតាឆ្នាំថ្មី សូមប្រសិទ្ធិពរជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការ សូមមានដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងក្រុមគ្រួសារ កុំបីឃ្លៀងឃ្លាតឡើយ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**ស ខេង**

# មាតិកា


I. ស្ថានភាពទូទៅ ......... ១

II. លទ្ធផលការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៤ ......... ៣

ក- ការងារផ្នែកច្បាប់ គោលនយោបាយជាតិ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ ......... ៣

ខ- ការអនុវត្តន៍យុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស ......... ៤

១- ការងារបង្ការ-ទប់ស្កាត់ ......... ៤

២- ការងារការពារ-ស្តារនីតិសម្បទាសមាហរណកម្ម និងមាតុភូមិនិវត្តន៍ ......... ៨

៣- ការងារអនុវត្តន៍ច្បាប់ ......... ១១

៤- ការងារកិច្ចការយុត្តិធម៌ ......... ១៤

៥-ការងារសហប្រតិបត្តិការអន្តរជាតិ ......... ១៥

៦- ការងារពាក់ព័ន្ធនឹងកុមារ ......... ១៨

៧- ការងារទេសន្តរប្រវេសន៍: ......... ១៩

គ- ការងារដឹកនាំ និងសម្របសម្រួលកិច្ចសហការ ៖ ......... ២២

ឃ- ការលើកកម្ពស់សមត្ថភាព ......... ២៤

១. ការបណ្តុះបណ្តាល ......... ២៤

២. សិក្ខាសាលា ......... ២៥

III. ការសន្និដ្ឋាន និងវាយតម្លៃ ......... ២៧

ក. ចំណុចខ្លាំង ......... ២៧

ខ. ចំណុចសេសសល់ និងភាពប្រឈម ......... ២៧

IV. ទិសដៅសម្រាប់ ឆ្នាំ២០១៥ ......... ២៨

# របាយការណ៍បូកសរុប
# សកម្មភាពនិងលទ្ធផល ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
# និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០១៤
# និងទិសដៅការងារ ឆ្នាំ២០១៥
**(គិតចាប់ពីថ្ងៃទី២៦/១២/១៣-២៥/១២/១៤)**

## I. ស្ថានភាពទូទៅ

ឆ្នាំ២០១៤ គឺជាការចាប់ផ្តើមអណត្តិថ្មីនៃរាជរដ្ឋាភិបាល បន្ទាប់ពីមានការបោះឆ្នោតនីតិកាលទី៥នៃរដ្ឋសភា កាលពីខែកក្កដា ឆ្នាំ២០១៣រួចមក ។ ប្រទេសជាតិមានការវិវត្តន៍ប្រែប្រួលទៅតាមសភាពការណ៍នយោបាយ សេដ្ឋកិច្ច និងសង្គម ដែលរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ជាចម្បងទៅលើកំណែទម្រង់ គ្រប់វិស័យ ដើម្បីភាពរីកចម្រើននៃប្រទេសជាតិ ។ ទន្ទឹមនឹងនោះ រាជរដ្ឋា-ភិបាលបានជំរុញការអនុវត្តន៍គោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាពដើម្បីការពារសន្តិសុខ និងសុវត្ថិភាពប្រជាពលរដ្ឋ ដោយបង្ការ ទប់ស្កាត់ និងបញ្ចៀសគ្រោះមហន្តរាយទាំងឡាយ ដែលបង្កឡើងពីការប្រព្រឹត្តបទល្មើស និងការធ្វេសប្រហែសរបស់ប្រជាពលរដ្ឋ ធ្វើឲ្យមានគ្រោះមហន្តរាយ ខូចខាតសុខភាពផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ បាត់បង់ទ្រព្យសម្បត្តិ កិត្តិយស សេចក្តីថ្លៃថ្នូរ រហូតដល់អាយុជីវិតថែមទៀត គួរឲ្យសោកស្តាយ ។

រាជរដ្ឋាភិបាល បានខិតខំពង្រីកសក្តានុពលសេដ្ឋកិច្ច តាមរយៈការទាក់ទាញភ្ញៀវទេសចរណ៍ឲ្យមកទស្សនាកំសាន្ត ដើម្បីបានឃើញការពិតជាក់ស្តែងអំពីសុវត្ថិភាព សោភ័ណភាព និងភាពរីកចម្រើនរបស់ព្រះរាជាណាចក្រកម្ពុជា និងបាននាំមកនូវការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ រោងចក្រ សហគ្រាស ដែលបង្កើតឲ្យមានការងារដល់ប្រជាពលរដ្ឋ គឺអាចធ្វើជាបុគ្គលិក កម្មករ អាជីវករ ផលិតករ សិប្បករ អ្នកដឹកជញ្ជូន និងជាកសិករ ដែលមានឱកាសបង្កើនផលិតផលសម្រាប់បម្រើឲ្យការហូបចុកប្រើប្រាស់ និងការនាំចេញដែលនាំឲ្យមានកំណើនប្រាក់ចំណូលតាមគ្រប់រូបភាព ដល់ប្រជាពលរដ្ឋរាប់លាននាក់ ។

ទោះបីជាមានការខិតខំបែបនេះក្តី ក៏ប្រជាពលរដ្ឋមួយចំនួននៅតែបន្តរងគ្រោះ ដោយអំពើហិង្សា អំពើជួញដូរមនុស្ស ការរំលោភបំពាន លើផ្លូវកាយ និងផ្លូវភេទ ការសេពគ្រឿងញៀន គ្រោះថ្នាក់ចរាចរណ៍ និងគ្រោះមហន្តរាយដទៃទៀតជារៀងរាល់ថ្ងៃ។ ទន្ទឹមនឹងនោះ ជនឱកាសនិយមបានព្យាយាមរកគ្រប់ល្បិចកល ដើម្បីកេងយកផលចំណេញ ដោយមិនគិតពីផលប៉ះពាល់ជាអវិជ្ជមានទៅលើប្រជាពលរដ្ឋ ឬប្រទេសជាតិឡើយ ។ ប្រជាពលរដ្ឋជាច្រើន បាននិងកំពុងតែធ្វើចំណាកស្រុក និងទេសន្តរប្រវេសន៍ឆ្លងដែនដោយផ្សងព្រេងទៅរកការងារធ្វើ ឬរកគូស្រករ នៅក្រៅប្រទេស តាមរបៀបមិនស្របច្បាប់ ។

ព្រឹត្តិការណ៍សំខាន់សម្រាប់ឆ្នាំ២០១៤ ជាពិសេស ចាប់ពីខែមិថុនា ដល់ខែកញ្ញា គឺការបញ្ជូនពលករខ្មែរត្រឡប់មកកម្ពុជាវិញដោយគំហុកជាងម្ភៃម៉ឺននាក់ ដោយរដ្ឋាភិបាលថៃ ដែលធ្វើឲ្យរាជរដ្ឋាភិបាលកម្ពុជាប្រឈមនឹងការរកដំណោះស្រាយដោយប្រញាប់ប្រញាល់ ដើម្បីទទួលពលករ និងផ្តល់នូវជម្រើសផ្សេងៗសម្រាប់ការរស់នៅ ។ ក្នុងនោះ ក៏មានកិច្ចសហការ និងការគាំទ្រពីអង្គការដៃគូជាតិ និងអន្តរជាតិជាច្រើនយ៉ាងសកម្មក៏ដូចជាពីសប្បុរសជន អាជីវករ និងប្រជាពលរដ្ឋនៅក្នុងតំបន់ដែលមានពលករ ជាពិសេសនៅច្រកអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលបានចូលរួមជាមួយអាជ្ញាធរ និងសមត្ថកិច្ច យ៉ាងសកម្មដោយមិនគិតពីការនឿយហត់ ។ ប៉ុន្តែគោលនយោបាយរបស់រដ្ឋាភិបាលថៃបានផ្លាស់ប្តូរយ៉ាងឆាប់រហ័សធ្វើឲ្យ

សភាពកាណ៍ប្រែប្រួល គឺការទាក់ទាញពលករឲ្យវិលត្រឡប់ទៅធ្វើការនៅប្រទេសថៃវិញ ។ ក្រុមមេខ្យល់បានផ្តល់ព័ត៌មានយ៉ាងឆាប់រហ័សអំពីការអំពាវនាវរបស់ថៅកែថៃ និងការបង្កើតការិយាល័យច្រកចេញចូលតែមួយនៅក្នុងប្រទេសថៃប្រមាណជាងចិតសិបកន្លែង ដើម្បីទទួលចុះឈ្មោះពលករ និងសម្របសម្រួលឲ្យមានការស្នាក់នៅ និងផ្តល់ប័ណ្ណអនុញ្ញាតធ្វើការក្នុងប្រទេសថៃ ធ្វើឲ្យពលករហូរចេញទៅវិញយ៉ាង អនាធិបតេយ្យជាថ្មីម្តងទៀត ។ នេះជាដំណោះស្រាយបណ្តោះអាសន្នរយៈពេលខ្លីរបស់រដ្ឋាភិបាលថៃ តែមិនមានផលប្រយោជន៍ពិតប្រាកដសម្រាប់ប្រជាជន និងប្រទេសកម្ពុជាឡើយ ។ ចំពោះសភាពការណ៍បែបនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយ និងសកម្មភាពជាច្រើន ដើម្បីកាត់បន្ថយហានិភ័យរបស់ពលករក្នុងការប្រឈមនឹងការកេងប្រវ័ញ្ច និងជួញដូរមនុស្ស ។ សកម្មភាពទាំងនោះ មានដូចជាការផ្តល់ជូនពលករនូវលិខិតឆ្លងដែន នៅតាមការិយាល័យច្រកចេញចូលតែមួយនៃខេត្តជាប់ព្រំដែន ការរៀបចំជាក្រុមការងារចល័តសម្រាប់ការផ្តល់លិខិតឆ្លងដែនស្របច្បាប់នៅឯប្រទេសថៃ ការផ្សព្វផ្សាយអំពីទីផ្សារការងារសម្រាប់យុវវ័យ និងប្រជាពលរដ្ឋទូទៅដើម្បីជាជម្រើសសម្រាប់ការងារ និងមុខរបរការចុះអនុស្សរណៈទ្វេភាគីជាថ្មីជាមួយរាជរដ្ឋាភិបាលថៃស្តីពីកិច្ចសហាការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងកិច្ចការពារជនរងគ្រោះជាដើម ។ កិច្ចការនេះ នឹងត្រូវបន្តអនុវត្តជាមួយប្រទេសដទៃទៀត មានប្រទេសម៉ាឡេស៊ី សាធារណរដ្ឋប្រជាមានិតចិនជាដើម ។

មិនតែប៉ុណ្ណោះ ក្នុងឆ្នាំ២០១៤ រាជរដ្ឋាភិបាលកម្ពុជាបានសរុបលទ្ធផលនៃការវាយតម្លៃទៅលើលទ្ធផលការងារ ប្រសិទ្ធភាព និងភាពខ្វះចន្លោះនៃការអនុវត្តផែនការសកម្មភាព ២០១១-២០១៣ ព្រមទាំងបានរៀបចំផែនការយុទ្ធសាស្ត្រ និងសកម្មភាពជាតិបន្តជំហានទី២ រយៈពេលប្រាំឆ្នាំ២០១៤-២០១៨ ដើម្បីធ្វើជាមូលដ្ឋាន និងជាផែនទីបង្ហាញផ្លូវក្នុងការធ្វើសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ ផែនការនេះមានយុទ្ធសាស្ត្រជាគន្លឹះចំនួន០៤ លទ្ធផលរំពឹងទុកចំនួន១០ និងសកម្មភាពចម្បងៗចំនួន១៣៣ គ្របដណ្តប់លើការបង្ការទប់ស្កាត់បទល្មើសជួញដូរមនុស្សគ្រប់រូបភាព កិច្ចការពារជនរងគ្រោះទាំងកុមារ យុវវ័យ ស្ត្រី និងបុរស ការអនុវត្តច្បាប់ដើម្បីបង្ក្រាប សង្គ្រោះ និងផ្តន្ទាទោស និងការពង្រឹងនូវកិច្ច សហប្រតិបត្តិការ និងការចូលរួមគាំទ្រអនុវត្តពីគ្រប់ភាគីពាក់ព័ន្ធយ៉ាងទូលំទូលាយ ។

ដោយហេតុថា ផែនការសកម្មភាពជាតិនេះនឹងត្រូវបានអនុវត្តដោយគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងរាជធានី ខេត្តទាំង២៥ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំកែសម្រួលរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់គណៈកម្មាធិការជាតិជាថ្មី ដើម្បីសម្របសម្រួល ប្រមូលផ្តុំគ្រប់កិច្ចខិតខំប្រឹងប្រែង សហការ ការចូលរួមគាំទ្រធនធានឲ្យកាន់តែទូលំទូលាយ ពីគ្រប់ភាគីពាក់ព័ន្ធគ្រប់កម្រិត ទាំងក្នុងផ្ទៃក្នុងជាតិ និងជាមួយអន្តរជាតិ ។ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** ដែលហៅកាត់ថា **គ.ជ.ប.ជ** ជាយន្តការជាតិតែមួយដែលទទួលខុសត្រូវជម្រុញការអនុវត្តច្បាប់ គោលនយោបាយជាតិ និងអន្តរជាតិ ផែនការ និងគោលការណ៍រាជរដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ព្រមទាំងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃយ៉ាងល្អិតល្អន់ លើស្ថានភាព លទ្ធផល និងភាពប្រឈមទាំងឡាយ ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាព ដែលកើតឡើងក្នុងព្រះរាជាណាចក្រកម្ពុជា និងនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

ជាលទ្ធផលជាក់ស្តែង ក្នុងសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងឆ្នាំ២០១៤នេះ មានដូចខាងក្រោម ៖

## II. លទ្ធផលការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៤

នៅក្នុងឆ្នាំ២០១៤ កន្លងទៅនេះ គណៈកម្មាធិការជាតិ និងថ្នាក់ក្រោមជាតិ ប.ជ.រ.ព.ភ បានបន្តយកចិត្តទុកដាក់អនុវត្តផែនការសកម្មភាព និងទិសដៅភារកិច្ចរបស់ខ្លួន ដោយពង្រឹងកិច្ចសហប្រតិបត្តិការរវាងបណ្ដាក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ទីភ្នាក់ងារអង្គការសហប្រជាជាតិ ទីភ្នាក់ងារក្រុមហ៊ុនឯកជនទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងបានធ្វើឲ្យសម្រេចនូវលទ្ធផលដូចខាងក្រោម ៖

### ក- ការងារផ្នែកច្បាប់ គោលនយោបាយជាតិ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ

ដើម្បីសម្រួលដល់ការអនុវត្តភារកិច្ចឲ្យទទួលបានជោគជ័យ **រាជរដ្ឋាភិបាលដាក់ចេញនូវ ឯកសារគតិយុត្តិចំនួន ០៨** (សម្រាប់សម្រួលដល់**គណៈកម្មាធិការជាតិចំនួន០៧** សម្រាប់**ក្រសួងទេសចរណ៍ចំនួន០១**) **គណៈកម្មាធិកាជាតិដាក់ចេញសេចក្ដីសម្រេចចំនួន ០២ ក្រសួងមហាផ្ទៃដាក់ចេញសេចក្ដីសម្រេចចំនួន០១ ក្រសួងយុត្តិធម៌ចំនួន០១ ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទាចំនួន០១ និងគណៈកម្មាធិការជាតិ និងថ្នាក់ក្រោមជាតិកសាងបទដ្ឋានបន្ថែមចំនួន២៧** ដូចមានខាងក្រោម ៖

**រាជរដ្ឋាភិបាល និងគណៈកម្មាធិការជាតិ គ.ជ.ប.ជ បានដាក់ចេញ:**

១. ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ ស្ដីពីការបង្កើត គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

២. សេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល លេខ ១៤៥ សសរ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤ ស្ដីពី ការតែងតាំងសមាសភាព គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ។

៣. អនុក្រឹត្យលេខ ២៧៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

៤. សេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិលេខ ០០១/១៤ សសរ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរ មនុស្សថ្នាក់ក្រោមជាតិ ។

៥. សេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិ លេខ០០២/១៤ សសរ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ ២០១៤ ស្ដីពីការបង្កើតក្រុមការក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័នសម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

៦. បទដ្ឋានតែងតាំងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.រ.ភ មាន៖

- ព្រះរាជក្រឹត្យ នស/រកត/១១១៤/១២៩៥ តែងតាំងថ្នាក់អគ្គលេខាធិការ គ.ជ.ប.ជ ០១រូប
- អនុក្រឹត្យ លេខ១៥១៨ អនក្រ.តត តែងតាំងអគ្គលេខាធិការរង ០៧រូប
- អនុក្រឹត្យ លេខ១៧៣៧ អនក្រ.តត តែងតាំងអគ្គលេខាធិការរង ០១រូប
- អនុក្រឹត្យលេខ១៦៦០អនក្រ.តត តែងតាំងថ្នាក់ប្រធានលេខាធិការដ្ឋាន និងមន្ត្រីជំនួយការ០៧រូប
- ប្រកាសក្រសួងមហាផ្ទៃលេខ ៥២៤០ប្រ.ក តែងតាំងថ្នាក់អនុប្រធានលេខាធិការដ្ឋាន និងមន្ត្រីជំនួយការ ១៣រូប ។

**ក្រសួងទេសចរណ៍:**

រាជរដ្ឋាភិបាលបានដាក់ចេញអនុក្រឹត្យលេខ ១៩១ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងមណ្ឌលកំសាន្តទេសចរណ៍មនុស្សពេញវ័យ ។

**ក្រសួងយុត្តិធម៌:**

ចេញសេចក្តីសម្រេចលេខ២២កយ.សសរ/១៤ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្តីពីការបង្កើតក្រុមបច្ចេកទេសនៃកម្មវិធីអូស្ត្រាលី អាស៊ី ដើម្បីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា ។

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា:**

បទដ្ឋានអប្បរមាលេខ១២៧៤សអយ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពី (**បទដ្ឋានអប្បបរិមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល**) ។

**លេខាធិការដ្ឋានដឹកនាំ ប.ជ.រ.ព.ភ ខេត្តព្រះសីហនុ:**

បានចេញលិខិតបង្គាប់ការលេខ០០៣ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ ស្តីពីដោះស្រាយក្មេងអនាថា ទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនទប់ស្កាត់ការជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ ។

**ការរៀបចំ និងកសាងបទដ្ឋានបន្ថែម:**

រៀបចំសេចក្តីព្រាងដាក់ជូនគណៈកម្មាធិការជាតិគ.ជ.ប.ជ ដើម្បីចុះហត្ថលេខា

**ក. សម្រាប់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** ចំនួន ០២ ឯកសារ គឺ៖

១. ធ្វើសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិ ស្តីពីរចនាសម្ព័ន្ធ និងតួនាទីភារកិច្ចលេខាធិការដ្ឋាននៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។

២. ធ្វើសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិ ស្តីពីតួនាទី និងភារកិច្ចក្រុមជំនួយការអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។

**ខ. សម្រាប់គណៈកម្មាធិការរាជធានី ខេត្ត** (គ.រ.ប.ជ និងគ.ខ.ប.ជ) ចំនួន ២៥៖

- សេចក្តីសម្រេច ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការរាជធានី (គ.រ.ប.ជ) ០១ច្បាប់ និង
- សេចក្តីសម្រេច ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការខេត្ត (គ.ខ.ប.ជ) ២៤ច្បាប់

## ខ- ការអនុវត្តន៍យុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស

### ១- ការងារបង្ការ-ទប់ស្កាត់

#### ១.១-ការផ្សព្វផ្សាយ អប់រំ ដើម្បីបង្ការ

ក្នុងឆ្នាំ២០១៤កន្លងទៅនេះ ការងារផ្សព្វផ្សាយទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរ និងសមត្ថកិច្ច បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយជាសាធារណៈទៅតាមគោលដៅ និងមានមនុស្សចូលរួមសរុបមានចំនួន **១,១៧៤,០២៤**នាក់ ស្រី**៥៣៥,៩១៩**នាក់ ព្រះសង្ឃ**១៥**អង្គ បើប្រៀបធៀបតួលេខនៃការផ្សព្វផ្សាយទៅនឹងឆ្នាំ២០១៣ ដែលមានចំនួន **៧៩២,៥៣២**នាក់ នោះមានការកើនឡើងចំនួន ៣៨១,៤៩២នាក់ ស្មើ ៤៨,១៣ភាគរយ ដោយមានសកម្មភាពដូចខាងក្រោម ៖

- **<u>ក្រសួងអប់រំ យុវជន និងកីឡា</u>** បានផ្សព្វផ្សាយក្របខណ្ឌច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារដល់សមាជិកក្រុមការងារនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានសិក្សាក្នុងខេត្តចំនួន១២ ដែលមានបុគ្គលិកអប់រំចូលរួមចំនួន **៩,៤៦២**នាក់ ស្រី**៧៥**នាក់ ។
- **<u>ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា</u>** បានផ្សព្វផ្សាយគោលនយោបាយស្តីពី បទដ្ឋានអប្បបរិមាសម្រាប់ថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយមានអង្គការដែលមានមណ្ឌលថែទាំចូលរួម ចំនួន៣៧ និងមានសមាសភាពចូលរួម ចំនួន**១១៩**នាក់ ។
- **<u>ក្រសួងកិច្ចការនារី</u>** បានផ្សព្វផ្សាយស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ច ដល់ភូមិចំនួន០៤ និងឃុំចំនួន០២ (ឃុំអន្លង់គ្រោត ឃុំក្បាលត្រាច) ក្នុងខេត្តពោធិសាត់ ដែលមានអ្នកចូលរួមសរុបចំនួន**៤០០**នាក់ (ស្រី**២៥៦**នាក់) ។
- **<u>អគ្គស្នងការដ្ឋាននគរបាលជាតិ</u>** ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាល ខេត្តស្វាយរៀង ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ ជាអង្គភាពអនុវត្តផ្ទាល់ បានផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់ផ្ទះម៉ាស្សាខារ៉ាអូខេ ផ្ទះសំណាក់ អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សបានចំនួន១០៣លើក សរុបរួមមាន ចំនួន **១០៣,៩០៣**នាក់ (ស្រី**៤៣,៤៧៧**នាក់) ។
- **<u>លេខាធិការដ្ឋាននៃគណៈកម្មាធិការ ប.ជ.រ.ព.ភ ខេត្ត</u>**
បានរៀបចំវេទិកាសាធារណៈផ្សព្វផ្សាយតាមវិទ្យុមានចំនួន២១លើក (ខេត្តសៀមរាបចំនួន១២លើក ខេត្តឧត្តរមានជ័យចំនួន០៥លើក ខេត្តបាត់ដំបងចំនួន០៣លើក) តាមទូរទស្សន៍ ចំនួន០១លើក បានប្រារព្ធទិវា១២ធ្នូ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ កិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឧបាយកលជនល្មើស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព គ្រោះថ្នាក់ផ្សេងៗដោយការធ្វើទេសន្តរប្រវេសន៍ការងារ ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ការការពារសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ការទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើកុមារ ការទប់ស្កាត់អំពើជួញដូរមនុស្ស និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ សរុបបានចំនួន **១,០៦០,១៨០**នាក់ (ស្រី**៥៩១,៦១១**នាក់) កុមារចំនួន**១០**នាក់ ព្រះសង្ឃចំនួន **១៥**អង្គ ក្នុងនោះមានដូចខាងក្រោម៖

| ល.រ | ឈ្មោះខេត្ត | ចំនួនអ្នកចូលរួមសរុប | ចំនួនស្ត្រីចូលរួម |
|---|---|---|---|
| ១ | រាជធានីភ្នំពេញ | មិនមានរបាយការណ៍បញ្ជាក់ | |
| ២ | ខេត្តកណ្តាល | ២១,៣២២នាក់ | ១២,៣៨៥នាក់ |
| ៣ | ខេត្តស្វាយរៀង | ៧,៥៩២នាក់ | ៣,៩៥៤នាក់ |
| ៤ | ខេត្តសៀមរាប | ២០,២០៩នាក់ | ១១,៦១៩នាក់ |
| ៥ | ខេត្តកំពង់ឆ្នាំង | ១១៩,៨៣១នាក់ | ៥៩,៤៦៩នាក់ |
| ៦ | ខេត្តព្រះវិហារ | ៧៤,០០៩នាក់ | ៣៩,៨៣០នាក់ |

| | | | |
|---|---|---|---|
| ៧ | ខេត្តព្រះសីហនុ | ៥០,៩១៨នាក់ (ព្រះសង្ឃ១៥អង្គ) | ១២,៧៨៣នាក់ |
| ៨ | ខេត្តក្រចេះ | ២,៥៧០នាក់ | ១,៨០៧នាក់ |
| ៩ | ខេត្តស្ទឹងត្រែង | ១៩៨នាក់ | ១៦៩នាក់ |
| ១០ | ខេត្តកំពង់ស្ពឺ | ១២,៧១២នាក់ | ៥,១៦៣នាក់ |
| ១១ | ខេត្តបាត់ដំបង | ៨៨៨,៨៩៥នាក់ | ២២៦,៥០៥នាក់ |
| ១២ | ខេត្តកំពង់ធំ | ៥,៩៣២នាក់ | ៣,៤៧៣ នាក់ |
| ១៣ | ខេត្តតាកែវ | ៨,៤១២នាក់ | ៥,៤៤៩នាក់ |
| ១៤ | ខេត្តបន្ទាយមានជ័យ | មិនមានរបាយការណ៍បញ្ជាក់ | |
| ១៥ | ខេត្តកំពត | ៤,៦៤៦នាក់ | ២,០០៩នាក់ |
| ១៦ | ខេត្តកែប | ៦៨,១៤៦នាក់ | ៣៤,៥១៩នាក់ |
| ១៧ | ខេត្តព្រៃវែង | ១០,៧០២នាក់ | ៧,២៥៥នាក់ |
| ១៨ | ខេត្តកោះកុង | ៦៧៥នាក់ | ៣៤៩នាក់ |
| ១៩ | ខេត្តពោធិសាត់ | ១៥៧,៥៨៣នាក់ | ៧៣,៥៧៣នាក់ |
| ២០ | ខេត្តកំពង់ចាម | ៣,៣៣៩នាក់ | ១,១៣៧នាក់ |
| ២១ | ខេត្តឧត្តរមានជ័យ | ៣០៥នាក់ | ១៣៦នាក់ |
| ២២ | ខេត្តរតនៈគីរី | ១,២០៦នាក់ | ៤៩២នាក់ |
| ២៣ | ខេត្តប៉ៃលិន | មិនមានរបាយការណ៍បញ្ជាក់ | |
| ២៤ | ខេត្តមណ្ឌលគិរី | ៩៤៣នាក់ | ៤៣៥នាក់ |
| ២៥ | ខេត្តត្បូងឃ្មុំ | ខេត្តបង្កើតថ្មី | |

### ១.២- ការអនុវត្តវិធានការបង្ការ-ទប់ស្កាត់

ពិនិត្យជារួមក្នុងឆ្នាំ២០១៤ កន្លងទៅនេះ លទ្ធផលសម្រេចបានលើការងារបង្ការ-ទប់ស្កាត់អំពើជួញដូរមនុស្សដោយនាយកដ្ឋានជំនាញ សមត្ថកិច្ច និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត សហការជាមួយស្ថាប័នពាក់ព័ន្ធ លទ្ធផលមានដូចខាងក្រោម ៖

- **<u>ការងារជំនាញប្រឆាំងការជួញដូរមនុស្ស នៅថ្នាក់ក្រសួង និងរាជធានី-ខេត្ត</u>**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ៖

- បានធ្វើការសម្ភាសន៍ពលរដ្ឋខ្មែរនិងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍បានចំនួន១,៦៩៤គូ និងសាកសួរសុខទុក្ខនារីខ្មែរដែលរៀបការរួច ហើយទៅរស់នៅក្រៅប្រទេសតាមរយៈទូរស័ព្ទផ្ទាល់របស់សាម៉ីខ្លួនបានចំនួន៣៥៦នាក់ដើម្បីបញ្ជាក់អំពីសុវត្ថិភាព ។ ក្នុងនោះយើងរកឃើញបទល្មើស០២ករណី (អាពាហ៍ពិពាហ៍ក្លែងក្លាយ ០១ករណី និងជួញដូរមនុស្ស ០១ករណី) និងអនុវត្តតាមនីតិវិធី
- បានធ្វើការសម្ភាសន៍ជនរងគ្រោះដែលបញ្ជូនមកពីក្រៅប្រទេសវិញ ក្នុងនោះជំនាញបានស្រាវជ្រាវរកឃើញករណីជួញដូរមនុស្សចំនួន១០ករណី ចាប់ខ្លួនជនសង្ស័យបានចំនួន១២នាក់ដោយអនុវត្តតាមនីតិវិធីជំនាញ និងបញ្ជូនសំណុំរឿងចំនួន១៦ករណីទៅតុលាការ

- តាមរយៈបណ្តឹង អង្គភាពជំនាញបានស្រាវជ្រាវរកឃើញអត្តសញ្ញាណជនសង្ស័យករណីជួញដូរពលកម្មចំនួន៣៥នាក់ ហើយបានកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។ ក្នុងនោះតុលាការបានចេញដីកាចាប់ខ្លួនជនសង្ស័យបានចំនួន០៨នាក់ (ស្រី០៣នាក់) និង១៥នាក់ទៀតតុលាការរាជធានី-ខេត្ត កំពុងពិនិត្យចាត់ការតាមនីតិវិធីបន្ត ។

- **ស្នងការរាជធានី ខេត្តៈ**
  - បានអនុវត្តនីតិវិធីស្រាវជ្រាវ និងតាមដានលើគោលដៅមុខរបរ ដែលសង្ស័យថាពាក់ព័ន្ធនឹងបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ នៅទូទាំង២៥រាជធានី-ខេត្ត បានចំនួន៨៥២លើក លើគោលដៅនៃការគ្រប់គ្រង
  - បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម និងផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដល់ម្ចាស់អាជីវកម្ម ស្ត្រីក្នុងហាងម៉ាស្សា ខារ៉ាអូខេ សរុបបានចំនួន ៣៥៤គោលដៅ មនុស្សចំនួន ១,៦៩០នាក់ (ស្រី១,១៥៦នាក់) ក្នុងនោះមាន ៖
    - ស្នងការដ្ឋាននគរបាលខេត្តតាកែវ បានចំនួន ១១២គោលដៅ និងមានមនុស្សចូលរួមចំនួន ៥១០នាក់ (ស្រី៣៦៦នាក់) ។
    - ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង បានចំនួន១១គោលដៅ ឲ្យអនុវត្តតាមច្បាប់ និងមានមនុស្សចំនួន១០០នាក់ (ប្រុស០៥នាក់ ជាអនីតិជន) ។
    - ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង បានចំនួន០៩គោលដៅ និងមានមនុស្សចំនួន ១០៩នាក់ (ស្រី៩១នាក់) ។
    - ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ក្រចេះ និងមណ្ឌលគីរី បានចំនួន២១២គោលដៅ និងមានមនុស្សចំនួន៩៦៣នាក់ (ស្រី៦១៥នាក់) ។
    - ស្នងការដ្ឋាននគរបាលខេត្តកែប បានចំនួន ១០គោលដៅ និងមានមនុស្សចំនួន១០៨នាក់ (ស្រី៩៤នាក់) ។
  - ស្នងការដ្ឋាននគរបាលខេត្តកោះកុងបានបិទខ្លឹមសារណែនាំលេខ០១៦ ស.ជ.ណ តាមគោលដៅអាជីវកម្មបានចំនួន ៦១៩ច្បាប់
  - ស្នងការដ្ឋានរាជធានី ខេត្ត តាមដានបច្ចុប្បន្នភាពស្ថិតិ និងគ្រប់គ្រងប្រជាពលរដ្ឋខ្មែរ ដែលធ្វើចំណាកស្រុកស្វែងរកការងារគិតមកដល់ខែធ្នូ ឆ្នាំ២០១៤ សរុបមានចំនួន**២៦៨,៧៣២**នាក់ (ស្រី**១១៣,៦៩១**នាក់) អនីតិជន**៩,០៥៨**នាក់ (ស្រី ៣,៣៩១នាក់) បើប្រៀបធៀបតួលេខទៅនឹងខែធ្នូ ឆ្នាំ២០១៣ ថយចុះចំនួន ៥៦,៧៩៣នាក់ ស្មើនឹង១៧,៤៤ភាគរយ ។

- <u>**គណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ ខេត្ត ចំនួន០២**</u>

បានទប់ស្កាត់ និងស្វែងរកការងារធ្វើនៅប្រទេសថៃសរុបចំនួន**៨,៣០៦**នាក់ អប់រំប្រជាពលរដ្ឋចំណាកស្រុកដែលមានបំណងឆ្លងដែនខុសច្បាប់ (ស្រី**៣,៥៧៨**នាក់) ក្នុងនោះមាន ៖

- <u>**ខេត្តបន្ទាយមានជ័យ**</u> បានចំនួន**៧,៧៤៤**នាក់ (ស្រី**៣,៣៤២**នាក់)
- <u>**ខេត្តបាត់ដំបង**</u> បានចំនួន **៥៦២**នាក់ (ស្រី**២៣៦**នាក់) ។

តារាងសកម្មភាពអប់រំបង្ការ និងទប់ស្កាត់

| ល.រ | លេខាធិការដ្ឋានខេត្ត | សកម្មភាពទប់ស្កាត់ | ចំនួនរួម | ស្រី |
|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | ទប់ស្កាត់ និងអប់រំប្រជាពលរដ្ឋដែលត្រៀមធ្វើចំណាកស្រុកឆ្លងដែនខុសច្បាប់ទៅធ្វើការនៅប្រទេសថៃ | ៧,៧៨៥ នាក់ | ៣.៣៨២ នាក់ |
| ២ | បាត់ដំបង | ទប់ស្កាត់និងអប់រំប្រជាពលរដ្ឋដែលត្រៀមធ្វើចំណាកស្រុកដោយខុសច្បាប់ទៅធ្វើការនៅប្រទេសថៃ | ៥៦២ នាក់ | ២៣៦ នាក់ |

### ២- ការងារការពារ-ស្តារនីតិសម្បទាសមាហរណកម្ម និងមាតុភូមិនិវត្តន៍

នៅក្នុងឆ្នាំ២០១៨កន្លងទៅនេះ ពិនិត្យលើការងារការពារស្តារនីតិសម្បទាសមាហរណកម្ម និងមាតុភូមិនិវត្តន៍ជួយដល់ជនរងគ្រោះមានលទ្ធផលដូចខាងក្រោម ៖

#### ២.១-ការងារការពារ-ស្តារនីតិសម្បទាជនរងគ្រោះ

- មណ្ឌលសំចតខេត្តបន្ទាយមានជ័យបានដកហូតកុមារស្ត្រីនិងបុរសរងគ្រោះ និងងាយរងគ្រោះក្រោយពីការកំណត់អត្តសញ្ញាណ ក្នុងចំណោមជនទេសន្តរប្រវេសន៍ការងារ ដែលអាជ្ញាធរថៃបញ្ជូនមកវិញ សរុបមាននចំនួន**៩៨**នាក់ (ស្ត្រី **២៣**នាក់ កុមារ **៥៧**នាក់ ក្នុងនោះកុមារី**៣១**នាក់) ។ ជនរងគ្រោះ និងងាយរងគ្រោះ ទាំងអស់ត្រូវបានប្រគល់ឲ្យអង្គការដៃគូ និងកំពុងស្វែងរកដោយធ្វើការប៉ាន់ប្រមាណក្នុងការធ្វើសមាហរណកម្ម ទៅគ្រួសារវិញ ។
- ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានធ្វើមាតុនិវត្តន៍ជនរងគ្រោះជនជាតិវៀតណាម ចំនួន២១នាក់ ទៅប្រទេសវៀតណាមវិញ ។
- បានសហការជាមួយអង្គការ IOM និងផ្តល់សេវាជួយជនរងគ្រោះដោយអំពើជួញដូរពលកម្មចំនួន១២នាក់ ស្រី០៥នាក់ មកពីប្រទេសម៉ាឡេស៊ី ។
- មន្ទីរ ស.អ.យ រាជធានី-ខេត្ត ចំនួន០៧ខេត្ត (ភ្នំពេញ ពោធិ៍សាត់ កំពត ក្រចេះ សៀមរាប ស្វាយរៀង និងបន្ទាយមានជ័យ) សហការជាមួយអង្គការដៃគូ ជួយជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន៣២៦ករណី (ស្រី២៥៧នាក់) បានធ្វើសមាហរណកម្មទៅសហគមន៍វិញ១៤៨ករណី ឆ្លើយតបការជួយ១៥ករណី បញ្ជូនរកសេវាផ្សេងៗជាមួយអង្គការដៃគូ១៣៨ករណី បានបិទចំនួន០២ករណី និងកំពង់តាមដានបន្ត ចំនួន២៧ករណី ។
- មន្ទីរ ស.យ.អ.ខេត្តសៀមរាប បានទទួលកុមារា កុមារី ស្ត្រីរងគ្រោះដោយអំពើប្រទូស្តកេរ្តិ៍ អំពើហិង្សាក្នុងគ្រួសារ និងអំពើសញ្ចារកម្ម មានចំនួន០៧នាក់ និងស្រី០៦នាក់ កុមាររងគ្រោះ និងងាយរងគ្រោះទាំងនេះបានប្រគល់ឱ្យអង្គការដៃគូដើម្បីស្តារនីតិសម្បទា ។

## ២.២-ការងារទទួលពលករពីអាជ្ញាធរបរទេស

### ២.២.១- តាមរយៈអាជ្ញាធរបរទេស សហការជាមួយក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ

ក្នុងឆ្នាំ២០១៤កន្លងទៅនេះ អាជ្ញាធរតាមបណ្ដាខេត្តជាប់ព្រំដែន និងសមត្ថកិច្ចបានទទួលពលករទេសន្តរប្រវេសន៍ការងារពីអាជ្ញាធរបរទេសបញ្ជូន មកវិញសរុបមានចំនួន **៣១៨,៩១០**នាក់ (ស្រី**១១៣,២៥៣**នាក់) ក្នុងនោះកុមារមានចំនួន**៣៥,៦៧៤**នាក់ (កុមារីចំនួន**១,៩៥០**នាក់) បើប្រៀបធៀបចំនួនតួលេខរួមទៅនឹងឆ្នាំ២០១៣ មានការកើនឡើងចំនួន **២៣៧,៩៣៧**នាក់ ដូចមានតារាងខាងក្រោម៖

**<u>តារាងពលករទេសន្តរប្រវេសន៍ការងារ ដែលបានបញ្ជូនមកវិញតាមអាជ្ញាធរបរទេស</u>**

| បញ្ជូនមកពី | ចំនួនសរុប | ចំនួនស្ត្រី | ចំនួនកុមារសរុប | ចំនួនកុមារី |
|---|---|---|---|---|
| ប្រទេសថៃ | ៣១៨,៥៧៤នាក់ | ១១៣,១១២នាក់ | ៣៥,៥៥៤ នាក់ | ១,៨៨៨ នាក់ |
| ប្រទេសវៀតណាម | ២០០នាក់ | ១៩១នាក់ | ១២០នាក់ | ៦២នាក់ |
| ប្រទេសឥណ្ឌូនេស៊ី | ២១នាក់ | | | |
| ប្រទេសចិន | ៧៤នាក់ | ៧៤នាក់ | | |
| ប្រទេសម៉ាឡេស៊ី | ៣៨នាក់ | ២០នាក់ | | |
| ប្រ៊ុយណេ | ០៧នាក់ | | | |
| **សរុប** | **៣១៨,៩១០នាក់** | **១១៣,៣៨៧នាក់** | **៣៥,៦៧៤នាក់** | **១,៩៥០នាក់** |

សមត្ថកិច្ចនគរបាលនៅតាមបណ្ដាច្រក បានសម្ភាសន៍ពលករមួយចំនួន ក្ដាប់បានថា មានទេសន្តរ ប្រវេសន៍ចំនួន២,០៧០នាក់ ត្រូវអាជ្ញាធរថៃឃាត់ខ្លួនលើសពីរយៈពេល០១ខែមុននឹងបញ្ជូនមកកម្ពុជាវិញ ។ ចំពោះទេសន្តរប្រវេសន៍ ទាំងអស់នោះត្រូវបានអប់រំណែនាំឱ្យត្រឡប់ទៅលំនៅដ្ឋានវិញ ។

ពលករទេសន្តរប្រវេសន៍ការងារទាំងនោះ បានបញ្ជូនត្រឡប់តាមច្រកអន្តរជាតិភ្នំពេញ ក្នុងឆ្នាំ២០១៤ កន្លងទៅនេះសរុបមានចំនួន១៣៦នាក់ ក្នុងនោះមកពីប្រទេសឥណ្ឌូនេស៊ីចំនួន២១នាក់ ប្រទេសម៉ាឡេស៊ី ចំនួន៣៨នាក់ និងប្រទេសចិនចំនួន៧៤នាក់ និងប្រ៊ុយណេ ចំនួន០៧នាក់ ។ ចំណែកតាមច្រកអន្តរជាតិបាវិត ខេត្តស្វាយរៀង មានមកពីវៀតណាម ២០០នាក់ និងច្រកផ្សេងទៀត មានច្រកអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ច្រកអន្តរជាតិដូង ច្រកភ្នំដី និងច្រករំដួល ខេត្តបាត់ដំបង ច្រកជាំស្រងាំ ខេត្តឧត្តរមានជ័យ និងច្រកអានសេះ ខេត្តព្រះវិហារ ពលករត្រូវបានបញ្ជូនមកពីប្រទេសថៃ សរុបចំនួន ៣១៨,៥៧៤នាក់ ។

**<u>តារាងចំនួនពលករទេសន្តរប្រវេសន៍ ខាងលើដែលបញ្ជូនមកតាមច្រកមាន</u>**

| រាជធានី-ខេត្ត | តាមច្រកទ្វារ | ចំនួនរួម | ស្រី | កុមារ | កុមារី | ពីប្រទេស | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ថៃ | វៀតណាម | ឥណ្ឌូនេស៊ី | ចិន | ម៉ាឡេស៊ី | ប្រ៊ុយណេ |
| ភ្នំពេញ | អន្តរជាតិភ្នំពេញ | ១៣៦ | | | | | | ២១ | ៧៤ | ៣៨ | ០៧ |
| បន្ទាយមានជ័យ | អន្តរជាតិប៉ោយប៉ែត | ២៨៦,៥២៤ | ១០១,៩៥៩ | ៣៣,១២២ | ១,២១៧ | ២៨៦,៥២៤ | | | | | |
| បាត់ដំបង | អន្តរជាតិដូង | ១៥,០១៨ | ៨,៦៨៨ | ១,២២២ | ៣១៧ | ១៥,០១៨ | | | | | |
| | ភ្នំដី(គីឡូម៉ែត្រ១៣) | ៦,៨៧១ | ២,៣២៨ | ៩៥៩ | ៣៥៣ | ៦,៨៧១ | | | | | |
| | អូររំដួល | ០៣ | ០២ | | | ០៣ | | | | | |
| ឧត្តរមានជ័យ | ជាំស្រងាំ | ១០,១០៣ | ៨,១៧៧ | ៧៨៩ | | ១០,១០៣ | | | | | |
| ព្រះវិហារ | អន្តរជាតិអានសេះ | ៥៥ | ០២ | ០២ | ០១ | ៥៥ | | | | | |
| ស្វាយរៀង | អន្តរជាតិបាវិត | ២០០ | ១៩១ | ១២០ | ៦២ | | ២០០ | | | | |
| | **សរុប** | **៣១៨,៩១០** | **១១៣,២៥៣** | **៣៥,៦៧៤** | **១,៩៥០** | **៣១៨,៥៧៤** | **២០០** | **២១** | **៧៤** | **៣៨** | **០៧** |

### ២.២.២- ការសង្គ្រោះជនរងគ្រោះក្នុងប្រទេសគ្មានស្ថានបេសកកម្មការទូតកម្ពុជាតាំងនៅ

តំណាងព្រះរាជាណាចក្រកម្ពុជានៅប្រទេសនោះ គឺជាភ្នាក់ងារសម្រាប់ការផ្តល់ព័ត៌មាន និងឆ្លើយតបទៅនឹងករណីជួញដូរមនុស្ស ៖

- ការសង្គ្រោះ ធ្វើឡើងតាមរយៈក្រសួងការបរទេស និងស្ថានទូតកម្ពុជាដែលនៅជិតបំផុត ។ នៅពេលទទួលបានដំណឹងអំពីការរំលោភបំពាន ការកេងប្រវ័ញ្ច និងករណីជួញដូរមនុស្ស ក្រសួងការបរទេស ឬស្ថានទូតកម្ពុជាបានធ្វើទំនាក់ទំនងទៅអាជ្ញាធរនៃប្រទេសដែលជនរងគ្រោះស្នាក់នៅ ឲ្យជួយអន្តរាគមន៍ ផ្តល់កន្លែងសុវត្ថិភាពដល់ជនរងគ្រោះ និងតាមចាប់ជនឧក្រិដ្ឋនៃអំពើជួញដូរមនុស្ស ។
- ករណីសង្គ្រោះនៅក្រៅប្រទេសកន្លងមក ក្រសួងការបរទេសបានសហការជាមួយអង្គការ IOM ដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះ និងធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញ ។

**តារាង ចំនួនករណីសង្គ្រោះនៅក្នុងប្រទេសដែលគ្មានស្ថានទូតកម្ពុជា**

| ឆ្នាំ | ប្រទេសមានស្ថានទូតកម្ពុជា | ប្រទេសមានជនរងគ្រោះកម្ពុជា | ចំនួនជនដែលបានធ្វើមាតុភូមិនិវត្តន៍ |
|---|---|---|---|
| ២០១៤ | គូវ៉ែត | អារ៉ាប៊ីសាអ៊ូឌីត (សហការជាមួយស្ថានទូតថៃ នៅអារ៉ាប៊ីសាអ៊ូឌីត) | ០៧ នាក់ (មាតុភូមិនិវត្តន៍)<br>០២ នាក់ (កំពុងដោះស្រាយ) |

### ២.២.៣. ការសង្គ្រោះក្នុងប្រទេសមានស្ថានបេសកកម្មការទូតកម្ពុជាតាំងនៅ៖

ចំពោះប្រទេសដែលមានស្ថានទូតកម្ពុជាតាំងនៅ ការសង្គ្រោះធ្វើឡើងតាមរយៈកិច្ចសហការ និងការផ្លាស់ប្តូរ ព័ត៌មាន ដោយផ្ទាល់ជាមួយរដ្ឋាភិបាល ឬសមត្ថកិច្ចនៃប្រទេសនោះ និងដោយមានកិច្ចសហការជាមួយអង្គការដៃគូ ជាពិសេសអង្គការ IOM ស្ថានទូតនៃប្រទេសគោលដៅប្រចាំនៅកម្ពុជា និងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដោយទទួលបានលទ្ធផលដូចខាងក្រោម ៖

| ប្រទេស | ចំនួនជនរងគ្រោះ ដែលបានសង្គ្រោះ និងធ្វើមាតុភូមិនិវត្តន៍ (សរុប) | ផ្សេងៗ |
|---|---|---|
| ចិនប្រជាមានិត | ៧៤ នាក់ | ស្ត្រី ៧៤ |
| ឥណ្ឌូណេស៊ី | ២១ នាក់ | |
| ម៉ាឡេស៊ី | ៣៤នាក់ | ស្រី ២០ |
| ប្រ៊ុយណេ | ០៧នាក់ | |
| វៀតណាម | ១១នាក់ | បុរស០២ ស្រី ០៤ កុមារា០២ កុមារី ០៣<br>(២០០នាក់ទៀតបញ្ជូនដោយអាជ្ញាធរព្រំដែន) |
| **សរុប** | **១៤៧នាក់** | |

លើសពីនេះទៅទៀត ក្រសួងសង្គមកិច្ច បានធ្វើការបញ្ជូនស្ត្រី និងកុមាររងគ្រោះចំនួន ០៦រូប ដែលស្នាក់នៅមជ្ឈមណ្ឌលអង្គការ W.V.C ចំនួន០៣នាក់ និងអង្គការ AKP ចំនួន ០៣នាក់ ធ្វើមាតុភូមិនិវត្តន៍ទៅប្រទេសវៀតណាមវិញ ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ១៤៦នាក់ (ស្រី១៨នាក់) ដោយផ្ទាល់បន្ថែមទៀតពីអង្គការ IOM និងអង្គការពាក់ព័ន្ធ ដែលមកពីប្រទេស ឥណ្ឌូនេស៊ីចំនួន០៣នាក់ ម៉ាឡេស៊ីចំនួន៣៣នាក់ ថៃចំនួន១០៤នាក់ និងប្រទេសចិនចំនួន០៦នាក់ ជនរងគ្រោះ ខាងលើបានធ្វើសមាហរណកម្មទៅស្រុកកំណើតវិញ។

### ២.២.៤- ចំណាត់ការក្នុងការការពារជនរងគ្រោះកម្ពុជា នៅក្រៅប្រទេស

- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានចូលរួមផ្សព្វផ្សាយទូលំទូលាយជាមួយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដល់ពលករកំពុងធ្វើការនៅក្រៅប្រទេស ។
- បើកលេខទូរស័ព្ទ Hot lines នៅស្ថានទូតប្រចាំប្រទេសដែលមានពលករ និងនៅនាយកដ្ឋាន កុងស៊ុល នៃក្រសួងការបរទេស ដើម្បីទទួលពាក្យបណ្តឹង និងជួយជនរងគ្រោះ។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចែកជូនលេខទូរស័ព្ទស្ថានទូតនៃប្រទេសគោលដៅ ដល់ ពលករមុនពេលចេញដំណើរទៅតាមក្រុមហ៊ុនស្របច្បាប់។
- ក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិ ការអន្តរជាតិ ចាត់បញ្ជូនមន្ត្រីទទួលបន្ទុកការងារ និងពលករទៅប្រចាំការនៅស្ថានទូតកម្ពុជា និងចាត់ឲ្យទីភ្នាក់ងារជ្រើសរើសពលករឯកជនដែលបញ្ជូនពលករទៅក្រៅប្រទេសឲ្យបញ្ជូន តំណាងក្រុមហ៊ុន យ៉ាងតិច០១រូប ទៅធ្វើការតាមដានសុខទុក្ខ និងគ្រប់គ្រងពលករក្នុងប្រទេស ដែលទទួលពលករ កម្ពុជា គឺ ៖
  - នៅសាធារណរដ្ឋកូរ៉េមានទីប្រឹក្សាការងារ ០១រូប ជាមន្ត្រីមកពីក្រសួងការងារបណ្តុះបណ្តាល វិជ្ជាជីវៈ។
  - នៅប្រទេសម៉ាឡេស៊ីមានមន្ត្រី **០២** រូបទទួលបន្ទុកការងារពលករ និងតំណាងសមាគមនាំ ពលករទៅធ្វើការនៅក្រៅប្រទេស (*ACRA*) **០១** រូប ។
  - នៅប្រទេសថៃមានមន្ត្រី **០១រូប** ទទួលបន្ទុកការងារពលករ និងតំណាងសមាគមជ្រើស រើសពលករទៅធ្វើការនៅក្រៅប្រទេស(*ACRA*) **០១** រូប ។
- មន្ត្រីការទូតទទួលបន្ទុកការងារពលករ ត្រូវបានទទួលការណែនាំអំពីការងារជួយជនរងគ្រោះ ដោយអំពើជួញដូរមនុស្សមុនពេលទៅបំពេញបេសកកម្មការទូតនៅក្រៅប្រទេស ។
- មន្ត្រីទទួលបន្ទុក បានទាក់ទងផ្តល់ពត៌មាន និងទទួលអនុសាសន៍ណែនាំពីក្រសួងអំពីចំណាត់ការនៅ ពេលមានពលករត្រូវជួយសង្គ្រោះ ។
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្កើតមជ្ឈមណ្ឌលធនធានពលករទេសន្តរប្រវេសន៍ ដែលមានផ្នែកផ្តល់ព័ត៌មានសំខាន់ៗ ទាក់ទងពលករទេសន្តរប្រវេសន៍ការងារ និងមានប្រព័ន្ធ ទទួលដោះស្រាយបណ្តឹងតវ៉ារបស់ពលករទេសន្តរប្រវេសន៍នៅគ្រប់ខេត្ត និងនៅនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ។

## ៣- ការងារអនុវត្តន៍ច្បាប់

***កិច្ចសហប្រតិបត្តិការបង្ក្រាបបទល្មើស***

កម្លាំងសមត្ថកិច្ចនគរបាល ក៏ដូចជាកងរាជអាវុធហត្ថ បានបង្កើនការស៊ើបអង្កេត បង្ក្រាប និងផ្តន្ទាទោសជនល្មើសជួញដូរផ្លូវភេទ និងជួញដូរពលកម្មតាមផ្លូវច្បាប់ ។ ការស្រាវជ្រាវរកមេខ្យល់តាមរយៈក្រុម ជនទេសន្តរប្រវេសន៍ដែលត្រូវបានសមត្ថកិច្ចថៃបញ្ជូនត្រឡប់តាមច្រកអន្តរជាតិ ។ ស្ថានបេសកកម្មកម្ពុជា

នៅបណ្តាប្រទេសពាក់ព័ន្ធ ក៏បានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ ដើម្បីតាមស្រាវជ្រាវរកចាប់មេខ្យល់ជួញដូរមនុស្សគ្រប់រូបភាព ។ សមត្ថកិច្ចបានបន្តស៊ើបអង្កេតរកបណ្តាញ មេខ្យល់ ដែលនាំនារីខ្មែរចេញទៅប្រទេសចិន បន្ទាប់ពីមានករណីរងគ្រោះជាបន្តបន្ទាប់ដោយការរកគូស្រករមិនតាមឆន្ទៈនិងមានការជួញដូរ។ បណ្តាញ ទូរស័ព្ទពិសេសរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ទទួលការហៅចូល២៤ម៉ោង ដែលអាច ផ្តល់ពត៌មានសម្រាប់ការស៊ើបអង្កេត និងបង្ក្រាបទាន់ពេល ។

នៅក្នុងឆ្នាំ២០១៤កន្លងទៅនេះ បើប្រៀបធៀបទៅក្នុងឆ្នាំ ២០១៣ ចំពោះការបង្ក្រាបបទល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ក្នុងរាជធានី/ខេត្តទាំង២៥ ដោយកម្លាំងនគរបាលជាតិ និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស ចំនួននៃការបង្ក្រាបសរុប មានចំនួន៩៥លើ ៩៩ករណី ចាប់ខ្លួនជនជាប់សង្ស័យបញ្ជូនទៅសាលាដំបូងរាជធានី ខេត្តបានចំនួន១២៧ លើ១២៥នាក់ មានការថយចុះចំនួន០៤ករណីជនជាប់សង្ស័យកើនឡើងចំនួន០២នាក់ ។

ក្នុងចំនួនជនជាប់សង្ស័យ ចំនួន១២៧នាក់ មានជនសង្ស័យជាអនីតិជន ចំនួន០៦នាក់ និងជនជាតិបរទេសមានចំនួន១៣នាក់ (កាណាដា០២នាក់ ចិន០៦នាក់ តួគី០១នាក់ អង់គ្លេស០១នាក់ បារាំង០១នាក់ អូស្ត្រាលី០១នាក់ ថៃ០១នាក់) និងសង្គ្រោះជនរងគ្រោះបានចំនួន៤១២នាក់ ដែលមានអាយុក្រោម១៥ឆ្នាំ ចំនួន៦៧នាក់ អាយុ១៥ ដល់ក្រោម១៨ឆ្នាំ ចំនួន ៣៦នាក់ និងអាយុពី១៨ឆ្នាំឡើង ចំនួន៣០៩នាក់ ដោយធ្វើការប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន១០៤នាក់ អង្គការដៃគូ១៧នាក់ និង២៩១នាក់ទៀតប្រគល់ឲ្យគ្រួសារវិញ ។

ក្នុងបទល្មើសទាំង៩៥ករណី ជនជាប់សង្ស័យចំនួន១២៧នាក់ (ស្រី៤៥នាក់) ដែលសមត្ថកិច្ចយើងបង្ក្រាបហើយបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត មានតារាងលំអិតខាងក្រោម ៖

❖ **តារាង បង្ក្រាបបទល្មើសរួម**

| បង្ក្រាបសរុប | | | ជួញដូរផ្លូវភេទ | | | ជួញដូរមនុស្ស | | |
|---|---|---|---|---|---|---|---|---|
| #ករណី | ជនសង្ស័យ | ជនរងគ្រោះ | #ករណី | ជនល្មើស | ជនរងគ្រោះ | #ករណី | ជនសង្ស័យ | ជនរងគ្រោះ |
| ៩៥/៩៩ | ១២៧/១២៥ (ស្រី៤៥) បរទេស១៣ | ៤១២/៣១១ | ៥៤/៦៥ | ៦៩/៧៨ បរទេស ០៤ | ១៨២/២២៣ | ៤១/៣៤ | ៥៨/៤៧ បរទេស ០៩ | ២៣០/៨៨ |

❖ **តារាង ជនរងគ្រោះ**

| ចំនួនរួម | អាយុ<១៥ | អាយុ១៥-ក្រោម១៨ | អាយុ១៨+ | បញ្ជូនទៅមន្ទីរសង្គមកិច្ច | បញ្ជូនទៅអង្គការដៃគូ | បញ្ជូនទៅគ្រួសារ |
|---|---|---|---|---|---|---|
| ៤១២ | ៦៧ | ៣៦ | ៣០៩ | ១០៤ | ១៧ | ២៩១ |

❖ **តារាង ជនរងគ្រោះតាមប្រភេទបទល្មើស**

| ជនរងគ្រោះដោយការជួញដូរផ្លូវភេទ | | | | ជនរងគ្រោះដោយការជួញដូរមនុស្ស | | | |
|---|---|---|---|---|---|---|---|
| ចំនួនរួម | អាយុ<១៥ | អាយុ១៥-១៧ | អាយុ១៨+ | ចំនួនរួម | អាយុ<១៥ | អាយុ១៥-<១៨ | អាយុ១៨+ |
| ១៨២ | ៥១ | ១៩ | ១១២ | ២៣០ | ១៦ | ១៧ | ១៩៧ |

ធៀបនឹងឆ្នាំ ២០១៣ អំពើដែលសង្ស័យថា ជួញដូរមនុស្សមានចំនួន ៤១ករណី/៣៤ករណី ជនជាប់សង្ស័យចំនួន៥៨នាក់/៤៧នាក់(ស្រី២៥នាក់) (អនីតិជនចំនួន០២នាក់) មានជនបរទេស០៩នាក់ (សញ្ជាតិកាណាដា០១នាក់ តួគី០១នាក់ ចិន០៦នាក់ និងអង់គ្លេស០១នាក់) មានជនរងគ្រោះចំនួន ២៣០នាក់/៨៨នាក់។

❖ តារាងបទល្មើសពាក់ព័ន្ធអំពើជួញដូរមនុស្ស

| បទល្មើស | ចំនួនករណី | ចំនួនជនសង្ស័យ | ជនបរទេស |
|---|---|---|---|
| ការនាំអនីតិជនជាអាទ៍ចេញដោយមិនស្របច្បាប់ | ០២ | ០២ | |
| ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ១៦ | ១៩ (អនីតិជន០២) | ចិន០១ |
| ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន | ១០ | ១៥ | |
| អំពើជួញដូរមនុស្ស ដោយមានគោលដៅជាក់លាក់ | ០១ | ០១ | |
| អំពើជួញដូរមនុស្សសម្រាប់នាំឆ្លងដែន | ០៣ | ១០ | ចិន០៥ |
| ការជ្រើសរើសមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ចន៍ | ០២ | ០២ | |
| ការទិញពេស្យាចារកុមារ | ០៦ | ០៦ | អង់គ្លេស០១ កាណាដា០១ ទួគី០១ |
| អំពើអូសទាញពេស្យាចារកុមារ | ០១ | ០៥ | |
| **សរុប** | **៤១** | **៦០** | **០៩នាក់** |

**អំពើធ្វើអាជីវកម្មផ្លូវភេទ មានចំនួន៥៤ករណី/៦៥**ករណី **ជនជាប់សង្ស័យចំនួន៦៩នាក់/៧៨នាក់** (ស្រី២០នាក់) ក្នុងនោះមានជនសង្ស័យជាអនីតិជន **ចំនួន០៥នាក់** មានជនបរទេស០៤នាក់(សញ្ជាតិកាណាដា**០១**នាក់ អូស្ត្រាលី០១នាក់ បារាំង០១នាក់ និងថៃ០១នាក់) មានជនរងគ្រោះចំនួន១៨២នាក់/២២៣នាក់ ។

❖ តារាងបទល្មើសជួញដូរផ្លូវភេទ

| បទល្មើស | ចំនួនករណី | ចំនួនជនសង្ស័យ | ជនបរទេស |
|---|---|---|---|
| សញ្ចារកម្ម | ១២ | ១៨ | |
| សញ្ចារកម្មមានស្ថានទម្ងន់ទោស | ០២ | ០៤ | |
| សញ្ចារកម្មមានអនីតិជន | ០១ | ០១ | |
| សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០៥ | ០៩ | |
| ការផ្ដល់ទីកន្លែងសម្រាប់ការធ្វើពេស្យាចារកុមារ | ០១ | ០១ | |
| អំពើរួមភេទជាមួយអនីតិជន ក្រោម១៥ឆ្នាំ | ២១ | ២៣ | អូស្ត្រាលី០១,កាណាដា០១, ថៃ០១ |
| អំពើអាសសើរអនីតិជនក្រោម១៥ឆ្នាំ | ១១ | ១១ | បារាំង០១ |
| ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | ០១ | ០២ | |
| **សរុប** | **៥៤** | **៦៩** | **០៤នាក់** |

### ៤- ការងារកិច្ចការយុត្តិធម៌

នៅក្នុងឆ្នាំ២០១៤កន្លងទៅនេះ តាមទិន្នន័យដែលទទួលបានពីក្រុមការងារកិច្ចការយុត្តិធម៌ (ក្រសួងយុត្តិធម៌) ដែលបានដកស្រង់ពីតុលាការ សាលាដំបូងរាជធានី-ខេត្ត មួយចំនួនបានធ្វើចំណាត់ ការលើសំណុំរឿងបទល្មើស ក្រោមច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្ម ផ្លូវភេទ គិតត្រឹមរយៈពេល១០ខែ ក្នុងឆ្នាំ២០១៤ សម្រង់ទិន្នន័យដើមមានដូចខាងក្រោម ៖

**ចំណាត់ការរបស់តុលាការ សាលាដំបូងរាជធានី-ខេត្ត** ទទួលបានពីរាជធានី-ខេត្ត សរុបលទ្ធផលតាមដំណាក់កាលមាន៖

- **ដំណាក់កាលអយ្យការ**មានចំនួន១២២សំណុំរឿង ចាត់ការរួចមានចំនួន៦៧សំណុំរឿង ជនសង្ស័យមានចំនួន១៧៦នាក់(ស្រី៤០នាក់) ត្រូវបានចោទប្រកាន់ចំនួន១៧៦នាក់កំពុងចាត់ការមានចំនួន ៧៨សំណុំរឿង ។
- **ដំណាក់កាលស៊ើបសួរ**មានចំនួន៦៧សំណុំរឿង ចាត់ការរួចមានចំនួន៣០សំណុំរឿង ជនសង្ស័យមានចំនួន១៣៦នាក់(ស្រី៣៩នាក់) ឃុំខ្លួន ចំនួន៩៥នាក់ ក្រៅឃុំ ចំនួន២៥នាក់ ជាប់ចោទ ចំនួន១៣២នាក់ និងលើកលែងចោទ ចំនួន០៤នាក់ ។
- **ដំណាក់កាលជម្រះ**មានចំនួន៧៤សំណុំរឿង ចាត់ការរួចមានចំនួន១០សំណុំរឿង ជនសង្ស័យមានចំនួន១៦៩នាក់(ស្រី៦០នាក់) ឃុំខ្លួន ចំនួន៩៥នាក់ ក្រៅឃុំ ចំនួន២៥នាក់ ផ្តន្ទាទោសបានចំនួន៣១នាក់ (ជាប់ពន្ធនាគារក្រោម០៥ឆ្នាំ មានចំនួន២១នាក់ ជាប់ពន្ធនាគារពី០៥ឆ្នាំ ដល់១៥ឆ្នាំមានចំនួន១០នាក់ និងឲ្យរួចផុតពីបទចោទ ចំនួន០១នាក់ ។

ដូចមានតារាងខាងក្រោម ៖

| ដំណាក់កាល ចំណាត់ការ | ចំនួនសំណុំរឿង (ចាត់ការរួច) | ចំនួនជនរងគ្រោះ | | | ចំនួនជនជាប់ចោទ | | | ចំនួនជនជាប់ចោទ តាមដំណាក់កាលចំណាត់ការតុលាការ | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | ដំណាក់កាល អយ្យការ | ដំណាក់កាលស៊ើបសួរ | | | | ដំណាក់កាលជំនុំជម្រះ | | | |
| | | អនីតិជន | នីតិជន | សរុប (ស្រី) | អនីតិជន | នីតិជន | សរុប (ស្រី) | ត្រូវចោទ | ឃុំខ្លួន | ក្រៅឃុំ | ជាប់ចោទ | លើកលែងចោទ | ឃុំខ្លួន | ក្រៅឃុំ | ផ្តន្ទាទោស | រួចពីបទចោទ |
| អយ្យការ | ១២២ (ស្រី៦៧) | ៥៦ | ៩៦ | ១៨៦ (១៤៨) | ៦ | ១៣៩ | ១៧៦ (៤០) | | | | | | | | | |
| ស៊ើបសួរ | ៦៧ (ស្រី៣០) | ៥១ | ៦៩ | ១២៣ (៩៩) | ៨ | ១១៩ | ១៣៦ (៣៩) | ១៧៦ | ៩៥ | ២៥ | ១៣២ | ៤ | ៩៥ | ៧១ | ក្រោម៥ឆ្នាំ : ២១ន<br>៥ដល់១៥ឆ្នាំ: ១០ន | ១ |
| ជម្រះ | ៧៤ (ស្រី១០) | ៣៩ | ៤៣ | ១០០ (៥៨) | ៦ | ១៥២ | ១៦៩ (៦០) | | | | | | | | | |
| សរុប | | | | | | | | ១៧៦ | ៩៥ | ២៥ | ១៣២ | ៤ | ៩៥ | ៧១ | ៣១នាក់ | ១ |

### ៥-ការងារសហប្រតិបត្តិការអន្តរជាតិ

ក្នុងឆ្នាំ២០១៩កន្លងទៅនេះ ការចូលរួមកិច្ចប្រជុំ និងបំពេញកិច្ចសហប្រតិបត្តិការ លើការងារ ពាក់ព័ន្ធទៅនឹងអំពើជួញដូរមនុស្សនៃប្រទេសក្នុងតំបន់ សរុបមាន**ចំនួន ៤៦**លើកក្នុងនោះមាន ៖

អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ ០៥លើក ក្រុមការងារខមមីត ០១លើក ក្រសួងកិច្ចការនារីចំនួន០៣លើក ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាចំនួន ០២លើក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ០១លើក នាយកដ្ឋានប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជននៃអគ្គស្នងការដ្ឋាននគរបាលជាតិ ចំនួន២៣លើក លេខាធិការដ្ឋានខេត្ត ព្រះវិហារចំនួន០១លើក ស្វាយរៀងចំនួន០៦លើក កណ្តាលចំនួន០១លើក ប៉ៃលិនចំនួន០១លើក មណ្ឌលគីរីចំនួន០១លើក និងខេត្តស្ទឹងត្រែងចំនួន ០១លើក ។

❖ **តារាងសកម្មភាពកិច្ចសហប្រតិបត្តិការ**

| ក្រសួង ស្ថាប័ន | សកម្មភាពកិច្ចសហប្រតិបត្តិការ | ទីកន្លែង |
|---|---|---|
| លេខាធិការដ្ឋាន ប.ជ.រ. ព.ភ ថ្នាក់ជាតិ | ▪ ជួបពិភាក្សា ជាមួយប្រតិភូប្រទេសហ្វីលីពីន(០១លើក) ប្រតិភូសហរដ្ឋអាមេរិក (០២លើក) ប្រធានថ្នាក់តំបន់អង្គការ IoM (០១លើក) ប្រធានថ្នាក់តំបន់គម្រោង AARTIP (០១លើក) ស្តីពីកិច្ចសហការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | លេខាធិការដ្ឋានប.ជ.រ.ព.ភ |
| ក្រុម ការងារ COMMIT | ▪ ចូលរួមកិច្ចប្រជុំក្រុមការងារខមមីតថ្នាក់តំបន់ (កម្ពុជា ថៃ ឡាវ វៀតណាម ភូមា) (Regional COMMIT Taskforce Meeting) រយៈពេល០២ថ្ងៃ (១៣-១៤/០១/២០១៩) នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់រាជធានីភ្នំពេញ ។ គោលបំណងចែករំលែកព័ត៌មាន និងពិភាក្សាគ្នាក្នុងចំណោមសមាជិកក្រុមការងារខមមីត ស្តីពីវឌ្ឍនភាពចុងក្រោយ និងត្រៀមធ្វើសមាហរណកម្មសកម្មភាពទៅនឹងគម្រោងថ្មី។ | រាជធានីភ្នំពេញ |
| ក្រសួង កិច្ចការនារី | ▪ លិខិតផ្ញើជូនស្ថានទូតម៉ាឡេស៊ីប្រចាំនៅកម្ពុជាជុំវិញកិច្ចពិភាក្សាបន្តលើសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នា រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលម៉ាឡេស៊ីស្តីពីកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។<br>▪ ចូលរួមកិច្ចប្រជុំក្រុមការងារ ខមមីត ថ្នាក់តំបន់លើកទី២ (SecondRegional COMMIT Taskforce Meeting) និងកិច្ចប្រជុំគណៈគ្រប់គ្រងគម្រោង (Project Management Board Meeting) (១៩-២០/០៥/២០១៩) ដែលមានសមាជិកប្រទេស (កម្ពុជា ចិន ឡាវ មីយ៉ាន់ម៉ា ថៃ វៀតណាម និងលេខាធិការដ្ឋាន UN-ACT ថ្នាក់តំបន់ និងលេខាធិការដ្ឋាន UN-ACT ទាំង០៦ប្រទេស ដែលមានចំនួនសរុប ៣៥ នាក់ ។<br>▪ ប្រជុំពិគ្រោះយោបល់លើកទី២ ស្តីពីការពង្រឹងភាពជាដៃគូជាមួយអ្នករាយការណ៍ជាតិអំពីការជួញដូរមនុស្ស និងយន្តការសមមូល (Second Consultative Meeting on Stregthening Partnerships with National Rapporters on Trafficking in Persons and Equivalent Mechanism) សមាសភាពចូលរួមមាន តំណាងមកពីអង្គភាពជាតិប្រឆាំងការជួញដូរមនុស្ស ចំនួន២៦ប្រទេស គ្រប់តំបន់ក្នុងពិភពលោក ។ | ប្រទេសកម្ពុជា<br>ប្រទេសថៃ<br>ប្រទេសថៃ |

| | | |
|---|---|---|
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា (០២លើក) | ▪ ចូលរួមសិក្ខាសាលាអាស៊ាន ស្តីពីការលើកកម្ពស់ការទទួលបានយុត្តិធម៌សម្រាប់ស្ត្រីរងគ្រោះដោយអំពើហិង្សា ក្នុងរឿងក្តីជួញដូរមនុស្សមានចំនួន១០ប្រទេស គឺ ប្រទេសកម្ពុជា ឡាវ វៀតណាម សាំងហ្គាពួរ ភូមា ថៃ ប្រ៊ុយណេ ម៉ាឡេស៊ី ឥណ្ឌូណេស៊ី និងហ្វីលីពីន ។<br>▪ ចូលរួមសិក្ខាសាលាតំបន់មេគង្គលើកទី៥ស្តីពីយុទ្ធសាស្ត្រក្នុងការការពារអំពើជួញដូរមនុស្សនិងផ្លាស់ប្តូរបទពិសោធន៍ជាមួយប្រទេសក្នុងអនុតំបន់មេគង្គមានចំនួន ០៥ប្រទេស គឺប្រទេសកម្ពុជា ឡាវ វៀតណាម ថៃ និងជប៉ុន។ | ប្រទេសប្រ៊ុយណេ<br><br><br>ប្រទេសថៃ |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (០១លើក) | ចូលរួមជាមួយប្រទេសសមាជិកអាស៊ាន នៅប្រទេសមីយ៉ាន់មា ថៃ និង ឡាវ ក្នុងការពិភាក្សា និងព្រាងឧបករណ៍សម្រាប់អនុវត្តសេក្តីថ្លែងការណ៍របស់មេដឹកនាំអាស៊ានស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិពលករទេសន្តរប្រវេសន៍។ | ប្រទេសថៃ |
| អគ្គស្នងការដ្ឋាននគរបាលជាតិ (២៣លើក) | ▪ នាយនគរបាល នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ០១រូប បានចូលរួមវគ្គ បណ្តុះបណ្តាល០១លើក ស្តីពីការគ្រប់គ្រងការអនុវត្តច្បាប់ក្នុងតំបន់អាស៊ីលើកទី៣៤ ក្រោមប្រធានបទការជួញដូរមនុស្ស និងការរត់ពន្ធមនុស្ស ។<br>▪ ទៅចូលរួមសិក្ខាសាលា ចំនួន០២លើក នៅប្រទេសថៃ ស្តីពីនីតិវិធីកំណត់អត្តជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងស្តីពីឧក្រិដ្ឋកម្មឆ្លងដែនពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ។<br>▪ ទៅចូលរួមសិក្ខាសាលា ចំនួន០១លើក បណ្តុះបណ្តាលចំនួន០៦លើកសិក្ខាលាសានៅប្រទេសប្រ៊ុយណេ០១លើក ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការស៊ើបអង្កេតបទល្មើសឆ្លងដែនពាក់ព័ន្ធ និងការជួញដូរមនុស្ស។ បណ្តុះបណ្តាលនៅប្រទេសហ្វីលីពីន០១លើក ស្តីពីនីតិវិធីសម្ភាសន៍ជនរងគ្រោះ ការ ស៊ើបអង្កេតនៅនឹងកន្លែង និងជាពិសេសទាក់ទងករណីកុមារ, បណ្តុះបណ្តាលនៅប្រទេសឥណ្ឌូណេស៊ី០១លើក ស្តីពីជំនាញស៊ើបអង្កេតការជួញដូរមនុស្ស, និងវគ្គស្តីការគ្រប់គ្រងការអនុវត្តច្បាប់ក្នុងតំបន់អាស៊ី ARLEMP លើកទី៣៥ ស្តីពីការជួញដូរមនុស្ស និងការរត់ពន្ធមនុស្ស ។<br>▪ ទៅចូលរួមសិក្ខាសាលា ចំនួន០២លើក ស្តីពីការស៊ើបអង្កេត និងពង្រឹងផ្នែកអន្តោប្រវេសន៍ឆ្លងដែន ក្នុងតំបន់អាស៊ីអាគ្នេយ៍ (នៅក្នុង ប្រទេសឥណ្ឌូនេស៊ី) និងការយល់ដឹងអំពីរបៀបរាយការណ៍ការជួញដូរមនុស្ស(នៅប្រទេសភូមា) ។<br>▪ ទៅចូលរួមសិក្ខាសាលា០៧លើក ស្តីពីការឆ្លើយតប ការរំលោភបំពានទៅលើកុមារក្នុងប្រព័ន្ធយុត្តិធម៌ (នៅក្នុងប្រទេសថៃ) ស្តីពីការលើកស្ទួយបណ្តាញទំនាក់ទំនងក្នុងចំនោមប្រទេសអាស៊ាន លើការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (នៅប្រទេសជប៉ុន) ស្តីពីបច្ចេកទេសស៊ើបអង្កេតបទល្មើសជួញដូរមនុស្ស (នៅប្រទេសរុស្ស៊ី) និងបណ្តុះបណ្តាល០១លើក ស្តីពីការស៊ើបអង្កេតការរត់ពន្ធមនុស្ស (នៅប្រទេសឥណ្ឌូនេស៊ី) ។<br>▪ ជួបពិភាក្សា និងពង្រាង MOU ជាមួយសន្តិសុខសាធារណៈ នៃសាធារណៈរដ្ឋប្រជាមានិតចិន។ | ប្រទេសវៀតណាម<br><br><br>ប្រទេសថៃ<br><br><br>ប្រទេសប្រ៊ុយណេ ហ្វីលីពីន ឥណ្ឌូនេស៊ី វៀតណាម<br><br><br>ប្រទេសឥណ្ឌូនេស៊ី ប្រទេសភូមា<br>ប្រទេសថៃ<br>ប្រទេសជប៉ុន<br>ប្រទេសរុស្ស៊ី<br>ប្រទេសឥណ្ឌូនេស៊ី |

| | | |
|---|---|---|
| | ▪ ជួបពិភាក្សាព្រាងកិច្ចសហប្រតិបត្តិការជាមួយអង្គភាពស៊ើបអង្កេតពិសេស ថៃ DSI ។ | |
| **លេខាធិការដ្ឋាន ប.ជ.រ.ព.ភ ខេត្តព្រះវិហារ** | ▪ រៀបចំកិច្ចប្រជុំទ្វេភាគីកម្ពុជានិងឡាវចំនួន០២លើកស្តីពីកិច្ចសហប្រតិបត្តិការរក្សាសន្តិសុខតាមបណ្តាយព្រំដែនក្នុងការបង្ការ-ទប់ស្កាត់ និងដោះស្រាយរាល់បទល្មើសដែលកើតមានពាក់ព័ន្ធអំពើជួញដូរមនុស្សការរត់ពន្ធ និងការធ្វើចំណាកស្រុកខុសច្បាប់ ។ | ប្រទេសកម្ពុជា |
| **លេខាធិការដ្ឋាន ប.ជ.រ.ព.ភ ខេត្តស្វាយរៀង** | ▪ លេខាធិការដ្ឋាន ប.ជ.រ.ភ.ព ខេត្ត និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សហការជាមួយអង្គការសន្តិសេនាទៅចូលរួមទស្សនកិច្ចសិក្សា ស្តីពីកិច្ចការពារកុមារបន្លាស់ទីនៅទីក្រុងហូជីម៉ិញ ប្រទេសវៀតណាម ។ | ប្រទេសវៀតណាម |
| | ▪ បានចូលរួមប្រជុំ ស្តីពីកិច្ចសហប្រតិបត្តិការការពារព្រំដែន ជាមួយគណៈប្រតិភូការពារព្រំដែនខេត្តឡុនអាន ចំនួន០១លើក មានវត្តមានចូលរួម២៥នាក់ នៅទីបញ្ជាការកងទ័ពការពារព្រំដែនស្រុកមុខហ៊្វា ខេត្តឡុងអាន ប្រទេសវៀតណាម | ប្រទេសវៀតណាម |
| | ▪ មន្ទីរសង្គមកិច្ចខេត្តបានបញ្ជូនស្ត្រី និងកុមារជនជាតិវៀតណាម ត្រូវបានគេជួញដូរមកកម្ពុជាទៅប្រគល់ឲ្យអាជ្ញាធរវៀតណាមវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិបាវិត ចំនួន០៦នាក់ស្រី ក្នុងនោះកុមារី០៣នាក់ដែលមានទីលំនៅ សុខចាង ដុងថាប់ កាន់ថឺ ឃ្លាំង និងកៀងយ៉ាង ។ | ប្រទេសវៀតណាម |
| | ▪ បានរៀបចំកិច្ចប្រជុំទ្វេភាគីកម្ពុជា (ខេត្តតៃនិញ)(ខេត្តឡុងអាន) វៀតណាម ស្តីពីកិច្ចការពារកុមារ និងការធ្វើបន្លាស់ទី វត្តមានចូលរួមចំនួន៣៨នាក់ នៅសាលប្រជុំសាលាខេត្ត គាំទ្រដោយអង្គការសន្តិសេនា ។ | ប្រទេសកម្ពុជា |
| | ▪ បានចូលរួមប្រជុំ ស្តីពីកិច្ចសហប្រតិបត្តិការបទល្មើសនៅជាប់ព្រំដែន ក្នុងនោះពាក់ព័ន្ធទៅនឹងបទល្មើសជួញដូរមនុស្សឆ្លងដែន ជាមួយភាគីវៀតណាម ចំនួន០១លើកនៅក្នុងខេត្តឡុងអាន អ្នកចូលរួមចំនួន២៥នាក់ ស្រី០១នាក់។ | ប្រទេសវៀតណាម |
| | ▪ ចូលរួមកិច្ចប្រជុំ ស្តីពីកិច្ចត្រួតពិនិត្យវាយតម្លៃការអនុវត្តកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងសមាគមន៍កម្ពុជាដើម្បីសន្តិភាពក្នុងការអភិវឌ្ឍន៍ ដំណាក់កាលឆ្នាំ២០១៤-២០១៦ ខេត្តស្វាយរៀង ខេត្តព្រៃវែង និងខេត្តកំពង់ចាម ជាមួយសមាគមន៍នារីខេត្តតៃនិញ ចំនួន០១លើកនៅខេត្តតៃនិញ មានអ្នក ចូលរួមចំនួន១១៧នាក់ជាស្ត្រី ។ | ប្រទេសវៀតណាម |
| **លេខាធិការដ្ឋាន ប.ជ.រ.ព.ភ ខេត្តកណ្តាល** | ▪ បានទៅប្រជុំបូកសរុបសម្មភាពជួញដូរស្ត្រី និងកុមារនៅសហាព័ន្ធនារីខេត្តអានយ៉ាង ប្រទេសវៀតណាម និងខេត្តតាកែវ សមាគមន៍នារីខេត្តកណ្តាល ។ | ប្រទេសវៀតណាម |
| **លេខាធិការដ្ឋាន ប.ជ.រ.ព.ភ ខេត្តប៉ៃលិន** | ▪ បានសហការជាមួយភាគីថៃពិភាក្សាគ្នាដើម្បីត្រួតពិនិត្យប្រជាពលរដ្ឋប្រទេសទាំងពីរ ដែលឆ្លងព្រំដែនទៅវិញទៅមកប្រកបដោយសុវត្ថិភាព។ | ប្រទេសកម្ពុជា |
| **លេខាធិការដ្ឋាន ប.ជ.រ.ព.ភ ខេត្តស្ទឹងត្រែង** | ▪ បានចូលរួមប្រជុំ កិច្ចសហប្រតិបត្តិការអន្តរជាតិ ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្លងដែន នៅខេត្ត ប៊ិញភៀក ប្រទេសវៀតណាម ។ | ប្រទេសវៀតណាម |
| **លេខាធិការដ្ឋាន ប.ជ.រ.ព.ភ ខេត្តមណ្ឌលគិរី** | ▪ បានចាត់ស្នងការរង ឲ្យទៅចូលរួមកិច្ចប្រជុំការអនុវត្តកិច្ចព្រមព្រៀងសហ ប្រតិបត្តិការ ជាមួយភាគីវៀតណាម នៅខេត្តបូនម៉ាធួត រយៈពេល០២ថ្ងៃ ។ | ប្រទេសវៀតណាម |

## ៦- ការងារពាក់ព័ន្ធនឹងកុមារ

ក្នុងឆ្នាំ២០១៤ ការអនុវត្តន៍ឆ្លើយតបទៅនឹងកិច្ចការពារកុមារ មានលេខាធិការដ្ឋាន ប.ជ.រ.ព.ភ ខេត្ត ចំនួន០៨ ដូចមានសកម្មភាពដូចខាងក្រោម ៖

- **ខេត្តព្រះសីហនុ**

ផ្នែកការពារសុវត្ថិភាពកុមារ**អង្គការម្លប់តាប៉ាង** បានដាក់បណ្ដាញសុវត្ថិភាពកុមារ និងបណ្ដាញ ម៉ូតូឌុប និងក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ បណ្ដាញតាមសហគមន៍ ភ្នាក់ងារទេសចរណ៍ សរុបចំនួន ១១៧នាក់ ក្នុងការការពារកុមារពីការរំលោភបំពានផ្សេងៗ ។

- **ខេត្តក្រចេះ**

- ការិយាល័យសុខមាលភាពកុមារ បានចុះត្រួតពិនិត្យក្នុងមណ្ឌល**អង្គការដំណឹងល្អ**ទាំង៤ លើការថែទាំជំនួសចំពោះកុមារក្នុងខេត្តមានចំនួន៣៥នាក់ កុមារី១៦នាក់។

- មន្ទីរបានសហការជាមួយអង្គការភូមិកុមារកម្ពុជា SOS ប្រចាំខេត្តក្រចេះ ជួយដល់កុមារកំព្រា រងគ្រោះ រស់នៅ និងសិក្សា សរុបចំនួន ៩៤នាក់ ស្ត្រី ៤០នាក់ ។

- **ខេត្តកណ្ដាល**

មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា បានចាត់ឲ្យមន្ត្រីបង្គោលចុះត្រួតពិនិត្យមើលការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្ដីពីការថែទាំជំនួសចំពោះកុមារថែទាំកុមារកំព្រា និងកុមាររងគ្រោះមាន៖

- នៅមណ្ឌលកុមារកំព្រាមូលនិធិហ្សានីហ្វលីបេប៊ី ចំនួន៤២នាក់(ស្រី១៥)
- មណ្ឌលកុមារកំព្រាភូមិអេម៉ាញ៉ូអែល ស្ថិតនៅភូមិទួលព្រិច ឃុំទួលព្រិច ស្រុកអង្គស្នួល ខេត្តកណ្ដាលចំនួន១០៩នាក់ (ស្រីចំនួន៥៤នាក់)
- នៅមណ្ឌលអង្គការផ្ទះនៃព្រះគុណ មើលពីការថែទាំកុមារកំព្រា សរុបចំនួន៥៧នាក់ (ស្រី៣០នាក់)
- នៅមណ្ឌលកុមារជីបូឌៀហ៊ាបនៅស្រុកខ្សាច់កណ្ដាល និង
- នៅមណ្ឌលកុមារកំព្រានៃសេចក្ដីសន្យាដំណឹងល្អ៩ ក្នុងស្រុកលើកដែក សរុបចំនួន៣១នាក់ (ស្រី១៥នាក់) និងនៅមណ្ឌលកុមារកំព្រានៃសេចក្ដីសន្យាដំណឹងល្អ៩ ក្នុងស្រុកលើកដែក ភូមិព្រែកតូច ឃុំព្រែកដាច់សរុបចំនួន១៤នាក់ (ស្រី០៦នាក់) ។

- **ខេត្តស្វាយរៀង**

**អង្គការមូលនិធិកុមារកម្ពុជា**បានសហការជាមួយគណៈកម្មការទ្រទ្រង់សាលាចុះតាមដាននិងជំរុញលើកទឹកចិត្តដល់កុមារដែលបោះបង់ការសិក្សាដោយមូលហេតុផ្សេងៗឲ្យបានចូលរៀនវិញ បានចំនួន៧០នាក់ (ស្រី២៣នាក់) នៅក្នុងឃុំគោលដៅ ស្រុកស្វាយជ្រំ និងបណ្ដុះបណ្ដាលពង្រឹងសមត្ថភាពមន្ត្រីការិយាល័យអប់រំស្រុកស្វាយជ្រំចំនួន០១លើក អ្នកចូលរួមចំនួន៣៨នាក់ ស្រី០៦នាក់ ស្ដីពីគោលនយោបាយសាលាកុមារមេត្រី ។

▪ **ខេត្តពោធិ៍សាត់**

ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន និងក្រុមការងារ បានចុះត្រួតពិនិត្យមើលការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីការថែទាំជំនួសចំពោះកុមារ កំព្រា និងកុមាររងគ្រោះ នៅតាមមណ្ឌលថែទាំកុមារចំនួន ០៧ ក្នុងនោះមានមណ្ឌលរដ្ឋ ០១កន្លែង និងមណ្ឌលអង្គការ០៦កន្លែង ពិនិត្យលើការគាំពារ និងថែទាំបណ្តុះបណ្តាលជនរងគ្រោះ និងងាយរងគ្រោះមានចំនួនសរុប ៣១២នាក់ ស្រីចំនួន ១៥០នាក់ ។

▪ **ខេត្តកំពង់ចាម**

សហការក្នុងការចុះស្វែងរកគ្រួសារកុមារចំនួន០៣គ្រួសារ និងការជួយការពារកុមាររងគ្រោះដោយអំពើជួញដូរមនុស្ស ។

▪ **ខេត្តកំពង់ឆ្នាំង**

បានអន្តរាគមន៍ប្រគល់កុមារី ចំនួន០២នាក់ទៅឲ្យអង្គការមេត្រីអន្តរជាតិ (ភ្នំពេញ) តាមសំណូមពរឪពុក-ម្តាយ ។

▪ **ខេត្តប៉ៃលិន**

បានសហការជាមួយអង្គការប្រតិបត្តិកុមារកម្ពុជា ចុះសួរសុខទុក្ខ និងចែកអំណោយដល់កុមារ រស់នៅតាមសហគមន៍ចំនួន២០ ។

បានចុះធ្វើអធិការកិច្ចមណ្ឌលថែទាំកុមារ ចំនួន០៣ មាន ៖ មណ្ឌលសង្គ្រោះជនអស់សង្ឃឹម មណ្ឌលដំណឹងល្អទាំង៤ និងមណ្ឌលកុមារកំព្រា ក្នុងការថែទាំជំនួសឲ្យស្របតាមបទដ្ឋានអប្បបរមា។

▪ **ខេត្តស្ទឹងត្រែង**

បានចុះត្រួតពិនិត្យ និងស្រង់ទិន្នន័យ មណ្ឌលថែទាំជំនួស នៅមណ្ឌលដំណឹងល្អទាំងបួន មណ្ឌលអភិវឌ្ឍន៍កុមារ ក្នុងការថែទាំកុមាររងគ្រោះ សរុប២១នាក់ (ស្ត្រី០៥ កុមារ១៦នាក់ កុមារី០៨នាក់) ។

**៧- ការងារទេសន្តរប្រវេសន៍:**

ដោយហេតុថា ចំណាកស្រុករបស់ប្រជាពលរដ្ឋ ជាពិសេស ពលករដែលធ្វើទេសន្តរប្រវេសន៍ឆ្លងដែនដោយប្រថុយប្រថាន បានបង្កឲ្យមានភាពរងគ្រោះជាច្រើន រាប់ទាំងការរំលោភបំពាន ការកេងប្រវ័ញ្ច ការជួញដូរមនុស្ស ជួញដូរពលកម្ម និងជួញដូរផ្លូវភេទផងនោះ រាជរដ្ឋាភិបាល បានចាត់ទុកបញ្ហាទេសន្តរប្រវេសន៍ជាបញ្ហាចម្បងមួយ ដែលមានការទំនាក់ទំនងជិតស្និទ្ធជា មួយអំពើជួញដូរមនុស្ស ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានជម្រុញអនុវត្តប្រកាសទាំង០៨ ដើម្បីឆ្លើយតបទៅនឹងអនុក្រឹត្យ ១៩០ អនក្រ.បក ស្តីពី គ្រប់គ្រងលើ ការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន ។

គណៈកម្មាធិការជាតិ បានប្រកាសគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលលេខ ០១ គកន ស្តីពីការគ្រប់គ្រងកម្លាំងពលកម្ម និងលំហូរទេសន្តរប្រវេសន៍កម្ពុជា ជម្រុញលើការងារទទួលខុសត្រូវរបស់ស្ថាប័នពាក់ព័ន្ធ ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំសេចក្តីព្រាងអនុស្សរណៈ នៃការយោគយល់គ្នារវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសម៉ាឡេស៊ី ស្តីពីការបញ្ជូនពលករស្របច្បាប់ទៅធ្វើការងារនៅម៉ាឡេស៊ី ។

បន្ទាប់ពីការកែសម្រួលរចនាសម្ព័ន្ធគណៈកម្មាធិការជាតិ លោកជំទាវ **ជូ ប៊ុនអេង អនុប្រធាន អចិន្ត្រៃយ៍ គ.ជ.ប.ជ** បានដឹកនាំពិភាក្សាក្នុងក្រុមការងារបច្ចេកទេស និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីធ្វើការសិក្សាស្រាវជ្រាវភាពប្រឈមនានាទាក់ទងទៅនឹងបញ្ហាទេសន្តរប្រវេសន៍ការងារ ។

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានរៀបចំវគ្គសិក្ខាសាលា ស្តីពីការបណ្តុះបណ្តាលទីភ្នាក់ងារក្រុមហ៊ុនជ្រើសរើសពលករ ក្នុងគោលបំណងពង្រឹងសមត្ថភាពយល់ដឹងដល់ក្រុមហ៊ុន អំពីច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស វិធានការពាក់ព័ន្ធ និងករណីពាក់ព័ន្ធនឹងការជ្រើសរើសពលករ ការបញ្ជូន និងការដាក់ពលករឲ្យធ្វើការងារ ដែលមិនមានការទទួលខុសត្រូវ ក្នុងគោលបំណងបង្ការការអនុវត្តន៍ខុសឆ្គងដែលនាំឲ្យកើតឡើងនូវអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្សេងៗ លើពលករ និងដើម្បីការពារសុវត្ថិភាពជូនពលករទេសន្តរប្រវេសន៍ ដែលស្វែងរកការងារធ្វើនៅក្រៅប្រទេសតាមរយៈក្រុមហ៊ុន ។

អគ្គស្នងការដ្ឋាននគរបាលជាតិ បានជំរុញឲ្យគ្រប់ស្នងការដ្ឋានរាជធានី-ខេត្ត តាមដានបច្ចុប្បន្នស្ថិតិប្រជាពលរដ្ឋ ដែលធ្វើចំណាកស្រុកស្វែងរកការងារ ដែលជាលំហូរចេញចូលមិនប្រក្រតី មិនមានការគ្រប់គ្រងច្បាស់លាស់ និងមានការប្រែប្រួលជារៀងរាល់ខែ ។

<u>**សម្គាល់៖**</u>

ទិន្នន័យនេះ គឺជាការធ្វើកំណត់ត្រាតាមដានស្ថិតិលំហូរចេញរបស់ប្រជាពលរដ្ឋដែលចាកចេញ ពីលំនៅដ្ឋានរបស់ខ្លួន ដើម្បីស្វែងរកការងារធ្វើ ទាំងនៅក្នុងប្រទេស ទាំងទៅក្រៅប្រទេស ប្រចាំខែ តែមិនបានញែកជាចំនួនតាមប្រភេទឲ្យបានជាក់លាក់ទេ ។

❖ តារាងតាមដានបច្ចុប្បន្នភាពចំណាកស្រុករបស់ពលរដ្ឋតាមខែនីមួយៗ ក្នុងឆ្នាំ២០១៤ (ក្នុង និងក្រៅប្រទេស)

| ល.រ | គិតក្នុងខែ | ចំនួនពលរដ្ឋចំណាកស្រុក ប្រែប្រួលតាមខែនីមួយៗ | | ចំនួនកុមារ | | កំណត់សំគាល់ |
|---|---|---|---|---|---|---|
| | | ចំនួនរួម | ស្រី | សរុបអនីតិជន | អនីតិជនជាកុមារី | |
| ១ | មករា | ៣៣០,០៣២ | ១៣៧,៣២៧ | 0 | 0 | កើនឡើង |
| ២ | កុម្ភៈ | ៣៤៤,៦៤៣ | ១៤៤,៥១២ | ១២,៤៨៤ | ៤,៩០៩ | កើនឡើង |
| ៣ | មីនា | ៣៥៩,៦៥៣ | ១៤៨,៤៥៩ | 0 | 0 | កើនឡើង |
| ៤ | មេសា | ៣៧៣,៦១៦ | ១៥៤,៦០០ | ១២,៩៤៨ | ៥,០២៥ | កើនឡើង |
| ៥ | ឧសភា | ៤០៧,៤៨៩ | ១៣,៨៧១ | ១៣,៨៧១ | ៥,៣៥០ | កើនឡើង |
| ៦ | មិថុនា | មិនមាន រ.ប.ក | មិនមាន រ.ប.ក | មិនមានរ.ប.ក | មិនមានរ.ប.ក | ក្នុងស្ថានភាពថៃចាប់បញ្ជូនពលករមកវិញយ៉ាងគំហុក |
| ៧ | កក្កដា | ២០៧,៥៨៧ | ៨៧,២៤៦ | ៧,៥៥៩ | ២,៩៥១ | ថយចុះ |
| ៨ | សីហា | ២២៨,៣៧៩ | ៩៤,៦៦៦ | ៧,៩២៣ | ១,៣៩៨ | កើនឡើង |
| ៩ | កញ្ញា | ២៤៣,៨៩១ | ១០២,០០៤ | ៨,៧៧២ | ៣,៣១៧ | កើនឡើង |
| ១០ | តុលា | ២៥២,៧៦៥ | ១០៥,៨១៩ | ៩,០២១ | ៣,៣៥៧ | កើនឡើង |
| ១១ | វិច្ឆិកា | ២៤១,៣៧៥ | ១០១,៦៤៥ | ៨,៨៤៧ | ៣,៣០៦ | ថយចុះ |
| ១២ | ធ្នូ | ២៦៨,៧៣២ | ១១៣,៦៩១ | ៩,០៥៨ | ៣,៣៩១ | កើនឡើង |



## គ- ការងារដឹកនាំ និងសម្របសម្រួលកិច្ចសហការ

ការងារដឹកនាំ សម្របសម្រួល និងពង្រឹងកិច្ចសហការក្នុងឆ្នាំ២០១៤កន្លងទៅនេះ សរុបមានចំនួន **៤០៦**លើក ដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ចំនួន**០៦**លើក ដោយអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ចំនួន**១២៤**លើក ក្រុមការងារអនុវត្តន៍ច្បាប់ចំនួន**០១**លើក ក្រសួងទេសចរណ៍ចំនួន**០១**លើក ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ចំនួន**១១**លើក ក្រសួងកិច្ចការនារី ចំនួន**១០**លើក (ក្រុមការងារខមមីតចំនួន**០៧**លើក) ក្រសួងយុត្តិធម៌ចំនួន**០១**លើក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន**១៣**លើក និងលេខាធិការដ្ឋានខេត្ត ចំនួន**២៣៩**លើក ប្រៀបធៀបទៅនឹងឆ្នាំ២០១៣ គឺកិច្ចប្រជុំសម្របសម្រួលកើន ចំនួន១៥៧លើក ។

ការសម្របសម្រួល សំខាន់គឺជាការរៀបចំកិច្ចប្រជុំ ពិគ្រោះយោបល់ ជំនួបជាមួយគណៈប្រតិភូជាតិ និងអន្តរជាតិ ការសិក្សាស្វែងយល់អំពីការងារដឹកនាំ រចនាសម្ព័ន្ធការងារ ផ្លាស់ប្តូរ ដកពិសោធន៍ការងារបច្ចេកទេស ការរៀបរៀងឯកសារជាបទដ្ឋានគតិយុត្តិ របាយការណ៍ ផែនការ ការពិនិត្យកែសម្រួលឯកសារពង្រឹងរបៀបរបបការងារ រៀបចំខ្លឹមសារបណ្តុះបណ្តាល ក្នុងការទប់ស្កាត់រាល់ទម្រង់នៃការរំលោភបំពានផ្លូវភេទ ទេសចរណ៍ផ្លូវភេទលើកុមារ ការជួញដូរមនុស្ស កិច្ចអន្តរាគមន៍ ការការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ពង្រឹងការគ្រប់គ្រងលំហូរពលករទេសន្តរប្រវេសន៍ និងការផ្តន្ទាទោសជនល្មើស.... ។ល។

លើសពីនេះទៅទៀត ក្នុងឆ្នាំ២០១៤ កន្លងទៅនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានបង្កើននូវកិច្ចខិតខំប្រឹងប្រែង ជំរុញសកម្មភាពការងារ ទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដោយផ្អែកលើយុទ្ធសាស្ត្រផែនការ និងទិសដៅសកម្មភាពជាតិ ដោយសម្រេចបានលទ្ធផលល្អប្រសើរ នៅក្នុងនោះមាន ៖

សន្និបាតបូកសរុប ដកពិសោធន៍លទ្ធផលការងារ ប.ជ.រ.ព.ភ ប្រចាំឆ្នាំ២០១៣ និងទិសដៅសម្រាប់អនុវត្តឆ្នាំ២០១៤ ។

រៀបចំព្រះរាជក្រឹត្យ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ដើម្បីកែទម្រង់រចនាសម្ព័ន្ធសមាសភាព និងតួនាទី ភារកិច្ច គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងបទដ្ឋានពាក់ព័ន្ធនានា សម្រាប់ការងារដឹកនាំ ត្រួតពិនិត្យវាយតម្លៃ នៅគ្រប់កម្រិត ។

**ក្រៅពីនេះ គណៈកម្មាធិការជាតិ ដែលមានលេខាធិការដ្ឋានជាសេនាធិការ និងក្រសួង ស្ថាប័នជំនាញជាប្រតិបត្តិករ បានធ្វើសិក្ខាសាលាថ្នាក់ជាតិ និងកិច្ចប្រជុំពិគ្រោះយោបល់ជាច្រើនលើករវាងក្រសួង ស្ថាប័ន ដៃគូពាក់ព័ន្ធ ដើម្បីរៀបចំយុទ្ធសាស្ត្រ និងផែនការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ៖**

- បានពិគ្រោះយោបល់ និងដកពិសោធន៍រវាងស្ថាប័នអនុវត្តន៍ច្បាប់ និងតុលាការ លើការងារឆ្លើយតបទៅនឹងការអនុវត្តច្បាប់ពាក់ព័ន្ធអំពើជួញដូរមនុស្ស ។
- បានព្រាងឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត បទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។
- បានពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងកិច្ចសន្យាការងារ រវាងនិយោជក និងពលករទៅបម្រើការងារតាមផ្ទះនៅក្រៅប្រទេស ដើម្បីធានាបាននូវសុវត្ថិភាពពលករ ។
- បានដាក់ឲ្យប្រើប្រាស់សម្ភារផ្សព្វផ្សាយ បង្ការ សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ។

- បានពិភាក្សា ពិនិត្យលើការអនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃលើសេវាមូលដ្ឋានជួយដល់កុមាររងគ្រោះ។

- បានចុះអនុស្សរណៈយោគយល់គ្នាលើកិច្ចសហការជាមួយអង្គការដៃគូ ។

-បានស្វាគមន៍ និងជួយឧបត្ថម្ភដល់ពលករទេសន្តរប្រវេសន៍ការងារ ដែលអាជ្ញាធរថៃចាប់បញ្ជូនមកវិញដោយគំហុក ។

- បានសហការជាមួយស្ថាប័នជំនាញ និងអង្គការដៃគូពង្រឹងកិច្ចសហប្រតិបត្តិការរួមគ្នាក្នុងការប្រយុទ្ធប្រឆាំងទៅនឹងអំពើជួញដូរមនុស្ស និងពិភាក្សាពិគ្រោះយោបល់គ្នាពិនិត្យអំពីក្របខណ្ឌច្បាប់ពាក់ព័ន្ធនីតិវិធីស្រាវជ្រាវស៊ើបអង្កេតដោយសម្ងាត់ ។

- បានសហការជាមួយអង្គការដៃគូផលិតបានសម្ភារៈឧបករណ៍ផ្សព្វផ្សាយ ជាច្រើនប្រភេទ មាន sticker, Tent Cared, Signboardនិងខ្សែ Video ខ្លីស្ដីពីការចូលរួមជួយដល់កុមារក្នុងការរំលោភបំពានផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍និងទម្រង់ នៃការកេងប្រវ័ញ្ចផ្សេងទៀតទៅលើកុមារ និងបង្ក្រាបបទល្មើស ដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងបង្ការ-ទប់ស្កាត់ជាមុនចំពោះពលករចំណាកស្រុកដែលមានបំណងឆ្លងដែនស្វែងរកការងារធ្វើនៅប្រទេសជិតខាងដើម្បីជាក់ និងផ្សព្វផ្សាយតាមគោលដៅរាជធានី-ខេត្ត ទាំង២៥។

ខាងក្រោមនេះ ជាតារាងការងារដឹកនាំ និងសម្របសម្រួលកិច្ចសហការ ជាមួយ ក្រសួង មន្ទីរ អង្គភាព ស្ថាប័នពាក់ព័ន្ធ និងដៃគូនានា របស់គណៈកម្មាធិការជាតិ និងរាជធានី ខេត្ត ៖

| **ស្ថាប័ន សម្របសម្រួល** | **ចំនួនសកម្មភាព** | **ស្ថាប័នចូលរួម និងអ្នកពាក់ព័ន្ធ** |
|---|---|---|
| គណៈកម្មាធិការជាតិ | សម្របសម្រួលកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញ ចំនួន០៦លើក | សមាជិក គ.ជ.ប.ជ |
| អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន១២៤លើក | សមាជិកលេខាធិការដ្ឋាន ក្រុមការងារ និងអង្គការដៃគូ |
| ក្រុមការងារអនុវត្តច្បាប់ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន០១លើក | សមាជិក ក្រុមការងារ និងអង្គការដៃគូ |
| ក្រសួងទេសចរណ៍ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន០១លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ក្រសួង ស.អ.យ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន១១លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ក្រសួងកិច្ចការនារី | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន១០លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ក្រសួងយុត្តិធម៌ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន០១លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន១៣លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |

| | | |
|---|---|---|
| ខេត្តកណ្តាល | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន១៣លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តស្វាយរៀង | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន២៨លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តសៀមរាប | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន០៨លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តកំពង់ឆ្នាំង | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន ០២លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តព្រះវិហារ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន ០២លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តព្រះសីហនុ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន១១លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តក្រចេះ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន ០២លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តស្ទឹងត្រែង | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន០១លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តកំពង់ស្ពឺ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន ០២លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តបាត់ដំបង | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន ៦៥លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តកំពង់ធំ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន១៥លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តតាកែវ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន ០១លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តបន្ទាយមានជ័យ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន១១លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តកំពត | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន០៥លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តកែប | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន ០១លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តព្រៃវែង | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន៣៤លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តកោះកុង | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន ០៤លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តពោធិសាត់ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន០២លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តកំពង់ចាម | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន១៣លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តឧត្តរមានជ័យ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន១៣លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តរតនៈគិរី | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន០៤លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តប៉ៃលិន | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន០២លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តត្បូងឃ្មុំ | (ខេត្តកើតថ្មី) | (ខេត្តកើតថ្មី មិនទាន់មានសកម្មភាព) |
| **សរុប** | **ប្រជុំសម្របសម្រួលលើការងារចំនួន៤០៦លើក** | |

## ឃ- ការលើកកម្ពស់សមត្ថភាព

### ១. ការបណ្តុះបណ្តាល

នៅក្នុងឆ្នាំ២០១៤កន្លងទៅនេះ ដោយមានកិច្ចសហការជាមួយអង្គការដៃគូជាតិ និងអន្តរជាតិ មានជាអាថិ៍៖ អង្គការ Cambodia ACTs, IOM, Winrock, World Vision, GVC, APLE, IJM, RAW IMPACT, CPU, AIM SWAT កម្ពុជាត្រាស្ត សូម៉ាលីម៉ម សមាគមន៍នារីដើម្បីសន្តិភាព និងអភិវឌ្ឍន៍ជាដើមនោះ អគ្គលេខាធិការដ្ឋាន ក៏ដូចជាលេខាធិការដ្ឋានរាជធានី-ខេត្ត បានធ្វើការបណ្តុះបណ្តាលសរុបបានចំនួន ១៣៣វគ្គ ដល់សិក្ខាកាមជាក្រុមប្រឹក្សាឃុំ មន្ត្រីថ្នាក់មូលដ្ឋាន មន្ត្រីលេខាធិការដ្ឋានខេត្ត ជនបង្គោល គ្រូបង្គោលណែនាំតម្រង់ទិសមុនពេលចេញដំណើរ មន្ត្រីអនុវត្តច្បាប់ លោកគ្រូ អ្នកគ្រូ និងបុគ្គលិកអង្គការ និង

ប្រតិបត្តិករទេសចរណ៍ នៅតាម សណ្ឋាគារ សរុបបានចំនួន**៥,១៣២**នាក់ (ស្រី**២,១៧៧**នាក់) ។ វគ្គបណ្តុះបណ្តាលបានផ្តោតជាសំខាន់ទៅលើចំណេះដឹងអំពីច្បាប់ស្តីពីការបង្ក្រាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បទដ្ឋានអប្បបរិមាស្តីពីសិទ្ធិការពារជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ចំណាកស្រុកដោយសុវត្ថិភាព ការទប់ស្កាត់អំពើជួញដូរមនុស្ស ការអភិវឌ្ឍន៍ស្ត្រី ការស៊ុំកូនអន្តរប្រទេស ការពង្រឹងកិច្ចការពារកុមារ សិទ្ធិកុមារ ការបង្ការ ការរំលោភបំពានផ្សេងៗលើស្ត្រី និងកុមារ ជំនាញអន្តរាគមន៍ជួយដល់ជនរងគ្រោះ និងបច្ចេកទេសស្តាប់ចម្លើយអនីតិជនរងគ្រោះ ក្នុងនោះមានដូចតារាងខាងក្រោម៖

❖ **<u>តារាងវគ្គបណ្តុះបណ្តាល</u>**

| ស្ថាប័នអនុវត្ត | ចំនួនវគ្គ | ចំនួនសិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | ០៤ | ១១៨ | ០៦ |
| ក្រសួងកិច្ចការនារី | ១០ | ៤៥៦ | ២៤៩ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ០៤ | ១៤៤ | ៦៧ |
| ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០១ | ៤៧ | ០៦ |
| នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស | ១៣ | ៣២៦ | ០៦ |
| កងរាជអាវុធហត្ថលើផ្ទៃប្រទេស | ០២ | ៦៣ | ១៣ |
| លេខាធិការដ្ឋានប.ជ.រ.ព.ភខេត្តសៀមរាប | ០៣ | ១១៩ | ៥២ |
| ខេត្តកំពង់ឆ្នាំង | ៣៤ | ១,២៧៤ | ៨១២ |
| ខេត្តព្រះវិហារ | ២១ | ៥៣៤ | ១០០ |
| ខេត្តកំពង់ស្ពឺ | ០៤ | ១៧៦ | ៤៨ |
| ខេត្តព្រៃវែង | ២០ | ៦៤០ | ១៩០ |
| ខេត្តស្វាយរៀង | ០៨ | ៥៧០ | ១៩៤ |
| ខេត្តព្រះសីហនុ | ០២ | ១៧៩ | ១១៧ |
| ខេត្តបាត់ដំបង | ០៤ | ១២៤ | ៤៥ |
| ខេត្តកំពង់ធំ | ០៣ | ២៧១ | ១៩៥ |
| ខេត្តកណ្តាល | ០១ | ៨១ | ៣៣ |
| ខេត្តកំពង់ចាម | ០២ | ១៩០ | ៧៤ |
| **សរុប** | **១៣៣** | **៥,១៣២** | **២,១៧៧** |

## ២. សិក្ខាសាលា

ក្នុងឆ្នាំ២០១៤កន្លងទៅនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ និងលេខាធិការដ្ឋាន ប.ជ.រ.ព ភ.រាជធានី-ខេត្ត បានសហការជាមួយអង្គការដៃគូជាតិ និងអន្តរជាតិ ធ្វើសិក្ខាសាលាផ្តោតទៅលើ ប្រធានបទសំខាន់ៗ ដែលជាកិច្ចការអាទិភាពទាក់ទងទៅនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សមាន៖

- ពិគ្រោះយោបល់ក្នុងការរៀបចំផែនការសកម្មភាពជាតិ ជំហាន២ (ឆ្នាំ២០១៤-២០១៨) ។
- បញ្ហាជួញដូរមនុស្សក្នុងវិស័យនេសាទសមុទ្រ ។
- បញ្ហាយេនឌ័រនៅក្នុងលំហូរទេសន្តរប្រវេសន៍ និងការជួញដូរមនុស្ស ។
- សុវត្ថិភាពកុមារនៅក្នុងវិស័យទេសចរណ៍ ។
- ពង្រឹងប្រសិទ្ធិភាពការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។
- ច្បាប់ពាក់ព័ន្ធការបង្ក្រាបអំពើជួញដូរមនុស្ស ។
- ការបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស ដល់ទីភ្នាក់ងារ ក្រុមហ៊ុនជ្រើសរើសពលករ ។
- បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរ ។
- ការកេងប្រវ័ញ្ចពលកម្មកុមារ ។

សិក្ខាសាលាសរុបបានចំនួន២៨វគ្គ សរុបមនុស្សបានចំនួន១,៧៨៦នាក់ (ស្រី៥២៥នាក់) ក្នុងនោះមានសកម្មភាពដូចខាងក្រោម ៖

❖ <u>តារាងវគ្គសិក្ខាសាលា</u>

| ស្ថាប័នអនុវត្ត | ចំនួនវគ្គ | ចំនួនសិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | ០៥ | ៤២៩ | ១២២ |
| ក្រសួងទេសចរណ៍ | ០៧ | ៣៥២ | ៩១ |
| ក្រសួងកិច្ចការនារី | ០១ | ១១០ | ១០២ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ០២ | ២៤៧ | ៤៣ |
| អគ្គស្នងការដ្ឋាននគរបាលជាតិ | ០១ | ៩៨ | |
| លេខាធិការដ្ឋាន ប.ជ.រ.ព.ភ ខេត្តបាត់ដំបង | ០១ | ៥១ | ២១ |
| ខេត្តកណ្តាល | ០១ | ៨១ | ៣៣ |
| ខេត្តព្រះសីហនុ | ០១ | ៤៥ | ៣២ |
| ខេត្តសៀមរាប | ១០ | ៣៥៦ | ១៣៤ |
| ខេត្តពោធិសាត់ | ០១ | ៤៩ | ៤៩ |
| ខេត្តស្វាយរៀង | ០១ | ៨៧ | ០ |
| **សរុប** | **២៨** | **១,៧៨៦** | **៥២៥** |

## III. ការសន្និដ្ឋាន និងវាយតម្លៃ

### ក. ចំណុចខ្លាំង

ឆ្នាំ២០១៤ ក៏ដូចជាក្នុងបណ្តាឆ្នាំនានាដែរ លទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងអាចសម្រេចបានដូចបានរៀបរាប់ខាងលើនេះ អាស្រ័យដោយ ៖

- មានអនុសញ្ញា និងពិធីសារអន្តរជាតិ និងច្បាប់ជាតិ សម្រាប់ជាបង្អែក
- មានការប្តេជ្ញាចិត្តខ្ពស់ និងការតម្រង់ទិសជាប្រចាំពីថ្នាក់ដឹកនាំកំពូលរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងគោលបំណងកាត់បន្ថយផលប៉ះពាល់ធ្ងន់ធ្ងរដល់កម្លាំងស្នូលរបស់ជាតិក្នុងការអភិវឌ្ឍន៍គ្រប់វិស័យ ដើម្បីការពារកិត្តិយស សេចក្តីថ្លៃថ្នូរ និងបន្ទុកដោះស្រាយរបស់ប្រជាពលរដ្ឋ និងប្រទេសជាតិ ។
- មានផែនការសកម្មភាពជាតិ និងយុទ្ធសាស្រ្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាផែនទីបង្ហាញផ្លូវ
- ឆ្នាំ ២០១៤ ជាតំណាក់កាលនៃការកសាងមូលដ្ឋានគ្រឹះ សម្រាប់ការងារជាយុទ្ធសាស្រ្តគឺការពង្រឹងនូវយន្តការអនុវត្ត ដែលមានរចនាសម្ព័ន្ធទូលំទូលាយតាំងពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ ប្រកបដោយសក្តានុពល និងពង្រីកឱកាសចូលរួម គាំទ្រ សហការ ពីដៃគូជាតិ និងអន្តរជាតិ និងការបន្តកសាងផែនការសកម្មភាពជាតិ ដែលមានយុទ្ធសាស្រ្តជាក់លាក់ សម្រាប់រយៈពេលប្រាំឆ្នាំ ធ្វើជាត្រីវិស័យ និងជាផែនទីបង្ហាញផ្លូវ
- មានការឯកភាពជាតិ ក្នុងការរួមសហប្រតិបត្តិការ និងការប្តេជ្ញាចិត្តខ្ពស់ ខិតខំប្រឹងប្រែង ជំនះឧបសគ្គនិងការលំបាកទាំងឡាយដើម្បីដោះស្រាយបញ្ហាប្រឈមពីមន្រ្តីអនុវត្តច្បាប់គ្រប់ថ្នាក់ ។
- មានការចូលរួមគាំទ្រ សហការ និងអនុវត្ត ពីបណ្តាដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ អង្គការសង្គមស៊ីវិល នានាយ៉ាងសកម្ម រហូតទទួលបាននូវលទ្ធផលគួរឲ្យមោទនៈ ។

### ខ. ចំណុចសេសសល់ និងភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែងនិងចំណុចខ្លាំងខាងលើ យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងភាពខ្វះចន្លោះក្នុងក្របខណ្ឌនៃការអនុវត្តដែលត្រូវបំពេញបន្ថែម រួមមាន៖

- ការរៀបចំសមាសភាព និងរចនាសម្ព័ន្ធ និងរបៀបរបបការងារ ក្នុងគណៈកម្មាធិការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទើបបង្កើតថ្មី ដែលត្រូវការចាំបាច់ក្នុងការពង្រឹងសមត្ថភាព
- ក្រសួងស្ថាប័នពាក់ព័ន្ធមិនទាន់បានអនុវត្តព្រមគ្នា នូវគោលការណ៍ណែនាំលេខ ០១ គកន ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០១៣ ស្តីពីការគ្រប់គ្រងកម្លាំងពលកម្ម និងលំហូរពលករទេសន្តរប្រវេសន៍កម្ពុជា
- ទំនាស់ផលប្រយោជន៍រវាងប្រទេសបញ្ជូន និងប្រទេសទទួលនៅតែជាកង្វល់សម្រាប់កិច្ចការពារពលករទេសន្តរប្រវេសន៍
- កិច្ចសហប្រតិបត្តិការអន្តរជាតិ និងជំនួយផ្នែកច្បាប់ឱ្យគ្នាទៅវិញទៅមកលើរឿងក្តីជួញដូរមនុស្សឆ្លងដែន នៅមានកម្រិត

- នៅមិនទាន់ឆ្លើយតបឱ្យបានល្អអំពីកិច្ចសហប្រតិបត្តិការក្រៅផ្លូវការរវាងទ្វេភាគី ពហុភាគី និងតំបន់ដើម្បីដោះស្រាយឱ្យបានឆាប់រហ័សលើរឿងក្តីជួញដូរមនុស្សនៅឡើយ
- យុទ្ធសាស្ត្រទាំងបួន ត្រូវការជម្រុញអនុវត្ត ឲ្យបានព្រមៗគ្នា ដែលកន្លងមកមិនទាន់ទទួលបានលទ្ធផលគួរជាទីពេញចិត្តនៅឡើយ ក្នុងនោះមានជាអាទិ៍ៈ ការងារបង្ការទប់ស្កាត់ទេសន្តរប្រវេសន៍ខុសច្បាប់ ការទប់ស្កាត់និងបង្ក្រាបជនល្មើស ដែលអូសទាញ កេងប្រវ័ញ្ច ជួញដូរជនរងគ្រោះ និងដាក់ទោសទណ្ឌ កិច្ចសហការរវាងក្រសួងស្ថាប័នជំនាញ ដែលមិនទាន់ល្អប្រសើរ ដែលជាហេតុឲ្យដំណោះស្រាយមិនទាន់មានប្រសិទ្ធភាពខ្ពស់ ការជួយជនរងគ្រោះ នៅមានកម្រិត ប្រជាពលរដ្ឋនៅតែមានជំនឿលើមេខ្យល់ និងនៅតែប្រថុយប្រថាន នឹងគ្រោះថ្នាក់
- កិច្ចសហការជាមួយប្រទេសពាក់ព័ន្ធនៅមានកម្រិត ជាពិសេស ក្នុងការរៀបចំ និងអនុវត្តកិច្ចព្រមព្រៀង ឬអនុស្សរណៈ
- ខ្វះការតាមដាន ត្រួតពិនិត្យ វាយតម្លៃ ទៀងទាត់ ។

ខាងលើនេះទាមទារឱ្យគ្រប់ក្រុមការងារថ្នាក់ជាតិ និង គណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភរាជធានី-ខេត្ត ពិនិត្យរាល់ភាពខ្វះចន្លោះរកចំណុចគន្លឹះរៀបចំជាយុទ្ធសាស្ត្រ និងមានវិធានការជំរុញជាក់ ស្តែងឱ្យស្របទៅនឹងផែនការសកម្មភាពជាតិ។

## IV. ទិសដៅសម្រាប់ ឆ្នាំ២០១៥

ផ្អែកលើការសន្និដ្ឋាន វាយតម្លៃខាងលើនេះ គណៈកម្មាធិការជាតិ បានកំណត់ទិសដៅ ដូចខាងក្រោម៖

១- ផ្សព្វផ្សាយព្រះរាជក្រឹត្យ ស្តីពីការបង្កើតគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងបទដ្ឋានគតិយុត្តិពាក់ព័ន្ធ។

២- ជម្រុញការរៀបចំ និងបង្កើត អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ដើម្បីឲ្យមានយន្តការការងារធ្វើជាសេនាធិការជូន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)។

៣- ជំរុញការរៀបចំ និងអនុវត្តផែនការសកម្មភាពជាតិ០៥ឆ្នាំជំហាន២ សម្រាប់ឆ្នាំ២០១៤-២០១៨ សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ទៅតាមយុទ្ធសាស្ត្រ និងសកម្មភាពគ្រោងទុក ។

៤- ជម្រុញការរៀបចំសកម្មភាពជាយុទ្ធសាស្ត្រ ដើម្បីអនុវត្តគោលការណ៍ណែនាំលេខ០០១ គកន ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាល ។

៥- បន្តរៀបចំក្រុមការងារថ្នាក់ជាតិ និងលេខាធិការដ្ឋានរាជធានី-ខេត្ត និងផែនការសកម្មភាពរបស់ខ្លួនសម្រាប់ឆ្នាំ២០១៤-២០១៥ និងបណ្តុះបណ្តាលពង្រឹងសមត្ថភាព មន្ត្រីទទួលបន្ទុកគ្រប់ថ្នាក់ ។

៦- បន្តជម្រុញការលើកកម្ពស់សមត្ថភាពដល់មន្ត្រីអនុវត្តច្បាប់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីរួមចំណែកក្នុងសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យកាន់តែប្រសើរ។

៧- បន្តពង្រឹងកិច្ចសហការល្អជាមួយបណ្តាអង្គការអន្តរជាតិ និងអង្គការដៃគូពាក់ព័ន្ធបន្តបើកវគ្គបណ្តុះបណ្តាលច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងច្បាប់ពាក់ព័ន្ធ និងជំនាញឯកទេសប្រឆាំងការជួញដូរមនុស្សដល់មន្ត្រីអនុវត្តន៍ច្បាប់ ស្ថាប័នពាក់ព័ន្ធ និងមន្ត្រីថ្នាក់មូលដ្ឋាន។

៨- ផ្សព្វផ្សាយដល់មន្ត្រីអនុវត្តច្បាប់ និងតុលាការអំពីនីតិវិធីក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងកិច្ចជំនួយផ្លូវច្បាប់ឱ្យគ្នាទៅវិញទៅមកលើរឿងក្តីជួញដូរមនុស្សឆ្លងដែន។

៩- បង្កើនសមត្ថភាពយល់ដឹង អំពីបច្ចេកទេសស៊ើបអង្កេតសម្ងាត់ដល់មន្ត្រីអនុវត្តច្បាប់ នគរបាល កងរាជអាវុធហត្ថ ព្រះរាជអាជ្ញា និងចៅក្រម ។

១០- បន្តយកចិត្តទុកដាក់ជម្រុញការផ្សព្វផ្សាយការបង្ការ-ទប់ស្កាត់ ដើម្បីលើកកម្ពស់ការយល់ដឹងជាសាកលអំពីបញ្ហាជួញដូរមនុស្ស និងបញ្ហាទេសន្តរប្រវេសន៍ការងារជាពិសេសចំពោះជនដែលងាយរងគ្រោះគ្រប់ប្រភេទ ទាំងបុរស ស្ត្រី យុវវ័យ និងកុមារ ។

១១- បន្តជម្រុញការគ្រប់គ្រង និងតាមដានត្រួតពិនិត្យទីភ្នាក់ងារជ្រើសរើសឯកជនឲ្យទទួលខុសត្រូវចំពោះសុវត្ថិភាពសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ពលករ។

១២- ខេត្តជាប់ព្រំដែនបន្តពង្រឹងសមត្ថកិច្ចការពារព្រំដែនដោយយកចិត្តទុកដាក់អំពីការរត់-ពន្ធមនុស្ស និងការជួញដូរមនុស្សឆ្លងកាត់ព្រំដែន ដោយសហប្រតិបត្តិការទ្វេភាគីមានវិធានការបង្ការបង្ក្រាបឲ្យត្រឹមត្រូវតាមច្បាប់។

១៣- លើកកម្ពស់ការអនុវត្តន៍គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពឲ្យបានល្អនៅថ្នាក់មូលដ្ឋានដោយពង្រឹងការងារបង្ការ-ទប់ស្កាត់ និងបង្ក្រាបបទល្មើសជួញដូរមនុស្សដែលអាចកើតមានក្រោមរូបភាពផ្សេងៗ។

១៤- ពង្រឹងកិច្ចសហប្រតិបត្តិការក្រៅផ្លូវការឱ្យមានប្រសិទ្ធភាពខ្ពស់ រវាងអង្គភាពឯកទេស ឬស្ថាប័នអនុវត្តច្បាប់ ដើម្បីដោះស្រាយរឿងក្តីជួញដូរមនុស្ស ឱ្យបានឆាប់រហ័សរវាងទ្វេភាគីពហុភាគី និង ប្រទេសក្នុងតំបន់។

១៥- បង្កើនកិច្ចសហប្រតិបត្តិការផ្លាស់ប្តូរព័ត៌មាន និងនីតិវិធីជំនួយច្បាប់ទៅវិញទៅមកក្នុង រឿងក្តីជួញដូរមនុស្ស រវាងប្រទេសក្នុងតំបន់ឈានការបង្ក្រាបបទឧក្រិដ្ឋឆ្លងដែន តាមរយៈអាជ្ញាធរកណ្តាលរបស់ជាតិ។

១៦- ពង្រឹងកិច្ចសហការជាមួយបណ្តាប្រទេសបញ្ជូនពលករ និងជាមួយប្រទេសទទួលពលករ ដើម្បីធ្វើឲ្យមានសុខដុមនីយកម្មក្នុងការការពារសិទ្ធិស្របច្បាប់របស់ពលករទេសន្តរប្រវេសន៍ ។

១៧- ពង្រឹងការតាមដានត្រួតពិនិត្យ វាយតម្លៃ និងការសិក្សាស្រាវជ្រាវ និងការចងក្រងទិន្នន័យ ដើម្បីជាមូលដ្ឋានក្នុងការឆ្លើយតបទៅនឹងការវិវត្តន៍ប្រែប្រួល នៃស្ថានភាពបទល្មើសជួញដូរមនុស្ស ។

រាជធានីភ្នំពេញ ថ្ងៃទី ៧០ ខែកុម្ភៈ ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ប្រធានគណៈកម្មាធិការជាតិ គ.ជ.ប.ជ**

**ស ខេង**

**កន្លែងទទួល៖**
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-សមាជិកគណៈកម្មាធិការជាតិ គ.ជ.ប.ជ
-សមាជិកក្រុមការងារ នៃគណៈកម្មាធិការជាតិ គ.ជ.ប.ជ
-គណៈកម្មាធិការដឹកនាំ និងលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ថ្នាក់រាជធានី-ខេត្ត
-អង្គការដៃគូអភិវឌ្ឍន៍
-ដើម្បីជូនជ្រាបជារបាយការណ៍
-ឯកសារ-កាលប្បវត្តិ

## តារាងការងារដឹកនាំ និងសម្របសម្រួលកិច្ចសហការ

| ស្ថាប័នសម្របសម្រួល | សកម្មភាព | ស្ថាប័ន និងបុគ្គលពាក់ព័ន្ធ |
|---|---|---|
| **គណៈកម្មាធិការជាតិ** សរុបចំនួន៦លើក | - សន្និបាតបូកសរុបសកម្មភាព និងលទ្ធផលការងារបង្ក្រាបទប់ស្កាត់និងបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ ២០១៣ និង ទិសដៅ ការងារសម្រាប់អនុវត្តឆ្នាំ ២០១៤ (ចំនួន០១លើក) ។<br>- ប្រជុំត្រីមាស និងប្រជុំវិសមញ្ញរបស់គណៈកម្មាធិការជាតិ ពិភាក្សាអំពីតម្រូវ ការក្នុងការកែលម្អ រចនាសម្ព័ន្ធ តួនាទីភារកិច្ច នៃយន្តការ ជាតិ ពិនិត្យ កែសម្រួលសេចក្ដីព្រាងព្រះរាជក្រឹត្យ អនុក្រឹត្យ និងសេចក្ដីសម្រេចនានា ផែនការសកម្មភាពជាតិ និង ពិភាក្សាលើរបាយការណ៍ ស្ដីពីកិច្ចខិតខំប្រឹងប្រែង របស់រាជរដ្ឋាភិបាលកម្ពុជា ឆ្លើយតបទៅនឹងចំណុចខ្វះ ចន្លោះ ក្នុងឆ្នាំ២០១៣ (ចំនួន០៥លើក) ។ | សមាជិក គណៈកម្មាធិការជាតិ គ.ជ.ប.ជ |
| **អគ្គលេខាធិការដ្ឋាន** ចំនួន ១២៤លើក | - ប្រជុំពិភាក្សាយោបល់ លើសេចក្ដីព្រាងព្រះរាជក្រឹត្យ និង អនុក្រឹត្យពាក់ព័ន្ធការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (ចំនួន០៩លើក) ។<br>- សម្របសម្រួល កិច្ចប្រជុំ ពិភាក្សាលើវិសាលភាពនៃ ក្របខណ្ឌយុទ្ធសាស្ត្រជាតិ ប្រមូលផ្ដុំ រៀបចំតាក់តែង (ចំនួន០៣លើក) ។<br>- ប្រជុំរៀបចំផែនការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ ២០១៤-២០១៨ (ចំនួន០៤លើក) ។<br>- ប្រជុំការងារបច្ចេទេសក្នុងការបង្ការ-ទប់ស្កាត់ និងការបង្ក្រាបអំពើជួញដូរមនុស្ស (ចំនួន០៥លើក) ។<br>- ប្រជុំពិនិត្យកែសម្រួល លើការងារ ប.ជរ.ព.ភ ដើម្បីដាក់ឆ្លងកិច្ចប្រជុំត្រីមាសទី៣នៃគណៈកម្មាធិការជាតិ (០២លើក) និងបានផ្ញើជូនក្រសួង ស្ថាប័ន អង្គភាព អង្គការពាក់ព័ន្ធ ដើម្បីកែលម្អទិន្នន័យបន្ថែម និងដាក់ជូនឯកឧត្តមប្រធាន គណៈកម្មាធិការជាតិពិនិត្យសម្រេច (ចំនួន០២លើក)។ | -ក្រសួង ស្ថាប័ន<br>-ក្រុមការងារលេខាធិការដ្ឋាន គ.ជ.ប.ជ<br>-អង្គការដៃគូ<br>-ក្រុមការងារបច្ចេកទេស<br><br>-ក្រសួង ស្ថាប័ន រាជធានី-ខេត្ត និងអង្គការដៃគូ<br>-ក្រសួង ស្ថាប័ន និង អង្គការដៃគូ<br>-ក្រសួងពាក់ព័ន្ធ អង្គការ WINROCK, UN-ACT, IOM<br>-ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | - រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់អគ្គលេខាធិការដ្ឋាន និងផែន ការសកម្មភាពឆ្នាំ២០១៥ និងឆ្នាំ២០១៦ និងផែនការថវិកា ឆ្នាំ ២០១៦ (ចំនួន០៣លើក) ។ | -សមាជិកអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |

| | | |
|---|---|---|
| | - ប្រជុំពិភាក្សា រៀបចំយុទ្ធសាស្ត្រការងារគ្រប់គ្រងលំហូរ ទេសន្តរប្រវេសន៍ និងផែនការសកម្មភាព (០២លើក) ។ | -សមាជិកក្រុមការងារ ទេសន្តរប្រវេសន៍ ក្រសួងការងារ និងអង្គការ UN Women |
| | - ប្រជុំពិភាក្សា រៀបចំផែនការចុះ ពង្រឹងការងារលេខាធិការដ្ឋាន រាជធានី-ខេត្ត និងបើកវគ្គបណ្តុះបណ្តាល(០៣លើក) និងរៀបចំផែនការបន្តរបស់រាជធានី-ខេត្ត ដោយផ្អែកលើ ផែនការជាតិ ។ | -អគ្គលេខាធិការដ្ឋាន |
| | - ប្រជុំ និងពិភាក្សាការងារ រៀបចំផែនការសកម្មភាពជាតិ និងកៀរគរការចូលរួមគាំទ្រ ជាថវិកា បច្ចេកទេស និងសកម្មភាពក្នុងការអនុវត្តផែនការបន្ត។ | -អង្គការដៃគូរជាតិ និងអន្តរជាតិ |
| | - ប្រជុំពិភាក្សា រៀបចំរបាយការណ៍ឆ្លើយតបទៅនឹងអនុសាសន៍ជាផែនការសកម្មភាពរបស់សហរដ្ឋអាមេរិក ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដាក់ជូនគណៈកម្មាធិការជាតិ និងផ្ញើទៅស្ថានទូតអាមេរិក(ចំនួន០៣លើក)។ | -ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | - ប្រជុំបែងចែកភារកិច្ចបណ្តោះអាសន្ន និង ណែនាំអំពីភារកិច្ច និងផែនការបណ្តុះបណ្តាលមន្ត្រី ក្នុងអគ្គលេខា ធិការដ្ឋាន និងមន្ត្រីតាមបណ្តាលេខាធិការដ្ឋានក្នុងរាជធានី-ខេត្ត(ចំនួន០២លើក)។ | -មន្ត្រីអគ្គលេខាធិការដ្ឋាន |
| | - ដឹកនាំកិច្ចប្រជុំប្រចាំសប្តាហ៍សម្របសម្រួលការប្រមូល ទិន្នន័យ និងធ្វើរបាយការណ៍សកម្មភាព និងលទ្ធផលនៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំខែ ត្រីមាស ឆមាសជាទៀងទាត់ និងរបាយការណ៍លទ្ធផលរបស់គ.ជ.ប.ជ ឆ្នាំ២០១៤ ទិសដៅឆ្នាំ២០១៥ (ចំនួន០៦លើក)។ | -មន្ត្រីអគ្គលេខាធិការដ្ឋាន |
| | - ជួបពិភាក្សាជាប្រចាំជាមួយមន្ត្រីជំនួយការទទួលបន្ទុកក្រុមការងារ ជំនាញក្រសួង ស្ថាប័ន និងទំនាក់ទំនងជាមួយមន្ត្រីទទួលបន្ទុកតាមបណ្តារាជធានី-ខេត្ត ដើម្បីតាមដាន ប្រមូលទិន្នន័យ និងរបាយការណ៍សកម្មភាព និងលទ្ធផល។ | -មន្ត្រីអគ្គលេខាធិការដ្ឋាន |
| | - ប្រជុំជាមួយលេខាធិការដ្ឋាន និងមន្ត្រីទទួលបន្ទុកការងាររបាយការណ៍នៃរាជធានី ខេត្តទាំង២៥ ដើម្បីពិនិត្យកែសម្រួលរបាយការណ៍ជាតិ (ចំនួន០១លើក)។ | -សមាជិករាជធានី-ខេត្ត |
| | - ជួបជាមួយប្រតិភូសភា និងក្រសួងការបរទេសសហរដ្ឋអាមេរិក រួមជាមួយក្រុមមន្ត្រីជំនាញ និងអង្គការUSAID ចំនួន១០នាក់ (០១លើក) និងមន្ត្រី ស្ថានទូតថ្មី ចំនួន០៤នាក់ (០១លើក) ក្នុងគោលបំណងស្វែងយល់ពីការរីក ចំរើនក្នុងការងារប្រឆាំងការជួញដូរមនុស្សរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើការវាយតម្លៃសកម្មភាពការងារ | -មន្ត្រីស្ថានទូតសហរដ្ឋអាមេរិក អង្គការ USAID |
| | - ដឹកនាំ សម្របសម្រួល និងជាគ្រូឧទ្ទេស ក្នុងសិក្ខាសាលាបណ្តុះបណ្តាលមន្ត្រីនគរបាល និងអាជ្ញាធរមូលដ្ឋាន នៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ តាមការស្នើ និងគាំទ្រ | -ស្ថាប័ន និង អាជ្ញាធរមូលដ្ឋាន និង អង្គការដៃគូរ |

| | | |
|---|---|---|
| | ដោយអង្គការ IOM,UNACT, Cambodia ACTs, CWCC, World Vision, Winrock, CARAM,... | |
| | - ចូលរួមរៀបចំ និងធ្វើជាវាគ្មិន ក្នុងវេទិកាតុមូល សម្រាប់ការផ្សព្វផ្សាយតាមទូរទស្សន៍ជាតិកម្ពុជា ស្តីពីជម្រើសការងារ និងមុខរបរសម្រាប់ប្រជាជនកម្ពុជា ដែលគាំទ្រដោយ អង្គការ CARE និងសម្ព័ន្ធអង្គការ Chabdai និងមានការចូលរួមពីតំណាងក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍។ | -តំណាង គ.ជ.ប.ជ<br>ក្រសួងការងារ<br>សមាគមនារីកម្ពុជា |
| | - ជួបជាមួយប្រតិភូស្ថានទូតហ្វីលីពីន(០១លើក) និងប្រតិភូអង្គការអន្តរជាតិមួយចំនួនក្នុងតំបន់ (០៣លើក) ដែលមកស្វែងយល់ពីយន្តការជាតិ យុទ្ធសាស្ត្រ និងបទពិសោធន៍ ក្នុងការឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស នៅកម្ពុជា ។ | -តំណាងស្ថានទូតហ្វីលីពីន<br>ប្រតិភូអង្គការអន្តរជាតិ |
| | - ប្រជុំជាមួយមន្ត្រីស្ថានទូតអាមេរិក និងអ្នកវាយតម្លៃឯករាជ្យអំពីលទ្ធផលនៃការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា CTIP II (ចំនួន០២លើក) ។ | -មន្ត្រីស្ថានទូតអាមេរិក |
| | - ប្រជុំពិភាក្សាជាមួយគ្រូបង្គោល រៀបចំឯកសារ និងសកម្មភាពចុះបណ្តុះបណ្តាលមន្ត្រីជួរមុខ និងបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់មន្ត្រីថ្នាក់មូលដ្ឋានក្នុងខេត្តពោធិ៍សាត់ បាត់ដំបង និងកំពត (ចំនួន០៣លើក)។ | -គ្រូបង្គោលនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស<br>អង្គការ Cambodia ACTs |
| | - ជួបពិភាក្សាដើម្បីស្វែងយល់អំពីស្ថានភាពគោលនយោបាយជាតិ និង កិច្ចសហប្រតិបត្តិការការងារបណ្តុះបណ្តាល និងអប់រំផ្សព្វផ្សាយពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ | -អង្គការ World Vision ជប៉ុន |
| | - ជួបជាមួយអ្នកស្រាវជ្រាវមកពីវិទ្យាស្ថានស្រាវជ្រាវ NEXUS ក្នុងគម្រោងអង្គការ IOM និងអង្គការ LSCW ដើម្បី សិក្សាអំពីករណីជនរងគ្រោះកម្ពុជាតាមទូកនេសាទ នៅ មហាសមុទ្រប៉ាស៊ីហ្វិកអាហ្វ្រិចខាងត្បូង តាមរយៈក្រុម ហ៊ុន GIANT OCEAN ដើម្បីរកដំណោះស្រាយសង្គ្រោះ និងអនុវត្តតាមនីតិវិធីច្បាប់ ។ | -វិទ្យាស្ថានស្រាវជ្រាវ<br>NEXUS |
| | - ប្រជុំពិភាក្សា ស្តីពីការដាក់បញ្ចូលផែនការសកម្មភាពរបស់ AAPTIP ជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ។ | -អង្គការAAPTIP |
| | - ពិភាក្សា លើផែនការសកម្មភាពដែលត្រូវអនុវត្តនៅខេត្ត ព្រៃវែង ខេត្តកំពង់ចាម និងកិច្ចសហការលើការរៀបចំ វេទិកាតុមូល ។ | -អង្គការCARE<br>Cambodia |
| | - ជួបពិភាក្សាលើគម្រោងអប់រំ និងផ្សព្វផ្សាយ ទប់ស្កាត់ការជួញដូរមនុស្សដល់អាជ្ញាធរមូលដ្ឋាន គ្រូ សិស្ស និងសហគមន៍ ដល់ខេត្តកំពង់ចាម និងខេត្តសៀមរាប ។ | -អង្គការចាប់ដៃ |
| | - ជួបប្រជុំសិក្សាស្វែងយល់ពីសកម្មភាពការងាររបស់គណៈ | -អង្គការ ចំនួន១១ (មកពី |

| | | |
|---|---|---|
| | កម្មាធិការជាតិ (គ.ជ.ប.ជ) និងយន្តការជាតិ ។<br>- លោកជំទាវ **ជូ ប៊ុនអេង** បានដឹកនាំក្រុមការងារជួបពិភាក្សាការងារជាមួយ ឯកឧត្តម **អ៊ិតសំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការការពារ និងការគ្រប់គ្រងលំហូរពលករទេសន្តរប្រវេសន៍ ។ | កម្ពុជា ថៃ និងហ្វីលីពីន)<br>-ប្រតិភូ គ.ជ.ប.ជ |
| | - ចូលរួមធ្វើជាវាគ្មិនក្នុងវេទិកាយុវជនថ្នាក់ជាតិ ប្រឆាំងទៅនឹងការជួញដូរមនុស្សការរំលោភបំពាន និងពលកម្មកុមាររៀបចំដោយអង្គការ World Vision ប្រចាំនៅកម្ពុជា ។ | -លោក **យឹម វិរៈ** អគ្គលេខាធិការរង គ.ជ.ប.ជ |
| | - ប្រកាសដាក់ឲ្យប្រើប្រាស់សំភារៈសម្រាប់យុទ្ធនាការផ្សព្វផ្សាយស្តីពី "សុវត្ថិភាពកុមារ ក្នុងវិស័យទេសចរណ៍" រៀបចំដោយអង្គការ World Vision ។ | -លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ |
| | - សម្ពោធការប្រើប្រាស់សារឆ្លើយតបជាសំឡេង ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពរៀបចំដោយអង្គការ WINROCK ។ | -មន្ត្រីអង្គការ UN |
| | - ជួបជាមួយមន្ត្រីអង្គការសហប្រជាជាតិ ទទួលបន្ទុកផលិតឯកសារដើម្បីផ្តល់កិច្ចសម្ភាសន៍ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងនិងអំពើជួញដូរមនុស្ស ។ | -គ.ជ.ប.ជ |
| | - ចុះសួរសុខទុក្ខក្មេងស្រីរងគ្រោះនៅមណ្ឌល CCPCR ករណីម្ចាស់ផ្ទះប្រើទារុណកម្មលើរាងកាយ និង ផ្លូវចិត្តធ្ងន់ធ្ងរ ។ | -លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ |
| | - ចូលរួមជាវាគ្មិនក្នុងកិច្ចសម្ភាសន៍តាមវិទ្យុ ទូរទស្សន៍ជាតិ និងអន្តរជាតិ អំពីការជួញដូរផ្លូវភេទលើកុមារ និងបញ្ហាទេសន្តរប្រវេសន៍ ។ | -លោក **យឹមវិរៈ** អគ្គលេខាធិការរង គ.ជ.ប.ជ |
| | - ចាត់មន្ត្រីអចិន្ត្រៃយ៍លេខាធិការដ្ឋាន ចូលរួមធ្វើជាវាគ្មិន ក្នុងកម្មវិធីទូរទស្សន៍ CTN PLUS ក្រោមប្រធានបទការការពារជនរងគ្រោះឆ្លងដែន ។ | -វិទ្យាស្ថានស្រាវជ្រាវ CDRI |
| | - ជួបពិភាក្សាលើបញ្ហា លំហូរទេសន្តរប្រវេសន៍ ការងារនៅក្រៅប្រទេស អំពីសុវត្ថិភាព និងការទទួលខុសត្រូវផ្នែកច្បាប់ | -ក្រសួងសង្គមកិច្ច អង្គការ World Vision និងអង្គការដៃគូរ |
| | - ប្រជុំស្តីពីការផ្លាស់ប្តូរនីតិវិធីពីការថែទាំកុមារីរងគ្រោះ ក្នុងមណ្ឌលនាវាថ្មី ឲ្យទៅសហគមន៍វិញ ។ | -សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល |
| | - ចុះហត្ថលេខា លើអនុស្សរណៈនៃការយោគយល់គ្នារវាង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរកុមារនៅកម្ពុជា ។ | -អង្គការ APLE និង អង្គការ Care |
| | - ចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាចំនួន០២ ក្នុងកិច្ចសហប្រតិបត្តិការរវាងលេខាធិការដ្ឋាន គ.ជ.ប.ជ និងអង្គការសកម្មភាពដើម្បីកុមារ (APLE) រវាងលេខាធិការដ្ឋាន គ.ជ.ប.ជ និងអង្គការ CARE (ចំនួន០២លើក) ។ | -អង្គការ Child Wise អង្គការទស្សនៈពិភពលោក |
| | - ប្រជុំជួបជាមួយអង្គការ Child Wise (០១លើក) និង អង្គការ | -អន្តរក្រសួងនិងអង្គការដៃគូ |

| | | |
|---|---|---|
| | ទស្សនៈពិភពលោក (០១លើក) ពិភាក្សាការសុំចុះធ្វើអនុស្សរណៈយោគយល់គ្នា MOU ក្នុងកិច្ចសហការ ការងារបង្ការទប់ស្កាត់ និងសហការរៀបចំកម្មវិធីសុវត្ថិភាព កុមារ ។ | |
| | - ប្រជុំពិភាក្សាផ្តល់យោបល់លើសេចក្តីព្រាងកិច្ចសន្យា ពលករបម្រើការងារនៅម៉ាឡេស៊ី និង និយោជកដែលមាន ក្នុងគោលបំណងការពារសុវត្ថិភាពចំពោះពលករ ។ | -អង្គការទស្សនៈពិភពលោក |
| | - ប្រជុំពិភាក្សាជាមួយ ស្តីពីការផ្សព្វផ្សាយសារអប់រំបង្ការទប់ស្កាត់អំពើជួញដូរកុមារ ជាsticker ឬផ្ទាំងប៉ាណូតាមទីសាធារណៈ និងការងារបណ្តុះបណ្តាល (០១លើក) ។ | -អង្គការទស្សនៈពិភពលោកថ្នាក់តំបន់ |
| | - ប្រជុំជាមួយក្រុមដឹកនាំថ្នាក់តំបន់ ដឹកនាំដោយលោកស្រី Aarti Kapoor អ្នកគ្រប់គ្រងកម្មវិធីប្រចាំតំបន់ពាក់ព័ន្ធ ការរៀបចំកម្មវិធីសុវត្ថិភាពកុមារ និងកិច្ចសហការជាមួយលេខាធិការដ្ឋានជាតិ (០១លើក ) ។ | -អង្គការ IJM |
| | - ប្រជុំពិភាក្សាស្តីពី វិស័យយុត្តិធម៌ពាក់ព័ន្ធនឹងកិច្ចអន្តរាគមន៍ជួយជនរងគ្រោះដោយអំពើជួញដូរមនុស្សសហការជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ០១លើក ។ | -ជាមួយក្រសួងស្ថាប័នដៃគូជាតិ អន្តរជាតិ |
| | - ប្រជុំពិភាក្សាពិគ្រោះយោបល់ ស្តីពីបញ្ហាពលករទេសន្តរប្រវេសន៍ និងកិច្ចការពារ ។ | -លោកជំទាវ **ជូ ប៊ុនអេង** |
| | - ធ្វើជាវាគ្មិនក្នុងសិក្ខាសាលាស្តីពីទេសន្តរប្រវេសន៍ និងការអភិវឌ្ឍន៍ នៅសណ្ឋាគារកាំបូឌីយ៉ាណា (រៀបចំដោយអង្គការ ខារ៉ាម) ។ | -អង្គការ Winrock |
| | - ជួបពិភាក្សាការងារ រៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីបញ្ហាជួញដូរមនុស្សក្នុងវិស័យនេសាទ និងពិនិត្យខ្សែវីដេអូបង្ហាញអំពីភាពរងគ្រោះដើម្បីធ្វើការផ្សព្វផ្សាយ ។ | -អង្គការ IJM |
| | - ជួបជាមួយអង្គការ IJM ពិភាក្សាលើបញ្ហាស៊ើបអង្កេតដោយសម្ងាត់ដើម្បីមានដំណោះស្រាយផ្លូវច្បាប់ បំពេញបន្ថែមនីតិវិធីក្នុងការអនុវត្ត ។ | -អង្គការ Plan |
| | - ជួបពិភាក្សាលើការស្រាវជ្រាវស្ថានភាពកុមារនិងកិច្ចការពារកុមារនៅកម្ពុជា ផ្តោតលើការអនុវត្តឆ្លើយតប និងការដោះស្រាយបញ្ហា ។ | - អង្គការCambodia ACTs និងអង្គការ CARE |
| | - ជួបពិភាក្សាលើការរៀបចំតុមូល ក្នុងកម្មវិធីទូរទស្សន៍ ស្តីពីទេសន្តរប្រវេសន៍ការងារ និងការទប់ស្កាត់អំពើជួញដូរមនុស្ស (ចំនួន០២លើក) ។ | -អង្គការ Winrock |
| | - ជួបពិភាក្សា និងរៀបចំកិច្ចប្រជុំអន្តរក្រសួង ពិនិត្យលើការរៀបចំសេចក្តីព្រាងផែនការសកម្មភាពជាតិជំហាន២ សម្រាប់ឆ្នាំ ២០១៩-២០១៨ (ចំនួន០៣លើក)។ | -អង្គការចាប់ដៃ |
| | - ប្រជុំពិនិត្យ និងឆ្លងការផ្សព្វផ្សាយបទយកការណ៍ ស្តីពីការកេងប្រវ័ញ្ចពលកម្មក្រោមរូបភាពទេសន្តរប្រវេសន៍ការងារ និង រូប | -អង្គការ World Vision |

| | | |
|---|---|---|
| | ភាពអាពាហ៍ពិពាហ៍ជាមួយជនបរទេស(ចិន) ដោយខុសច្បាប់ ។ | |
| | - ជួបពិភាក្សាក្នុងការផលិតឯកសាបណ្តុះបណ្តាល ស្តីពីការរក្សាសុវត្ថិភាពកុមារ ។ | -អង្គការ UN Women |
| | - ជួបពិភាក្សាលើបញ្ហាបណ្តុះបណ្តាល ពង្រឹងសមត្ថភាពអំពីច្បាប់ និង ជំនាញទាក់ទងនឹងការជួញដូរមនុស្ស ដល់មន្ត្រីអនុវត្តន៍ច្បាប់ ។ | -គ.ជ.ប.ជ<br>មន្ត្រីខេត្តកណ្តាល |
| | - សម្របសម្រួលរៀបចំការធ្វើសិក្ខាសាលា និងធ្វើជាវាគ្មិន ស្តីពីការពង្រឹងប្រសិទ្ធភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ ជាមួយខេត្តកណ្តាល ។ | -លោក **យឹម វិរៈ** អគ្គលេខាធិការរង គ.ជ.ប.ជ និងអង្គការ ខារ៉ាម |
| | - អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដឹកនាំធ្វើវេទិការ សាធារណៈ ចំនួន០២លើក ស្តីពីសុវត្ថិភាពចំណាកស្រុក និង ការជួញដូរមនុស្ស ធ្វើក្នុងស្រុកកំពង់ត្រាច០១លើក និង ស្រុកឈូក០១លើក ក្នុងខេត្តកំពត ដោយរៀបចំសហការ ឧបត្ថមពីអង្គការ CARAM ។ | -ទីប្រឹក្សា CNCC<br>-លោក **យឹម វិរៈ** អគ្គលេខាធិការរង គ.ជ.ប.ជ |
| | - ជួបជាមួយទីប្រឹក្សារបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ឆ្លើយតបការអនុវត្តច្បាប់ ចំពោះការប្រព្រឹត្តបទល្មើស ពាក់ព័ន្ធកុមារនៅកម្ពុជា និងការរៀបចំផែនការសម្រាប់ សុវត្ថិភាពកុមារ។ | -លោក **យឹម វិរៈ** អគ្គលេខាធិការរង គ.ជ.ប.ជ |
| | - ធ្វើគណៈអធិបតីក្នុងពិធីបើកសិក្ខាសាលាស្តីពីភាពឈ្លាសវៃនៃទេសន្តរប្រវេសន៍ការងារ រៀបចំដោយមូលនីធិអាស៊ី និងសមាគមន៍យុវជនខ្មែរ ។ | -លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ |
| | - ធ្វើជាវាគ្មិន និងធ្វើបទបង្ហាញក្នុងសិក្ខាសាលាស្តីពីបញ្ហាយេនឌ័រនៅក្នុងលំហូរទេសន្តរប្រវេសន៍សហការរៀបចំដោយអគ្គលេខាធិការ ដ្ឋានជាតិ និងមជ្ឈមណ្ឌលស្រាវជ្រាវ អភិបាលកិច្ចរបស់ក្រសួងមហាផ្ទៃ ។ | -លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ |
| | - ប្រជុំជាមួយប្រធាន គ.ជ.ប.ជ ស្តីពីការបង្កើតអគ្គលេខា-ធិការដ្ឋាន គ.ជ.ប.ជ និង ពិនិត្យលើការរៀបចំតួនាទីភារកិច្ចក្រុមការងារអន្តរក្រសួង ។ | -គណៈកម្មាធិការជាតិ គ.ជ.ប.ជ |
| | - ប្រជុំពិនិត្យ រៀបចំធ្វើសេចក្តីសម្រេចភារកិច្ចរបស់ក្រុមការងារអន្តរក្រសួង ។ | -លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ |
| | - ប្រជុំពិភាក្សាលើបញ្ហា CTIP II និងកិច្ចសហការជាមួយ អង្គការ Winrock ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ | - USAID<br>អង្គការ Winrock |
| | - ប្រជុំពិភាក្សាលើកិច្ចសហការរៀបចំ វេទិកាផ្សព្វផ្សាយក្នុងទិវាប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ និងការបណ្តុះបណ្តាល | -អង្គការ Cambodia ACTs<br>អង្គការ CARE |

| | | |
|---|---|---|
| | ស្តីពីបញ្ហាចំណាកស្រុកដោយសុវត្ថិភាព ។<br>- ចូលរួមដឹកនាំយុទ្ធនាការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងទិវា១២ធ្នូ បាន០៤ខេត្ត គឺខេត្តកណ្តាល ខេត្តកំពង់ចាម ខេត្តព្រៃវែង និងខេត្តស្វាយរៀង (ចំនួន០៤លើក)។<br>- ប្រជុំពិភាក្សា លើកផែនការបណ្តុះបណ្តាល ពង្រឹងសមត្ថភាពមន្រ្តីចំនួន ០៥ខេត្ត (កណ្តាល បន្ទាយមានជ័យ កំពង់ធំ តាកែវ ព្រះវិហារ) ស្តីពីការរំលោភបំពានលើកុមារក្នុង សហគមន៍ ។<br>- ចូលរួមជាវាគ្មិនក្រុមប្រឹក្សាជាតិដើម្បីកុមារក្នុងវេទិកាកុមារ និងអ្នកធ្វើគោលនយោបាយ សរុបអ្នកចូលរួមចំនួន១៣០នាក់ ផ្តោតនិងឆ្លើយតបទៅនឹងសិទ្ធិជាមូលដ្ឋានរបស់កុមារ ។<br>- ដឹកនាំកិច្ចប្រជុំក្រុមការងារអន្តរក្រសួង រៀបចំរបាយការណ៍ឆ្លើយតបសកម្មភាពដែលបានអនុវត្តកន្លងមក ប្រៀបទៅនឹងផែនការសកម្មភាពរបស់សហរដ្ឋអាមេរិក ។<br>- ប្រជុំពិនិត្យលើការរៀបចំផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ ២០១៤-២០១៨ ។<br>- ជួបជាមួយស្ថានទូត Philippine ដើម្បីដកបទពិសោធន៍អំពីសកម្មភាពជួញដូរមនុស្ស ទាក់ទងទេសន្តរប្រវេសន៍ការងារ ។<br>- ចូលរួមជាវាគ្មិន នៅក្រសួងសង្គមកិច្ច ស្តីពីការឆ្លើយតបទៅនឹងសិទ្ធិរបស់កុមារកម្ពុជា ។<br>-ប្រជុំជួបជាមួយអង្គការ Aple ពិភាក្សារៀបចំធ្វើសិក្ខាសាលាចែករំលែកបទពិសោធន៍ អំពីការការពារ ថែទាំ និងការ បង្រ្កាបបទល្មើស (ចំនួន០១លើក) និងសុំការអនុញ្ញាតធ្វើ កិច្ចសហការជាមួយ គ.ជ.ប.ជ (ចំនួន០១លើក) ។<br>-ប្រជុំជួបជាមួយអង្គការ Cambodia ACTs រៀបចំការធ្វើ សិក្ខាសាលាថ្នាក់ជាតិ ស្តីពីការទប់ស្កាត់ ការជួញដូរមនុស្ស ដល់ក្រុមហ៊ុនជ្រើសរើសពលករ ។<br>-ធ្វើជាវាគ្មិន ស្តីពីការទប់ស្កាត់បញ្ហារំលោភបំពានផ្លូវភេទក្នុងមូលដ្ឋាន (ជីវិតយើងសង្គមយើង) ក្នុងកម្មវិធីវិទ្យុជាតិកម្ពុជា (០១លើក) និងពិនិត្យលើខ្សែភាពយន្តថ្មីសម្រាប់ផ្សព្វផ្សាយក្នុងការទប់ស្កាត់ អាពាហ៍ពិពាហ៍ខុសច្បាប់ទៅប្រទេសចិន (០១លើក) ។ | ខេត្តកណ្តាល<br>-លោកជំទាវ **ជូ ប៊ុនអេង** និងមន្ត្រី អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ<br>-អង្គការទស្សនៈពិភពលោក<br>-លោក **ឃឹម វិរៈ** អគ្គលេខាធិការរង គ.ជ.ប.ជ<br>-ក្រុមការងារអន្តរក្រសួង<br>-លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងក្រុមការងារអន្តរក្រសួង<br>-ស្ថានទូត Philippine<br>-លោក **ឃឹម វិរៈ** អគ្គលេខាធិការរង គ.ជ.ប.ជ<br>-អង្គការ Aple<br>--លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ<br>-លោក ស៊ុន វ៉ូ អគ្គលេខាធិការរង គ.ជ.ប.ជ<br>-អង្គការ Winrock |
| **ក្រុមការងារ អនុវត្តច្បាប់ នៃលេខាធិការដ្ឋាន** | - ប្រជុំពិភាក្សាលើការងារសិក្ខាសាលាថ្នាក់ជាតិ ជាមួយក្រសួងយុត្តិធម៌ និងអគ្គស្នងការដ្ឋាននគរបាលជាតិ ក្នុងការងារយុត្តិធម៌ព្រហ្មទណ្ឌ និង ពិភាក្សាលើការធ្វើមេរៀនបណ្តុះ បណ្តាលដល់ | -ក្រសួងយុត្តិធម៌<br>អង្គការ UNODC |

| | | |
|---|---|---|
| គ.ជ.ប.ជ ចំនួន ០១លើក | នគរបាលជួរមុខ និងនគរបាលឯកទេស ។ | |
| **ក្រសួងទេសចរណ៍** ចំនួន ០១លើក | ប្រជុំរៀបចំផលិតសម្ភារផ្សព្វផ្សាយរួមមាន៖ Sticker, Tent Card និងSigboard ស្តីពីការចូលរួមជួយការពារកុមារដែលមានខ្លឹមសារ "សូមធ្វើជាអ្នកដំណើរដែលជួយរក្សាសុវត្ថិភាពកុមារ Be a child Safe Traveller" សម្រាប់ធ្វើការផ្សព្វផ្សាយនៅតាមបណ្តារាជធានី-ខេត្ត ទាំង២៥ ។ | -អង្គការដៃគូ |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា** ចំនួន១១លើក | - ប្រជុំពិភាក្សាលើសេចក្តីព្រាងកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។<br>- ប្រជុំពិភាក្សាបន្តលើ សេចក្តីព្រាងគោលការណ៍ណែនាំការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ។<br>- ប្រជុំពិភាក្សាពិនិត្យខ្សែភាពយន្តខ្នាតខ្លី ដែលមានឈ្មោះថាការជួញដូរមនុស្សក្រោមកម្មវិធីសមាហរណកម្ម នៃអង្គការ IOM ដើម្បីធ្វើការផ្សព្វផ្សាយ ។<br>- ប្រជុំពិភាក្សាជាមួយអង្គការមូលនិធិសុម៉ាលីម៉ម រៀបចំផែនការបណ្តុះបណ្តាល ស្តីពីគោលនយោបាយ និងបទដ្ឋាន អប្បបរមាស្តីពីកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្សទៅលើខេត្តគោលដៅចំនួន០៣ ។<br>- ប្រជុំពិភាក្សាអំពីកិច្ចព្រមព្រៀងរវាងអង្គការ Samaritans Purse International Relief ក្នុងកិច្ចសហការការងារ ។<br>- ប្រជុំជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ស្តីពីកិច្ចសហការអន្តរក្រសួង លើការងារជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។<br>- ប្រជុំពិនិត្យលើសេចក្តីព្រាងឧបករណ៍ត្រួតពិនិត្យ ការអនុវត្តបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស (ចំនួន០២លើក) ។<br>- ប្រជុំលើកទី២ ឆ្នាំ២០១៤ ក្រុមអ្នកពាក់ព័ន្ធធ្វើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។<br>- ប្រជុំត្រួតពិនិត្យការរៀបចំធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំ ។<br>- ចុះអនុវត្តសាកល្បងលើទម្រង់ នៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ក្នុងខេត្តចំនួន០៥ (សៀមរាប, បន្ទាយមានជ័យ, កំពង់ចាម, ស្វាយរៀង និង រាជធានីភ្នំពេញ) ។ | -អន្តរក្រសួង<br>-អន្តរក្រសួង<br>-អន្តរក្រសួង អង្គការដៃគូ<br>-អង្គការសូម៉ាលីម៉ម<br>-អង្គការ Samaritan Purse<br>-អង្គការ IJM<br>-អន្តរក្រសួង<br>-អន្តរក្រសួង<br>-ជំនាញ<br>-ជំនាញ និងអង្គការដៃគូ |
| **ក្រសួងកិច្ចការនារី (ក្រុមការងារខមមីត)** (ចំនួន១០លើក) | - ប្រជុំរៀបចំលិខិតជូនសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីសុំការអនុញ្ញាតជាគោលការណ៍ធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ច ប្រជុំមន្ត្រីជាន់ខ្ពស់ខមមីត (កិច្ចសម្របសម្រួលគំនិតផ្តួចផ្តើមថ្នាក់រដ្ឋមន្ត្រីប្រឆាំង | -ក្រុមការងារខមមីត |

| | | |
|---|---|---|
| | ការជួញដូរមនុស្ស នៅមហាអនុតំបន់មេគង្គ)លើកទី១០ និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីនៃដំណើរការខមមីតលើកទី៤ នៅដើមខែមេសា ឆ្នាំ២០១៥ នៅរាជធានីភ្នំពេញ ។ | |
| | -រៀបចំកិច្ចប្រជុំក្រុមការងារខមមីតកម្ពុជាពិនិត្យនិងពិភាក្សាលើរបាយការណ៍ការងារខមមីតឆ្នាំ២០១៣ និងទិសដៅឆមាសទី២ ឆ្នាំ២០១៤ ។ | -អង្គការ UN-ACT |
| | -រៀបចំកិច្ចប្រជុំក្រុមការងារខមមីតកម្ពុជា ដោយសហការជាមួយអង្គការ UN-ACT ក្នុងគោលបំណងពិនិត្យ និងពិភាក្សាលើការងារត្រៀមរៀបចំសម្រាប់កិច្ចប្រជុំមន្ត្រីជាន់និង ថ្នាក់រដ្ឋមន្ត្រីខ្ពស់ខមមីតលើកទី៤ ដែលនឹងត្រូវរៀប ចំឡើងនៅដើមខែមេសាឆ្នាំ២០១៥ នៅរាជធានីភ្នំពេញ ។ | -ក្រុមការងារខមមីត និងអង្គការ UN-ACT |
| | - រៀបចំកិច្ចប្រជុំអ្នកពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ប្រចាំត្រីមាសទី១ ឆ្នាំ២០១៤ ដើម្បីផ្លាស់ប្តូរ បទពិសោធន៍ចែករំលែកព័ត៌មាន និងផ្តល់ជាអនុសាសន៍សម្រាប់ការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅប្រទេសកម្ពុជា ដោយសហការជាមួយអង្គការ UN-ACT។ | -អន្តរក្រសួងពាក់ព័ន្ធ និងអង្គការដៃគូ |
| | -ប្រជុំក្រុមការងារខមមីតពិនិត្យ និងកែសម្រួលរបាយការណ៍សិក្សាស្រាវជ្រាវ ស្តីពីការជួញដូរមនុស្ស។ | -ក្រុមការងារ COMMIT |
| | - ប្រជុំពិនិត្យកែសម្រួលមេរៀនបណ្តុះបណ្តាលជនបង្គោល ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព ។ | -ក្រុមការងារ COMMIT |
| | -រៀបចំគម្រោងថវិកាសម្រាប់ចំណាយក្នុងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ខមមីត (កិច្ចសម្របសម្រួលគំនិតផ្តួចផ្តើមថ្នាក់រដ្ឋមន្ត្រីប្រឆាំងការជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គលើកទី១០) ។ | -ក្រុមការងារ COMMIT |
| | -ពិនិត្យ និងជួយកែសម្រួលឯកសារស្រាវជ្រាវស្តីពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកចំពោះគ្រួសារ និងសហគមន៍នៅខេត្តបាត់ដំបង ដោយសហការជាមួយមន្ទីរកិច្ចការនារីខេត្តបាត់ដំបង និងគាំទ្រដោយអង្គការ UN WOMEN ។ | -មន្ត្រីក្រសួងកិច្ចការនារី អង្គការ UN WOMEN |
| | -ប្រជុំក្រុមការងារខមមីតកម្ពុជា ក្រោមអធិបតីភាពលោកជំទាវវេជ្ជបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ដើម្បីពិនិត្យ និង ពិភាក្សាលើការរៀបចំផែនការសកម្មភាពអនុតំបន់លើកទី៤ ឆ្នាំ២០១៥-២០១៨ ដែលផ្តោតសំខាន់លើការកសាងប្រព័ន្ធនិងយន្តការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដែលមានអ្នកចូលរួមចំនួន៥២នាក់ ស្រី២៩នាក់ ។ | -អន្តរក្រសួង អង្គការដៃគូ |
| | - លោកជំទាវ **សាន្ត អរុណ** រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារខមមីតកម្ពុជា និងលោកជំទាវអនុរដ្ឋលេខាធិការទទួលបន្ទុក និងមន្ត្រីជំនាញ ជួបសម្ភាសន៍ជាមួយ មន្ត្រីតំណាងអង្គការ CDRI ជុំវិញបញ្ហាសិក្សាស្រាវជ្រាវ ស្តីពីទំនាក់ទំនងរវាងគោលនយោបាយសាធារណៈចំពោះ ចំណាកស្រុក និងការអភិវឌ្ឍនៅកម្ពុជា ។ | -ក្រុមការងារ COMMIT អង្គការ CDRI |

| | | |
|---|---|---|
| **ក្រសួងយុត្តិធម៌** ចំនួន ០១លើក | -ប្រជុំពិភាក្សាពិគ្រោះយោបល់លើសេចក្ដីព្រាងផែនការយុទ្ធសាស្ត្រនៃកម្មវិធីអូស្ត្រាលី អាស៊ីដើម្បីប្រឆាំងការជួញដូរមនុស្ស | -អង្គការដៃគូ |
| **ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ** ចំនួន ១៣លើក | -បានសហការជាមួយអង្គការ ILO គម្រោងអាស៊ានត្រីកោណ ប្រជុំពិគ្រោះយោបល់លើសេចក្ដីព្រាង អនុស្សរណៈនៃការយោគយល់គ្នារវាងរដ្ឋាភិបាលម៉ាឡេស៊ី និងរាជរដ្ឋាភិបាលកម្ពុជាស្ដីពីការជ្រើសរើស និងការដាក់ឲ្យពលករខ្មែរធ្វើការងារទូទៅនៅប្រទេសម៉ាឡេស៊ី<br>-សម្របសម្រួលកិច្ចប្រជុំជាមួយអង្គការអន្តរជាតិ(១២លើក)<br>-អធិការកិច្ចធ្វើការដាសតឿននិងពន្យល់ឲ្យអនុវត្តត្រឹមត្រូវតាមច្បាប់ បទបញ្ញា ជៀសវៀងសកម្មភាពពាក់ព័ន្ធការជួញដូរ ។ | -រដ្ឋាភិបាលម៉ាឡេស៊ី ILO,UNWomen,WI, IOM<br><br>-ក្រុមហ៊ុន |
| **លេខាធិការដ្ឋានរាជធានី-ខេត្ត បានសម្របសម្រួលកិច្ចប្រជុំការងារ មានដូចខាងក្រោម ៖** | | |
| ខេត្តកណ្ដាល | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន**១៣**លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តស្វាយរៀង | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន**២៨**លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តសៀមរាប | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន**០៨**លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តកំពង់ឆ្នាំង | សម្របសម្រួលកិច្ចប្រជុំការងារចំនួន **០២**លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តព្រះវិហារ | សម្របសម្រួលកិច្ចប្រជុំការងារចំនួន **០២**លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តព្រះសីហនុ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន**១១**លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តក្រចេះ | សម្របសម្រួលកិច្ចប្រជុំការងារចំនួន **០២**លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តស្ទឹងត្រែង | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន**០១**លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តកំពង់ស្ពឺ | សម្របសម្រួលកិច្ចប្រជុំការងារចំនួន **០២**លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តបាត់ដំបង | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន **៦៥**លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តកំពង់ធំ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន**១៥**លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តតាកែវ | សម្របសម្រួលកិច្ចប្រជុំការងារចំនួន**០១**លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តបន្ទាយមានជ័យ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន**១១**លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តកំពត | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន**០៥**លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តកែប | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន **០១**លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តព្រៃវែង | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន**៣៤**លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តកោះកុង | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន **០៤**លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តពោធិសាត់ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន**០២**លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តកំពង់ចាម | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន**១៣**លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តឧត្តរមានជ័យ | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន**១៣**លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តរតនៈគិរី | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន**០៤**លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តប៉ៃលិន | សម្របសម្រួលកិច្ចប្រជុំការងារ ចំនួន**០២**លើក | សមាជិកក្រុមការងារ និងអង្គការដៃគូ |
| ខេត្តត្បូងឃ្មុំ | (ខេត្តកើតថ្មី) | (ខេត្តកើតថ្មី) |
| **សរុប** | **លេខាធិការដ្ឋានខេត្ត ចំនួន២២ បានប្រជុំសម្របសម្រួល លើការងារ ចំនួន២៣៩លើក** | |

# ឧបសម្ព័ន្ធ ១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## លទ្ធផលបង្ក្រាបបទល្មើសអាជីវកម្មផ្លូវភេទ និងអំពើជួញដូរមនុស្ស ទូទាំងប្រទេស
## គិតចាប់ពីថ្ងៃទី ២៦-១២-២០១៣ ដល់ថ្ងៃទី ២៥-១២-២០១៤

| ល.រ | នាយកដ្ឋាន រាជធានី-ខេត្ត | បង្ក្រាបរួម | | | | | | | | អាជីវកម្មផ្លូវភេទ | | | | | | | | ជួញដូរមនុស្ស | | | | | | | | បញ្ជូនជនរងគ្រោះទៅ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បង្ក្រាបរួម | ជនល្មើស | | | ជនរងគ្រោះ | | | | បង្ក្រាប | ជនល្មើស | | | ជនរងគ្រោះ | | | | បង្ក្រាប | ជនល្មើស | | | ជនរងគ្រោះ | | | | មជ្ឈមណ្ឌលសង្គមកិច្ច | អង្គការ | គ្រួសារ |
| | | | រួម | ស្រី | បរទេស | រួម | -15 | 15-17 | 18+ | | រួម | ស្រី | បរទេស | រួម | -15 | 15-17 | 18+ | | រួម | ស្រី | បរទេស | រួម | -15 | 15-17 | 18+ | | | |
| 1 | បន្ទាយមានជ័យ | 7 | 7 | | | 84 | 3 | | 81 | 3 | 3 | | | 12 | 1 | | 11 | 4 | 4 | | | 72 | 2 | | 70 | | 7 | 77 |
| 2 | បាត់ដំបង | 9 | 9 | | 2 | 13 | 12 | 1 | | 7 | 7 | | 1 | 11 | 11 | | | 2 | 2 | | 1 | 2 | 1 | 1 | | | | 13 |
| 3 | កំពង់ចាម | 11 | 12 | 7 | | 22 | 4 | 11 | 7 | 2 | 2 | | | 10 | 2 | 7 | 1 | 9 | 10 | 7 | | 12 | 2 | 4 | 6 | | | 22 |
| 4 | កំពង់ឆ្នាំង | 2 | 2 | | | 2 | 2 | | | 2 | 2 | | | 2 | 2 | | | | | | | | | | | | | 2 |
| 5 | កំពង់ស្ពឺ | 1 | 1 | 1 | | 3 | | | 3 | | | | | | | | | 1 | 1 | 1 | | 3 | | | 3 | | | 3 |
| 6 | កំពង់ធំ | | | | | | | | | | | | | | | | | | | | | | | | | | | |
| 7 | កំពត | | | | | | | | | | | | | | | | | | | | | | | | | | | |
| 8 | កណ្តាល | 3 | 4 | 2 | | 13 | | 6 | 7 | 1 | 2 | 1 | | 9 | | 5 | 4 | 2 | 2 | 1 | | 4 | | 1 | 3 | 9 | 2 | 2 |
| 9 | កោះកុង | 4 | 6 | 2 | | 33 | | 3 | 30 | 2 | 3 | 2 | | 8 | | | 8 | 2 | 3 | | | 25 | | 3 | 22 | 4 | | 29 |
| 10 | ក្រចេះ | | | | | | | | | | | | | | | | | | | | | | | | | | | |
| 11 | មណ្ឌលគិរី | | | | | | | | | | | | | | | | | | | | | | | | | | | |
| 12 | ភ្នំពេញ | 21 | 35 | 18 | 7 | 63 | 14 | 6 | 43 | 11 | 14 | 6 | | 25 | 6 | 1 | 18 | 10 | 21 | 12 | 7 | 38 | 8 | 5 | 25 | 24 | 4 | 35 |
| 13 | ព្រះវិហារ | | | | | | | | | | | | | | | | | | | | | | | | | | | |
| 14 | ព្រៃវែង | 1 | 1 | 1 | | 2 | | | 2 | 1 | 1 | 1 | | 2 | | | 2 | | | | | | | | | | | 2 |
| 15 | ពោធិ៍សាត់ | | | | | | | | | | | | | | | | | | | | | | | | | | | |
| 16 | រតនគិរី | 1 | 1 | 1 | | 4 | 1 | | 3 | | | | | | | | | 1 | 1 | 1 | | 4 | 1 | | 3 | 4 | | |
| 17 | សៀមរាប | 3 | 3 | 1 | 2 | 8 | 4 | | 4 | 1 | 1 | | 1 | 3 | 3 | | | 2 | 2 | 1 | 1 | 5 | 1 | | 4 | | | 8 |
| 18 | ព្រះសីហនុ | 9 | 9 | 2 | 1 | 21 | 6 | 4 | 11 | 7 | 7 | 2 | 1 | 19 | 6 | 2 | 11 | 2 | 2 | | | 2 | | 2 | | 13 | | 8 |
| 19 | ស្ទឹងត្រែង | | | | | | | | | | | | | | | | | | | | | | | | | | | |
| 20 | ស្វាយរៀង | 1 | 1 | | | 1 | 1 | | | 1 | 1 | | | 1 | 1 | | | | | | | | | | | | | 1 |
| 21 | តាកែវ | | | | | | | | | | | | | | | | | | | | | | | | | | | |
| 22 | ឧត្តរមានជ័យ | 1 | 5 | 1 | | 51 | | 1 | 50 | | | | | | | | | 1 | 5 | 1 | | 51 | | 1 | 50 | | | 51 |
| 23 | កែប | | | | | | | | | | | | | | | | | | | | | | | | | | | |
| 24 | ប៉ៃលិន | | | | | | | | | | | | | | | | | | | | | | | | | | | |
| 25 | នាយកដ្ឋាន | 16 | 19 | 8 | 1 | 59 | 17 | 4 | 38 | 11 | 14 | 7 | 1 | 47 | 16 | 4 | 27 | 5 | 5 | 1 | | 12 | 1 | | 11 | 35 | 4 | 20 |
| 26 | កងរាជអាវុធហត្ថ | 5 | 12 | 1 | | 33 | 3 | | 30 | 5 | 12 | 1 | | 33 | 3 | | 30 | | | | | | | | | 15 | | 18 |
| 27 | ត្បូងឃ្មុំ | | | | | | | | | | | | | | | | | | | | | | | | | | | |
| | **សរុបរួម** | 95 | 127 | 45 | 13 | 412 | 67 | 36 | 309 | 54 | 69 | 20 | 4 | 182 | 51 | 19 | 112 | 41 | 58 | 25 | 9 | 230 | 16 | 17 | 197 | 104 | 17 | 291 |

(តារាងបទល្មើសពីអគ្គស្នងការដ្ឋាននគរបាលជាតិ)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ៩ ៤៧៧ ៤

# លទ្ធផលបង្ក្រាបបទល្មើស ជួញដូរមនុស្ស ទូទាំងប្រទេស
## គិតចាប់ពីថ្ងៃទី ២៦-១២-២០១៣ ដល់ថ្ងៃទី ២៥-១២-២០១៤

| ល.រ | នាយកដ្ឋាន រាជធានី-ខេត្ត | បង្ក្រាបសរុប | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | បង្ក្រាប | ជនរងគ្រោះ | | | | ជនល្មើស | | |
| | | | សរុប | -15 | 15-17 | 18 | សរុប | ប | ស |
| 1 | បន្ទាយមានជ័យ | 4 | 72 | 2 | | 70 | 4 | 4 | |
| 2 | បាត់ដំបង | 2 | 2 | 1 | 1 | | 2 | 2 | |
| 3 | កំពង់ចាម | 9 | 12 | 2 | 4 | 6 | 10 | 3 | 7 |
| 4 | កំពង់ឆ្នាំង | | | | | | | | |
| 5 | កំពង់ស្ពឺ | 1 | 3 | | | 3 | 1 | | 1 |
| 6 | កំពង់ធំ | | | | | | | | |
| 7 | កំពត | | | | | | | | |
| 8 | កណ្ដាល | 2 | 4 | | 1 | 3 | 2 | 1 | 1 |
| 9 | កោះកុង | 2 | 25 | | 3 | 22 | 3 | 3 | |
| 10 | ក្រចេះ | | | | | | | | |
| 11 | មណ្ឌលគិរី | | | | | | | | |
| 12 | ភ្នំពេញ | 10 | 38 | 8 | 5 | 25 | 21 | 9 | 12 |
| 13 | ព្រះវិហារ | | | | | | | | |
| 14 | ព្រៃវែង | | | | | | | | |
| 15 | ពោធិ៍សាត់ | | | | | | | | |
| 16 | រតនគិរី | 1 | 4 | 1 | | 3 | 1 | | 1 |
| 17 | សៀមរាប | 2 | 5 | 1 | | 4 | 2 | 1 | 1 |
| 18 | ព្រះសីហនុ | 2 | 2 | | 2 | | 2 | 2 | |
| 19 | ស្ទឹងត្រែង | | | | | | | | |
| 20 | ស្វាយរៀង | | | | | | | | |
| 21 | តាកែវ | | | | | | | | |
| 22 | ឧត្តរមានជ័យ | 1 | 51 | | 1 | 50 | 5 | 4 | 1 |
| 23 | កែប | | | | | | | | |
| 24 | ប៉ៃលិន | | | | | | | | |
| 25 | នាយកដ្ឋាន | 5 | 12 | 1 | | 11 | 5 | 4 | 1 |
| 26 | កងរាជអាវុធហត្ថ | | | | | | | | |
- បំពេញភារកិច្ចផ្សេងៗទៀត ដែលប្រធាន គ.ជ.ប.ជ និងក្រសួងមហាផ្ទៃប្រគល់ឱ្យ ។

**មាត្រា ៤.-**

អគ្គលេខាធិការដ្ឋាន មានសិទ្ធិប្រើប្រាស់ត្រា និងរូបសញ្ញាសម្គាល់របស់ គ.ជ.ប.ជ ។

**មាត្រា ៥.-**

អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប.ជ ដឹកនាំដោយអគ្គលេខាធិការ មួយរូប និងមានអគ្គលេខាធិការរងមួយចំនួន តាមការចាំបាច់

- អគ្គលេខាធិការ អគ្គលេខាធិការរង ត្រូវតែងតាំងតាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ។

**មាត្រា ៦.-**

អគ្គលេខាធិការដ្ឋាន នៃ គ.ជ.ប.ជ បង្កើតឱ្យមានលេខាធិការដ្ឋានរដ្ឋបាល សរុប មួយ សម្រាប់ដំណើរការលើការងារឱ្យមានប្រសិទ្ធភាព ។

**មាត្រា ៧.-**

អគ្គលេខាធិការដ្ឋាន នៃ គ.ជ.ប.ជ មានរចនាសម្ព័ន្ធ ដូចខាងក្រោម ៖

- លេខាធិការដ្ឋានរដ្ឋបាល សរុប
- ក្រុមមន្ត្រីជំនួយការ អគ្គលេខាធិការដ្ឋាន

លេខាធិការដ្ឋានរដ្ឋបាល សរុប ដឹកនាំដោយប្រធាន មួយរូប មានឋានៈ និងបុព្វសិទ្ធិស្មើប្រធាននាយកដ្ឋាន និងមានអនុប្រធានលេខាធិការដ្ឋាន ជាជំនួយការ មានឋានៈ និងបុព្វសិទ្ធិស្មើអនុប្រធាននាយកដ្ឋាន ចំណុះក្រសួងមហាផ្ទៃ.

ក្រុមមន្ត្រីជំនួយការរបស់អគ្គលេខាធិការដ្ឋាន មានចំនួនសមស្រប តាមទំហំក្រុមការងារជំនាញនីមួយៗ សម្រាប់ទំនាក់ទំនងការងារជាមួយក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន ដែលមានឋានៈ និងបុព្វសិទ្ធិស្មើ ប្រធាននាយកដ្ឋាន ឬអនុប្រធាននាយកដ្ឋាន

មន្ត្រីដែលបម្រើការងារក្នុងអគ្គលេខាធិការដ្ឋាន លេខាធិការដ្ឋាន និងក្រុមមន្ត្រីជំនួយការ ត្រូវមាន ក្របខ័ណ្ឌមកពីក្រសួងមហាផ្ទៃ ។ ក្នុងករណីចាំបាច់អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប.ជ អាចស្នើសុំមន្ត្រីជំនាញ ពីក្រសួងដទៃ ។

តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់លេខាធិការដ្ឋានរដ្ឋបាល សរុប និងក្រុមមន្ត្រីជំនួយការ ត្រូវកំណត់ ដោយប្រកាសរបស់ប្រធាន គ.ជ.ប.ជ ។

## ជំពូកទី ៣
## អវសានប្បញ្ញត្តិ

**មាត្រា ៨.-**

សេចក្តីសម្រេចលេខ ៩២ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ លេខាធិការដ្ឋាន "ប.ជ.រ.ព.ភ" និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនៃអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង មហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ប្រធានស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧ៣ ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីគោរពជម្រាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី**
**សូមហត្ថលេខា**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងប្រធាន គ.ជ.ប.ជ**

**ស ខេង**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការនៃរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# អង្គការលេខ របស់គណៈកម្មាធិការជាតិ
# ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស



# ឧបសម្ព័ន្ធ២

# សេចក្តីពន្យល់ អំពីរូបសញ្ញាគណៈកម្មាធិការជាតិ និងគណៈកម្មាធិការខេត្ត ប្រឆាំងការជួញដូរមនុស្ស

ក. រូបសញ្ញា**គ.ជ.ប.ជ**

មានសញ្ញាជារង្វង់កងចក្រ ខាងក្នុងមានរូបនិមិត្តសញ្ញារាងជាបាតដៃពីរទ្រមនុស្សបីនាក់ មានន័យថា រួមគ្នាអនុវត្តច្បាប់ ដើម្បីការពារ ប្រជាពលរដ្ឋ ទាំងបុរស ស្ត្រី និងកុមារ

និងមានអក្សរព័ទ្ធជុំវិញៈខាងលើជាភាសាខ្មែរ ថា**គណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស** និងមានអក្សរកាត់ បួនតួ គឺ **គ.ជ.ប.ជ**ខាងក្រោម ជាភាសាអង់គ្លេស ថា៖National Committee for Counter Trafficking (N.C.C.T) ដែលបញ្ជាក់អំពីយន្តការជាតិ ដែលមានលក្ខណៈ ជាអន្តរក្រសួង ស្ថាប័ន ក្នុងការងារប្រយុទ្ធប្រឆាំងរាល់ទម្រង់នៃការជួញដូរមនុស្ស ។

ខ. រូបសញ្ញា **គ.រ.ប.ជ** និង**គ.ខ.ប.ជ**

មានទ្រង់ទ្រាយប្រហាក់ប្រហែលគ្នា នឹងរូបសញ្ញាគណៈកម្មាធិការជាតិ តែរូបសញ្ញាបាតដៃទ្រមនុស្ស មានទំហំតូចជាង និងមានអក្សរខ្មែរ និងអង់គ្លេស បញ្ជាក់អំពី ថ្នាក់រាជធានី (ភ្នំពេញ) និងថ្នាក់ខេត្ត និងដែលមានឈ្មោះរាជធានី ខេត្តនីមួយៗ ផងដែរ ។



ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ១៨៥ សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣ /៩០៣ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## សម្រេច

ប្រការ១-

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១.ឯកឧត្តម **ស ខេង** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២.ឯកឧត្តម **អ៊ិត សំហេង** | រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣.លោកជំទាវ **អ៊ឹង កន្ថាផាវី** | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | អនុប្រធាន |
| ៤.ឯកឧត្តម **អង្គ វង្សវឌ្ឍានា** | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |

| | | |
|---|---|---|
| ៥.ឯកឧត្តម **ខេង សួត** | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៦.ឯកឧត្តម **ហង់ ជួនណារ៉ុន** | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៧.លោកជំទាវ **ជូ ប៊ុនអេង** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធានអចិន្ត្រៃយ៍ |
| ៨.ឯកឧត្តម នាយឧត្តមសេនីយ៍ | **នេត សាវឿន** អគ្គស្នងការ នគរបាលជាតិ | អនុប្រធាន |
| ៩.ឯកឧត្តម **ស៊ូ តិរិទ្ធ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១០.ឯកឧត្តម **ឡុង វិសាលោ** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១១.លោកជំទាវ **ដាំ ដារ៉ានី** | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ១២.ឯកឧត្តម **ជូ វិចិត្ត** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៣.លោកជំទាវ **ម៉ែន សុបតា** | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១៤.ឯកឧត្តម **ថៃ នរៈសត្យា** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៥.លោកជំទាវ **ម៉ាត់ ម៉ារ៉ា** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៦.លោកជំទាវ **ចាន់ ធី** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១៧.លោកជំទាវ **ទួច សារ៉ុម** | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | សមាជិក |
| ១៨.លោកជំទាវ **ម៉ាន់ ម៉ារា** | រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៩.លោកជំទាវ **តាន់ ឡូចឆេង** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ២០.លោកជំទាវ **ប្រាក់ ច័ន្ទណាយ** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ២១.លោកជំទាវ **ហោ ម៉ាលីន** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ២២.លោកជំទាវ **ឡាយ ណារិន** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ២៣.ឯកឧត្តម **ហោ សារុន** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ២៤.ឯកឧត្តម នាយឧត្តមសេនីយ៍ | **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ២៥.ឯកឧត្តម នាយឧត្តមសេនីយ៍ | **ម៉ៅ ច័ន្ទតារា** អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ | សមាជិក |
| ២៦.ឯកឧត្តម នាយឧត្តមសេនីយ៍ | **សុខ ផល** អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ | សមាជិក |
| ២៧.ឯកឧត្តម ឧត្តមសេនីយ៍ឯក | **សៀក សុជាតិ** នាយកទីចាត់ការការងារព្រំដែន អគ្គបញ្ជាការដ្ឋាន ក្រសួងការពារជាតិ | សមាជិក |

ប្រការ២-

ក្នុងករណីដែលក្រសួងស្ថាប័ន ឬអង្គភាពណាមួយមានការផ្លាស់ប្តូរសមាសភាពខាងលើ ត្រូវធ្វើសំណើមកប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីតែងតាំងជាថ្មី។

ប្រការ៣-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៤-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន អង្គភាព និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តតាមសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***<u>កន្លែងទទួល</u>***

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-អគ្គលេខាធិការរាជរដ្ឋាភិបាល*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*

*-ដូចប្រការ១*

*-រាជកិច្ច*

*-ឯកសារ*

*-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស
គ.ជ.ប.ជ
លេខ ០៩៤/១៤ ស.ស.រ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ចុះថ្ងៃទី២៤ខែកញ្ញាឆ្នាំ២០១៣ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនីតិកាលទី៥នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទចុះថ្ងៃទី១៥ខែកុម្ភៈ ឆ្នាំ២០០៨
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៦១៤/៨០៨ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការបង្កើត គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញអនុក្រឹត្យលេខ២៧៣អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## សម្រេច

**ប្រការ១**.-

ត្រូវបានបង្កើតក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័នចំនួន០៦ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជជាយន្តការសម្របសម្រួលការងារដឹកនាំ និង អនុវត្តដើម្បីធានាឱ្យមានកិច្ចសហការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងរាជរដ្ឋាភិបាល ផ្នែកឯកជន វិទ្យាស្ថានឬអ្នកស្រាវជ្រាវ អង្គការដៃគូជាតិ អន្តរជាតិ និងអ្នកពាក់ព័ន្ធដទៃទៀត ធ្វើឲ្យសម្រេចផែនការជាតិ និងយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

**ប្រការ២**.-

ក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័នទាំង០៦គឺ៖

១. ក្រុមការងារបង្ការ ទប់ស្កាត់

២. ក្រុមការងារការពារជនរងគ្រោះ

៣. ក្រុមការងារអនុវត្តន៍ច្បាប់

៤. ក្រុមការងារកិច្ចការយុត្តិធម៌

៥. ក្រុមការងារកិច្ចការទេសន្តរប្រវេសន៍

៦. ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ ។

**ប្រការ ៣**.-

ក្រុមការងារបង្ការ ទប់ស្កាត់ ដឹកនាំដោយក្រសួងអប់រំយុវជន និងកីឡា និងមានសមាសភាពមកពីក្រសួង ស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិ ដែលបាននឹងកំពុងធ្វើសកម្មភាពក្នុងគោលដៅបង្ការទប់ស្កាត់អំពើជួញដូរមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក. សមាសភាពៈ

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា(០១រូប) | អនុប្រធានអចិន្ត្រៃយ៍ |
| - តំណាងក្រសួងកិច្ចការនារី | អនុប្រធាន |
| - តំណាងក្រសួងទេសចរណ៍ | អនុប្រធាន |
| - តំណាងអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ | អនុប្រធាន |
| - តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - អគ្គនាយកបច្ចេកទេស ឬអគ្គនាយករងក្រសួងអប់រំយុវជន និងកីឡា | សមាជិក |
| - តំណាងក្រសួងព័ត៌មាន | សមាជិក |
| - តំណាងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី | សមាជិក |
| - តំណាងក្រសួងផែនការ | សមាជិក |
| - តំណាងក្រសួងវប្បធម៌ វិចិត្រសិល្បៈ | សមាជិក |
| - តំណាងក្រសួងធម្មការ សាសនា | សមាជិក |
| - តំណាងក្រសួងប្រៃសណីយ៍ ទូរគមនាគមន៍ | សមាជិក |
| - តំណាងក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| - តំណាងក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| - តំណាងក្រសួងសុខាភិបាល | សមាជិក |
| - តំណាងក្រសួងកសិកម្ម | សមាជិក |
| - តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| - តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ | សមាជិក |
| - តំណាងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មក្រសួងមហាផ្ទៃ | សមាជិក |
| - តំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ | សមាជិក |
| - តំណាងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| - តំណាងទីចាត់ការការងារព្រំដែន អគ្គបញ្ជាការដ្ឋាន ក្រសួងការពារជាតិ | សមាជិក |
| - តំណាងភាគបាតក្រហមកម្ពុជា | សមាជិក |

ម

- តំណាងសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ សមាជិក
- តំណាងសហភាពសហព័ន្ធយុវជន សមាជិក
- តំណាងអង្គការដៃគូជាតិ និងអន្តរជាតិដទៃទៀត សមាជិក ។

ខ. ភារកិច្ច៖

ក្រុមការងារបង្ការទប់ស្កាត់មានភារកិច្ចដូចតទៅ ៖

- ពង្រឹងកិច្ចសហការរវាងសមាជិកក្នុងក្រុមការងារ ជាមួយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងដៃគូពាក់ព័ន្ធដទៃទៀត ដើម្បី៖
  - ○ រៀបចំបង្កើតគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងថវិកាសម្រាប់ការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្សតាមគ្រប់រូបភាពនិងដាក់ជូន គ.ជ.ប.ជ ពិនិត្យ និងផ្តល់យោបល់
  - ○ បង្កើតសារឯកសារអប់រំនិងវិធីសាស្ត្រថ្មីៗសម្រាប់អប់រំយុវវ័យអំពីជម្រើសត្រឹមត្រូវដើម្បីអនាគត
  - ○ ផ្តល់ការយល់ដឹងអំពីច្បាប់ និងគោលនយោបាយពាក់ព័ន្ធអំពើជួញដូរមនុស្សដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់តាមមុខសញ្ញារបស់ស្ថាប័នរៀងៗខ្លួន
  - ○ បង្កើតសម្ភារអប់រំផ្សព្វផ្សាយ រៀបចំយុទ្ធនាការតាមគ្រប់រូបភាព ក្នុងកម្មវិធីសិក្សា វេទិកាសាធារណៈតាមសហគមន៍ និងតាមបណ្តាញផ្សព្វផ្សាយនានា
  - ○ ផ្តល់ការយល់ដឹងដល់គ្រូតាមបណ្តាគ្រឹះស្ថានសិក្សា និងសាលាបណ្តុះបណ្តាលគ្រូគ្រប់កម្រិតឲ្យយល់ដឹងអំពីអំពើជួញដូរមនុស្ស ផលប៉ះពាល់ កលល្បិចរបស់ជនល្មើសជួញដូរមនុស្ស និងការធ្វើអាជីវកម្មពលកម្ម និងផ្លូវភេទ ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស ដើម្បីអប់រំបន្តដល់យុវសិស្ស និងយុវវ័យក្នុងសហគមន៍
  - ○ ផ្លាស់ប្តូរយោបល់ និងបទពិសោធន៍ក្នុងការអប់រំតម្រង់ទិស កុមារ យុវជនក្នុងសាលា និងក្នុងសហគមន៍សំដៅលើកកម្ពស់កម្រិតនៃការទទួលបានការសិក្សាអប់រំ បំណិនជីវិត ជំនាញបច្ចេកទេស ពង្រីកកម្មវិធីតម្រង់ទិសវិជ្ជាជីវៈ និងមុខរបរ សំដៅលើកកម្ពស់ជីវភាពរស់នៅ កាត់បន្ថយការធ្វើចំណាកស្រុកដោយប្រថុយប្រថាន
- សហការជាមួយវិស័យឯកជន និងទីភ្នាក់ងារជ្រើសរើសពលករ ឲ្យយកចិត្តទុកដាក់អំពីកម្រិតវប្បធម៌ និងបង្កលក្ខណៈឲ្យបុគ្គលិក កម្មកររោងចក្រ សហគ្រាស និងពលករទេសន្តរប្រវេសន៍ មានឱកាសអភិវឌ្ឍន៍ចំណេះដឹង និងសមត្ថភាពជំនាញ
- ទទួលអនុវត្តគោលនយោបាយ គោលការណ៍ណែនាំផ្សេងៗរបស់រាជរដ្ឋាភិបាល និងតាមការណែនាំរបស់ គ.ជ.ប.ជ
- ពិនិត្យ កែលម្អសារ និងរូបភាពផ្សព្វផ្សាយជាសាធារណៈផ្សេងៗដើម្បីឲ្យទទួលបានលទ្ធផលជាវិជ្ជមាន ដែលអាចកាត់បន្ថយ និងលុបបំបាត់បទល្មើសជួញដូរមនុស្សគ្រប់រូបភាព
- រៀបចំកិច្ចប្រជុំប្រចាំខែ និងកិច្ចប្រជុំដទៃទៀតតាមការចាំបាច់
- ធ្វើរបាយការណ៍ទៀងទាត់អំពីលទ្ធផលសកម្មភាពនៃការអនុវត្តការងារ ទៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មិនហួសពីថ្ងៃចុងក្រោយនៃខែនីមួយៗ និងរបាយការណ៍ ត្រីមាស ឆមាស ឆ្នាំ ដើម្បីបូកសរុបរបាយការណ៍ជូនគណៈកម្មាធិការជាតិ គ.ជ.ប.ជ
- ប្រជុំក្រុមការងារទៀងទាត់ប្រចាំខែ និងកិច្ចប្រជុំផ្សេងទៀត តាមការចាំបាច់
- ចូលរួមសកម្មភាពដទៃទៀត តាមការប្រគល់ជូនពី គ.ជ.ប.ជ ។

**ប្រការ៤.-**

ក្រុមការងារការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមានសមាសភាពមកពីក្រសួង និងស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិ ដែលបាន និងកំពុងធ្វើសកម្មភាពក្នុងគោលដៅជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

ក. សមាសភាព៖

- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ក.ស.អ.យ) ប្រធាន
- រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ក.ស.អ.យ (០១រូប) អនុប្រធានអចិន្ត្រៃយ៍
- តំណាងក្រសួងកិច្ចការនារី អនុប្រធាន
- តំណាងអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ អនុប្រធាន
- តំណាងក្រសួងយុត្តិធម៌ អនុប្រធាន
- តំណាងក្រសួងការបរទេស អនុប្រធាន
- តំណាងក្រសួងអប់រំ យុវជន និងកីឡា សមាជិក
- តំណាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សមាជិក
- អគ្គនាយកបច្ចេកទេស ឬអគ្គនាយករង ក.ស.អ.យ សមាជិក
- តំណាងក្រសួងព័ត៌មាន សមាជិក
- តំណាងក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- តំណាងក្រសួងសុខាភិបាល សមាជិក
- តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ សមាជិក
- តំណាងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មក្រសួងមហាផ្ទៃ សមាជិក
- តំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ សមាជិក
- តំណាងកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
- តំណាងទីចាត់ការការងារព្រំដែន អគ្គបញ្ជាការដ្ឋាន ក្រសួងការពារជាតិ សមាជិក
- តំណាងកាកបាទក្រហមកម្ពុជា សមាជិក
- តំណាងសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ សមាជិក
- តំណាងសហភាពសហព័ន្ធយុវជន សមាជិក
- តំណាងអង្គការដៃគូជាតិ និងអន្តរជាតិដទៃទៀត សមាជិក

ខ. ភារកិច្ច៖

ក្រុមការងារការពារជនរងគ្រោះ មានភារកិច្ចដូចតទៅ ៖

- ពង្រឹង និងពង្រីកកិច្ចសហការរវាងសមាជិកក្នុងក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ស្ថាប័នរដ្ឋ ឯកជន និងអង្គការដៃគូ ទាំងនៅក្នុងស្រុក ទាំងនៅប្រទេសពាក់ព័ន្ធដើម្បី៖
  - រៀបចំបង្កើតគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងថវិកាសម្រាប់ការងារការពារជនរងគ្រោះ និងដាក់ជូន គ.ជ.ប.ជ ពិនិត្យ និងផ្តល់យោបល់
  - ផ្តល់ព័ត៌មាន កំណត់អត្តសញ្ញាណជនរងគ្រោះឱ្យបានត្រឹមត្រូវ និងជួយជនរងគ្រោះឱ្យបានទាន់ពេលវេលា

- ○ ជួយឲ្យជនរងគ្រោះមានសិទ្ធិទទួលបាននូវសេវាសមស្រប និងមានគុណភាពឆ្លើយតបទៅនឹងកម្រិតនៃភាពរងគ្រោះ មានជាអាច់សេវាថែទាំ កិច្ចការពារផ្លូវច្បាប់ ការផ្តល់ប្រឹក្សា សេវាសុខភាព សេវាសង្គមកិច្ច ការស្តារនីតិសម្បទា ការធ្វើមាតុភូមិនិវត្តន៍ ការធ្វើសមាហរណកម្មទៅក្នុងគ្រួសារ ឬសហគមន៍
- ○ លើកកម្ពស់សិទ្ធិជនរងគ្រោះក្នុងការចូលរួមក្នុងសកម្មភាពនានាដោយគ្មានការរើសអើង
- ○ លើកកម្ពស់ជីវភាពរស់នៅ ដល់ជនរងគ្រោះតាមរយៈការផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ បច្ចេកទេសកែច្នៃក្នុងមុខរបរ ឥណទាន អប់រំសីលធម៌និងបំណិនជីវិត ជាដើម
- ○ ផ្តល់កិច្ចការពារផ្លូវច្បាប់ដោយជួយរកនិង/ឬផ្តល់សេវាផ្នែកច្បាប់ដល់ជនរងគ្រោះឆ្លើយតបទៅនឹងល័ក្ខខ័ណ្ឌ និងកម្រិតនៃភាពរងគ្រោះរបស់បុគ្គល ឬក្រុមគោលដៅ
- ○ ទទួលយកជនរងគ្រោះដោយអំពើជួញដូរ ឬកេងប្រវ័ញ្ចដែលធ្វើមាតុភូមិនិវត្តន៍ ដើម្បីទទួលបានការស្តារនីតិសម្បទា សេវានានា និងធ្វើសមាហរណកម្ម
- ○ តាមដាន និងគ្រប់គ្រងករណីជាប្រព័ន្ធ និងចងក្រងប្រព័ន្ធទិន្នន័យ

- ចូលរួមតាមដាន ត្រួតពិនិត្យការអនុវត្តសកម្មភាពរបស់ស្ថាប័នទទួលខុសត្រូវក្នុងការចងក្រងឯកសារមេរៀនបទពិសោធន៍ ជាករណីសិក្សា ដើម្បីធ្វើឱ្យប្រសើរឡើងដល់ការអនុវត្តសកម្មភាពការពារជនរងគ្រោះ
- លើកកម្ពស់គុណភាពសេវាកម្មតាមមណ្ឌលថែទាំជនរងគ្រោះឲ្យស្របតាមបទដ្ឋានអប្បបរមានៃការថែទាំជំនួស
- បង្កើតល័ក្ខខ័ណ្ឌនៃការផ្តល់នីតិសម្បទាដល់មណ្ឌលថែទាំជនរងគ្រោះដើម្បីបង្កើតជាមណ្ឌលគំរូដែលមានលក្ខណៈងាយស្រួល និងផ្តល់សេវាជាកញ្ចប់
- ធ្វើរបាយការណ៍ទៀងទាត់អំពីលទ្ធផលសកម្មភាពនៃការអនុវត្តការងារ ទៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មិនហួសពីថ្ងៃចុងក្រោយនៃខែនីមួយៗ និងរបាយការណ៍ ត្រីមាស ឆមាស ឆ្នាំ ដើម្បីបូកសរុបរបាយការណ៍ជូនគណៈកម្មាធិការជាតិ គ.ជ.ប.ជ
- ប្រជុំក្រុមការងារទៀងទាត់ប្រចាំខែ និងកិច្ចប្រជុំផ្សេងទៀត តាមការចាំបាច់
- ចូលរួមសកម្មភាពដទៃទៀត តាមការប្រគល់ជូនពី គ.ជ.ប.ជ ។

**ប្រការ ៥**.-

ក្រុមការងារអនុវត្តន៍ច្បាប់ដឹកនាំដោយអគ្គស្នងការដ្ឋាននគរបាលជាតិ និងមានសមត្ថកិច្ចជំនាញមកពីក្រសួង ស្ថាប័នពាក់ព័ន្ធជាតិនិងអន្តរជាតិដែលបាននិងកំពុងធ្វើសកម្មភាពដោយស្របច្បាប់ និងមានការទទួលស្គាល់ពីរាជរដ្ឋាភិបាល ក្នុងគោលដៅរួមចំណែកធ្វើឲ្យសកម្មភាពបង្ក្រាបបទល្មើស ចាប់ជនល្មើស និងសង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស អាជីវកម្មពលកម្ម និងអាជីវកម្មផ្លូវភេទ ប្រកបដោយប្រសិទ្ធភាព ។

ក. សមាសភាព៖

| | |
|---|---|
| - អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | ប្រធាន |
| - អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (០១រូប) | អនុប្រធានអចិន្ត្រៃយ៍ |
| - តំណាងអគ្គមហាអយ្យការអមតុលាការកំពូល | អនុប្រធាន |
| - ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្សក្រសួងមហាផ្ទៃ | អនុប្រធាន |
| - តំណាងក្រសួងយុត្តិធម៌ | អនុប្រធាន |
| - តំណាងអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ | អនុប្រធាន |

- តំណាងកងរាជអាវុធហត្ថលើផ្ទៃប្រទេស អនុប្រធាន
- តំណាងក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក
- តំណាងក្រសួងកិច្ចការនារី សមាជិក
- តំណាងក្រសួងការបរទេស សមាជិក
- តំណាងក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- តំណាងក្រសួងសុខាភិបាល សមាជិក
- តំណាងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មក្រសួងមហាផ្ទៃ សមាជិក
- តំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ សមាជិក
- តំណាងទីចាត់ការការងារព្រំដែន អគ្គបញ្ជាការដ្ឋាន ក្រសួងការពារជាតិ សមាជិក
- តំណាងអង្គការដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធដទៃទៀត សមាជិក។

ខ. ភារកិច្ចៈ

ក្រុមការងារអនុវត្តន៍ច្បាប់ មានភារកិច្ចដូចតទៅ ៖

ពង្រឹងកិច្ចសហការរវាងសមាជិកក្នុងក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងដៃគូពាក់ព័ន្ធដទៃទៀត ដើម្បីៈ

- តាមដានត្រួតពិនិត្យសភាពការណ៍ និងការវិវត្តប្រែប្រួលនៃបទល្មើស កលល្បិចជនល្មើស ទំនោរនិងបញ្ហាសង្គមដែលជាកត្តាអូសទាញ ឬជំរុញ ឬនាំប្រជាពលរដ្ឋទៅរកភាពរងគ្រោះដោយការជួញដូរមនុស្ស ការរំលោភបំពាន និងការកេងប្រវ័ញ្ចគ្រប់រូបភាព
- រៀបចំបង្កើតគោលនយោបាយ យុទ្ធសាស្ត្រ វិធានការ ផែនការ និងថវិកា សម្រាប់ការងារបង្ក្រាប បទល្មើសជួញដូរមនុស្ស និងសង្គ្រោះជនរងគ្រោះ ដាក់ជូន គ.ជ.ប.ជ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ផ្នែកឯកជន អង្គការដៃគូ ស្ថានទូត និងសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ក្នុងតំបន់ និងជាអន្តរជាតិ ពង្រីកការចូលរួមពីប្រជាពលរដ្ឋដើម្បីប្រមូលពត៌មាន ដែលអាចធានាដល់វិធានការបង្ក្រាបបទល្មើស ចាប់ជនល្មើសនិងជួយជនរងគ្រោះ ក្នុងករណីអំពើជួញដូរមនុស្សឆ្លងដែនទាន់ពេលវេលា
- លើកកម្ពស់ការអនុវត្តអនុសញ្ញាណ សន្ធិសញ្ញា និងកត្តិកាសញ្ញាអន្តរជាតិ ច្បាប់ និងគោលនយោបាយជាតិ គោលការណ៍ណែនាំ កិច្ចព្រមព្រៀង អនុស្សរណៈទ្វេភាគី ពហុភាគី ផែនការនិងបទដ្ឋានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ជាមួយបណ្តាភាគីពាក់ព័ន្ធក្នុងប្រទេស ក្រៅប្រទេស ក្នុងតំបន់ និងជាអន្តរជាតិ ឱ្យទទួលបានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់
- ចូលរួមតាមដាន ត្រួតពិនិត្យការងារជំនាញមន្ត្រីអនុវត្តន៍ច្បាប់ នៅតាមបណ្តាមូលដ្ឋានថ្នាក់ក្រោមជាតិ ទីតាំងឈរជើងរបស់កម្លាំងសមត្ថកិច្ចរបស់រាជធានី ខេត្តជាប់ព្រំដែន និងមានវិធានការតឹងរឹងសំដៅលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអនុវត្តច្បាប់
- ជំរុញការអនុវត្តសកម្មភាពរបស់មន្ត្រីអនុវត្តន៍ច្បាប់នៅគ្រប់កម្រិតទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- លើកកម្ពស់ការប្រើប្រាស់សេវាទូរស័ព្ទទាន់ហេតុការណ៍ និងបានចាត់វិធានការសមស្រប ទាន់ពេលវេលា
- ធ្វើរបាយការណ៍ទៀងទាត់អំពីលទ្ធផលសកម្មភាពនៃការអនុវត្តច្បាប់ទៅអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ មិនហួសពីថ្ងៃចុងក្រោយនៃខែនីមួយៗ និងរបាយការណ៍ ត្រីមាស ឆមាស ឆ្នាំ ដើម្បីបូកសរុបរបាយការណ៍ជូនគណៈកម្មាធិការជាតិ គ.ជ.ប.ជ

- ប្រជុំក្រុមការងារទៀងទាត់ប្រចាំខែ និងកិច្ចប្រជុំផ្សេងទៀត តាមការចាំបាច់
- ចូលរួមសកម្មភាពដទៃទៀត តាមការប្រគល់ជូនពី គ.ជ.ប.ជ ។

**ប្រការ ៦.-**

ក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌ និងមានសមាសភាពមកពីក្រសួង និងស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិដែលបាន និងកំពុងធ្វើសកម្មភាពក្នុងគោលដៅផ្តល់កិច្ចការពារផ្នែកច្បាប់ ដើម្បីផ្តល់ភាពយុត្តិធម៌ជូនជនរងគ្រោះ និងផ្តន្ទាទោសជនល្មើសនៃអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ជាពិសេសលើស្ត្រីនិងកុមារ ។

ក. សមាសភាព៖

| | | |
|---|---|---|
| - រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | | ប្រធាន |
| - រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | (០១រូប) | អនុប្រធានអចិន្ត្រៃយ៍ |
| - តំណាងអគ្គមហាអយ្យការអមសាលាឧទ្ធរណ៍ | | អនុប្រធាន |
| - តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | | អនុប្រធាន |
| - តំណាងអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ | | អនុប្រធាន |
| - តំណាងអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងយុត្តិធម៌ | | សមាជិក |
| - តំណាងក្រុមប្រឹក្សានីតិកម្ម ក្រសួងមហាផ្ទៃ | | សមាជិក |
| - តំណាងក្រសួងការបរទេស | | សមាជិក |
| - តំណាងក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា | | សមាជិក |
| - តំណាងរាជអាវុធហត្ថលើផ្ទៃប្រទេស | | សមាជិក |
| - តំណាងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មក្រសួងមហាផ្ទៃ | | សមាជិក |
| - តំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ | | សមាជិក |
| - តំណាងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ | | សមាជិក |
| - តំណាងអង្គការដៃគូជាតិ និងអន្តរជាតិ | | សមាជិក។ |

ខ. ភារកិច្ច៖

ក្រុមការងារកិច្ចការយុត្តិធម៌ មានភារកិច្ច ៖

- រៀបចំនីតិវិធី និងផែនការសម្រាប់ការប្រមូលទិន្នន័យនៃការផ្តន្ទាទោស ករណីជួញដូរមនុស្សឲ្យបានជាប្រចាំ
- ប្រមូលទិន្នន័យពាក់ព័ន្ធនឹងដំណើរការផ្តន្ទាទោសករណីជួញដូរមនុស្ស ពីស្ថាប័នអយ្យការ និងសាលាដំបូងរាជធានី ខេត្តឱ្យបានទៀងទាត់តាមពេលវេលាកំណត់
- ពង្រឹងកិច្ចសហការរវាងស្ថាប័នអយ្យការ និងមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីការងារប្រមូលព័ត៌មាន និងភស្តុតាងឲ្យបានគ្រប់គ្រាន់ដើម្បីបម្រើឲ្យការងារផ្តន្ទាទោសប្រកបដោយយុត្តិធម៌
- ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ គោលការណ៍ណែនាំ វិធានការ និងផែនការនានា ដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សឱ្យទទួលបានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់
- ផ្សព្វផ្សាយអប់រំ និងបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ ជំរុញកិច្ចសហប្រតិបត្តិការជាមួយអន្តរជាតិក្នុងការអនុវត្តច្បាប់ដើម្បីបង្ក្រាបអំពើជួញដូរមនុស្ស ជាអាទិ៍ ការអនុវត្តសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ និងការធ្វើបត្យាប័ន នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ល។

- តាមដាន ត្រួតពិនិត្យការអនុវត្តនីតិវិធីពាក់ព័ន្ធការផ្តន្ទាទោស និងផ្លាស់ប្តូរបទពិសោធន៍ជាក់ស្តែងរវាងគ្នា ដើម្បីលើកកម្ពស់គុណភាពប្រព័ន្ធយុត្តិធម៌
- រៀបចំផែនការសកម្មភាព និងបង្កើតយុទ្ធសាស្ត្រឆ្លើយតបទៅនឹងសកម្មភាពការងារចំពោះមុខ
- ធ្វើរបាយការណ៍ទៀងទាត់អំពីលទ្ធផលសកម្មភាពនៃការអនុវត្តការងារ ទៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មិនហួសពីថ្ងៃចុងក្រោយនៃខែនីមួយៗ និងរបាយការណ៍ ត្រីមាស ឆមាស ឆ្នាំ ដើម្បីបូកសរុបរបាយការណ៍ជូនគណៈកម្មាធិការជាតិ គ.ជ.ប.ជ
- ប្រជុំក្រុមការងារទៀងទាត់ប្រចាំខែ និងកិច្ចប្រជុំផ្សេងទៀត តាមការចាំបាច់
- ចូលរួមសកម្មភាពដទៃទៀត តាមការប្រគល់ជូនពី គ.ជ.ប.ជ ។

**ប្រការ ៧**.-

ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយក្រសួងកិច្ចការនារី និងមានសមាសភាពមកពីក្រសួង និងស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិដែលបាន និងកំពុងធ្វើសកម្មភាពដោយមានកិច្ចសហការជាមួយប្រទេសពាក់ព័ន្ធ ក្នុងតំបន់ និងអន្តរជាតិ ក្នុងគោលដៅពង្រឹងកិច្ចសហការក្នុងការរៀបចំ និងជំរុញការអនុវត្តកិច្ចព្រមព្រៀង អនុស្សរណៈទ្វេភាគី ពហុភាគី ក្នុងគោលដៅជួយការពារប្រជាពលរដ្ឋកម្ពុជាពីភាពរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាពជាពិសេស លើស្ត្រី និងកុមារ នៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

ក. សមាសភាព៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងកិច្ចការនារី (០១រូប) | អនុប្រធានអចិន្ត្រៃយ៍ |
| - ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកកិច្ចការឧក្រិដ្ឋកម្មឆ្លងដែនក្នុងតំបន់អាស៊ាន | អនុប្រធាន |
| - តំណាងក្រសួងយុត្តិធម៌ | អនុប្រធាន |
| - តំណាងក្រសួងការបរទេស | អនុប្រធាន |
| - តំណាងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | អនុប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី | សមាជិក |
| - តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| - តំណាងក្រសួងទេសចរណ៍ | សមាជិក |
| - តំណាងក្រសួងព័ត៌មាន | សមាជិក |
| - តំណាងក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| - តំណាងក្រសួងសុខាភិបាល | សមាជិក |
| - តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ | សមាជិក |
| - តំណាងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មក្រសួងមហាផ្ទៃ | សមាជិក |
| - តំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ | សមាជិក |
| - តំណាងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| - តំណាងទីចាត់ការការងារព្រំដែន អគ្គបញ្ជាការដ្ឋាន ក្រសួងការពារជាតិ | សមាជិក |
| - តំណាងអង្គការដៃគូជាតិ និងអន្តរជាតិដទៃទៀត | សមាជិក។ |

ខ. ភារកិច្ច៖

ពង្រឹងកិច្ចសហការរវាងសមាជិកក្នុងក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងដៃគូពាក់ព័ន្ធដទៃទៀត ដើម្បី៖

- រៀបចំយុទ្ធសាស្ត្រ ផែនការ ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីឆ្លើយតបទៅនឹងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស
- ផ្សព្វផ្សាយលទ្ធផលនៃកិច្ចសហការ ព្រមទាំងសភាពការណ៍ និងការវិវត្តប្រែប្រួលនៃអំពើជួញដូរមនុស្ស ការរំលោភបំពាន និងការកេងប្រវ័ញ្ចក្នុងមហាអនុតំបន់មេគង្គ ក្នុងប្រទេសសមាជិកសហគមន៍អាស៊ីអាគ្នេយ៍ និងប្រទេសក្រៅតំបន់ ជាអន្តរជាតិដើម្បីរិះរកវិធានការកាត់បន្ថយឬលុបបំបាត់បទល្មើសជួញដូរមនុស្សឆ្លងដែន
- សម្របសម្រួលជាមួយ គ.ជ.ប.ជ និងក្រុមការងារជំនាញអន្តរក្រសួង ដើម្បីតាមដានវាយតម្លៃ និងជំរុញការអនុវត្តផែនការសហប្រតិបត្តិការ ទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសពាក់ព័ន្ធ
- សហការជាមួយក្រុមការងារពាក់ព័ន្ធដើម្បីលើកកម្ពស់ការអនុវត្តអនុសញ្ញា សន្ធិសញ្ញា និងកត្តិកាសញ្ញា កិច្ចព្រមព្រៀង អនុស្សរណៈទ្វេភាគី ពហុភាគី ផែនការនិងបទដ្ឋានពាក់ព័ន្ធនឹងកិច្ចសហការរវាងជាមួយបណ្តាប្រទេសភាគីពាក់ព័ន្ធក្នុងប្រទេស ក្រៅប្រទេស ក្នុងតំបន់ និងជាអន្តរជាតិ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឱ្យទទួលបានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់
- ចូលរួម តាមដាន ត្រួតពិនិត្យការអនុវត្តសកម្មភាពរបស់ស្ថាប័នពាក់ព័ន្ធទៅតាមផែនការ និងយុទ្ធសាស្ត្រដែលបានឯកភាព
- រៀបចំ និងសម្របសម្រួលការចូលរួមកិច្ចប្រជុំ សិក្ខាសាលា សន្និសីទជាតិនិងអន្តរជាតិពាក់ព័ន្ធនឹងការជួញដូរមនុស្ស
- ធ្វើរបាយការណ៍ទៀងទាត់អំពីលទ្ធផលសកម្មភាពនៃកិច្ចសហការ និងទិសដៅបន្តទៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មិនហួសពីថ្ងៃចុងក្រោយនៃខែនីមួយៗ និងរបាយការណ៍ ត្រីមាស ឆមាស ឆ្នាំ ដើម្បីបូកសរុបរបាយការណ៍ជូនគណៈកម្មាធិការជាតិ គ.ជ.ប.ជ
- ប្រជុំក្រុមការងារទៀងទាត់ប្រចាំខែ និងកិច្ចប្រជុំផ្សេងទៀត តាមការចាំបាច់
- ចូលរួមសកម្មភាពដទៃទៀត តាមការប្រគល់ជូនពី គ.ជ.ប.ជ ។

**ប្រការ ៨.-**

ក្រុមការងារទេសន្តរប្រវេសន៍ ដឹកនាំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានសមាសភាពមកពីក្រសួង និងស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិ ដែលបាន និងកំពុងធ្វើសកម្មភាពក្នុងគោលដៅតាមដាន និងទប់ស្កាត់អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មពលកម្ម និងអាជីវកម្មផ្លូវភេទក្រោមរូបភាពទេសន្តរប្រវេសន៍ ទាំងតាមប្រព័ន្ធស្របច្បាប់ និងតាមប្រព័ន្ធមិនស្របច្បាប់ ។

ក. សមាសភាព៖

| | |
|---|---|
| - រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| - រដ្ឋលេខា ឬអនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធានអចិន្ត្រៃយ៍ |
| - តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| - តំណាងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | អនុប្រធាន |
| - តំណាងក្រសួងយុត្តិធម៌ | អនុប្រធាន |

- តំណាងក្រសួងកិច្ចការនារី អនុប្រធាន
- អគ្គនាយក អគ្គនាយកដ្ឋានហត្ថពលកម្ម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- តំណាងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ សមាជិក
- តំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ សមាជិក
- តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ សមាជិក
- តំណាងនាយកដ្ឋានកណ្តាលនគរបាលព្រំដែន ក្រសួងមហាផ្ទៃ សមាជិក
- តំណាងក្រសួងសុខាភិបាល សមាជិក
- តំណាងកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
- តំណាងទីចាត់ការការងារព្រំដែន អគ្គបញ្ជាការដ្ឋាន ក្រសួងការពារជាតិ សមាជិក
- តំណាងសមាគមទីភ្នាក់ងារជ្រើសរើសពលករ សមាជិក
- តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក
- តំណាងក្រសួងព័ត៌មាន សមាជិក
- តំណាងកាកបាទក្រហមកម្ពុជា សមាជិក
- តំណាងសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ សមាជិក
- តំណាងសហភាពសហព័ន្ធយុវជន សមាជិក
- តំណាងអង្គការដៃគូជាតិ និងអន្តរជាតិដទៃទៀត សមាជិក។

ខ. ភារកិច្ចៈ

ក្រុមការងារគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ មានភារកិច្ច ៖

- ពង្រឹងកិច្ចសហការរវាងក្រសួង ស្ថាប័នជាសមាជិក អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងក្រុមការងារ ពាក់ព័ន្ធដើម្បី
  - រៀបចំយុទ្ធសាស្ត្រដើម្បីឆ្លើយតបទៅនឹងការគ្រប់គ្រងទេសន្តរប្រវេសន៍
  - ដាក់ចេញវិធានការសមស្រប ឆ្លើយតបទៅនឹងការលើកកម្ពស់សុវត្ថិភាពទេសន្តរប្រវេសន៍គ្រប់រូបភាព និងជួយដល់ជនរងគ្រោះទាំងនៅក្នុងប្រទេសនិងទាំងនៅក្នុងប្រទេសគោលដៅ
  - ជំរុញអនុវត្ត តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ សេចក្តីសម្រេច គោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល ផែនការ បទដ្ឋាននានាពាក់ព័ន្ធនឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ និងលើកកម្ពស់សុវត្ថិភាពពលករខ្មែរដែលទៅធ្វើការនៅក្រៅប្រទេស តាំងពីពេលចាកចេញពីផ្ទះ រហូតត្រឡប់មកដល់ផ្ទះវិញ
- ជំរុញឱ្យមានកិច្ចព្រមព្រៀង ឬអនុស្សរណៈទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសពាក់ព័ន្ធ ក្នុងតំបន់ និងអន្តរជាតិពាក់ដើម្បីការពារសិទ្ធិស្របច្បាប់របស់ពលករពលការិនីទេសន្តរប្រវេសន៍
- សហការជាមួយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ រៀបចំផែនការ និងតាមដាន ត្រួតពិនិត្យ វាយតម្លៃការអនុវត្តរបស់ក្រុមហ៊ុនជ្រើសរើសពលករស្របច្បាប់ដើម្បីមានវិធានការ ឬលើកសរសើរ
- ចាត់វិធានការលុបបំបាត់មេខ្យល់ជួញដូរមនុស្ស និងដោះស្រាយភាពរងគ្រោះរបស់ពលករ
- រៀបចំផែនការសកម្មភាព និងបង្កើតយុទ្ធសាស្ត្រឆ្លើយតបទៅនឹងសកម្មភាពការងារចំពោះមុខ

- ធ្វើរបាយការណ៍ទៀងទាត់អំពីលទ្ធផលសកម្មភាពនៃការអនុវត្តការងារ ទៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មិនហួសពីថ្ងៃចុងក្រោយនៃខែនីមួយៗ និងរបាយការណ៍ ត្រីមាស ឆមាស ឆ្នាំ ដើម្បីបូកសរុបរបាយការណ៍ជូនគណៈកម្មាធិការជាតិ គ.ជ.ប.ជ
- ប្រជុំក្រុមការងារទៀងទាត់ប្រចាំខែ និងកិច្ចប្រជុំផ្សេងទៀត តាមការចាំបាច់
- ចូលរួមសកម្មភាពដទៃទៀត តាមការប្រគល់ជូនពី គ.ជ.ប.ជ ។

**ប្រការ ៩.-**

សមាសភាពជាក់ស្តែងរបស់ក្រុមការងារនីមួយៗ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់គ.ជ.ប.ជ។

ក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ននីមួយៗ ត្រូវលើកគម្រោងថវិការួមសម្រាប់សកម្មភាពរួមរបស់ក្រុមការងារដែលត្រូវដាក់បញ្ចូលក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័នជាប្រធានក្រុមការងារ ។ រីឯថវិកាដែលត្រូវអនុវត្តសកម្មភាពជាជំនាញដោយឡែករបស់ក្រសួងស្ថាប័ន គឺជាបន្ទុករបស់សាមីក្រសួងស្ថាប័នរៀងៗខ្លួន ។

ក្រុមការងារ មានសិទ្ធិទទួលយកថវិកា និងការគាំទ្រពីដៃគូជាតិ និងអន្តរជាតិ ផ្នែកឯកជន និងពីប្រភពផ្សេងទៀត ដើម្បីបំរើឱ្យសកម្មភាពរួមរបស់ក្រុមការងារ ក្នុងគោលដៅប្រឆាំងអំពើជួញដូរមនុស្សទៅតាមមុខសញ្ញារៀងៗខ្លួន ដោយត្រូវរាយការណ៍ជូនគណៈកម្មាធិការជាតិ គ.ជ.ប.ជ ដើម្បីបូកសរុប ។

**ប្រការ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ១១.-**

សេចក្តីសំរេចនេះមានអនុភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០១៤

**ប្រធាន គ.ជ.ប.ជ**

**ស ខេង**

**កន្លែងទទួល៖**

- ខុទ្ទកាល័យទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យក្រសួងមហាផ្ទៃ
- សមាជិក គ.ជ.ប.ជ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

លេខ ៖ ០០១/១៤ គ.ជ.ប.ជ

# សេចក្តីសម្រេច
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល (នីតិកាលទី៥) នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការបង្កើត គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)
- បានឃើញអនុក្រឹត្យលេខ២៧៣អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## សម្រេច

**ប្រការ១.-**

សេចក្តីសម្រេចនេះ កំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ក្រោមជាតិ ដែលជាយន្តការអន្តរមន្ទីរ ស្ថាប័ន សម្រាប់សម្របសម្រួលដឹកនាំការអនុវត្តយុទ្ធសាស្ត្រប្រឆាំងអំពើជួញដូរមនុស្ស និងការពារជនរងគ្រោះនៅក្នុងដែនសមត្ថកិច្ចនៃរាជធានី ខេត្ត នីមួយៗ ។

**ប្រការ២.-**

ត្រូវបានបង្កើតគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្នុងដែនសមត្ថកិច្ចរាជធានី ហៅកាត់ថា គ.រ.ប.ជ និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅក្នុងដែនសមត្ថកិច្ចខេត្តនីមួយៗនៃព្រះរាជាណាចក្រកម្ពុជា ដែលហៅកាត់ថា គ.ខ.ប.ជ ។

គ.រ.ប.ជ ដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី និងគ.ខ.ប.ជ ដឹកនាំដោយអភិបាលនៃគណៈអភិបាលខេត្ត ដែលមានសមាជិកជាប្រធានមន្ទីរពាក់ព័ន្ធជុំវិញរាជធានី ខេត្ត ព្រះរាជអាជ្ញាអមសាលាដំបូង

រាជធានី ខេត្ត ស្នងការនគរបាលរាជធានី ខេត្ត មេបញ្ជាការកងរាជអាវុធហត្ថរាជធានី ខេត្ត មេបញ្ជាការកម្លាំងឈរជើងតាមព្រំដែន ច្រកអន្តរជាតិ ច្រកតំបន់ ច្រកទ្វេភាគី (បើមាន) អភិបាលខណ្ឌ ស្រុក ក្រុង និងប្រធានអង្គភាពពាក់ព័ន្ធសំខាន់ៗផ្សេងទៀតក្នុងរាជធានី ខេត្ត (បើមាន) ។

សមាសភាពនៃ គ.រ.ប.ជ ឬ គ.ខ.ប.ជ ត្រូវបានតែងតាំងដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស តាមការស្នើសុំរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ។

**ប្រការ៣.-**

គ.រ.ប.ជ ឬ គ.ខ.ប.ជ មានលេខាធិការដ្ឋានមួយជាអង្គភាពជំនួយដើម្បីដឹកនាំការងារប្រចាំថ្ងៃ ដែលមានការិយាល័យការងារអចិន្ត្រៃយ៍នៅក្នុងសាលារាជធានី ខេត្ត ។

លេខាធិការដ្ឋាន ដឹកនាំដោយអភិបាលរងរាជធានី ឬខេត្ត ០១រូប អមដោយអនុប្រធានលេខាធិការដ្ឋាន ០១រូប មានឋានៈជានាយករងរដ្ឋបាល រាជធានី ឬខេត្ត និងមានមន្ត្រីមួយចំនួនជាជំនួយតាមការចាំបាច់ មកពីក្របខណ្ឌសាលារាជធានី ខេត្ត ឬពីស្នងការដ្ឋាន នគរបាលរាជធានី ខេត្ត ឬពីមន្ទីរស្ថាប័ន ពាក់ព័ន្ធ ។

សមាសភាពនៃលេខាធិការដ្ឋាន ត្រូវបានតែងតាំងដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការរាជធានី (គ.រ.ប.ជ) ឬគណៈកម្មាធិការខេត្ត (គ.ខ.ប.ជ )។

**ប្រការ៤.-**

អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ត្រូវចាត់តាំងមន្ត្រីយ៉ាងតិច ០១រូប ឱ្យទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សសម្រាប់ ក្រុង ស្រុក ខណ្ឌ ដែលហៅកាត់ថា ម.ក្រ.ប.ជ (សម្រាប់ក្រុង) ម.ស្រ.ប.ជ (សម្រាប់ស្រុក) និង ម.ខ.ប.ជ (សម្រាប់ខណ្ឌ) ។

**ប្រការ៥.-**

មេឃុំ ចៅសង្កាត់ ត្រូវចាត់តាំងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់មួយរូបឱ្យទទួលបន្ទុកការងារប្រឆាំងការជួញដូរមនុស្ស ដែលហៅកាត់ថា ម.ស.ប.ជ (សម្រាប់សង្កាត់) និងម.ឃ.ប.ជ (សម្រាប់ឃុំ) និងមានមេភូមិជាជំនួយទៅតាមការងារជាក់ស្តែងរបស់ឃុំសង្កាត់ ។

**ប្រការ៦.-**

គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី (គ.រ.ប.ជ) ឬគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្ត (គ.ខ.ប.ជ) នីមួយៗ មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ក្រោមការដឹកនាំរបស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ ជំរុញអនុវត្តច្បាប់ គោលនយោបាយ ផែនការជាតិ ផែនការខេត្ត និងយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងដែនសមត្ថកិច្ចរបស់រាជធានី និងខេត្តនីមួយៗ ។
- ជាបញ្ជាការផ្ទាល់លើលេខាធិការដ្ឋាន គ.រ.ប.ជ ឬ គ.ខ.ប.ជ តាមដានត្រួតពិនិត្យ វាយតម្លៃបទល្មើស និងភាពរីកចម្រើននៃការអនុវត្តការងារ
- ពិនិត្យ និងសម្រេចលើផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំដែលស្នើឡើងដោយលេខាធិការដ្ឋានសម្រាប់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់រាជធានី ខេត្ត ដើម្បីដាក់បញ្ចូលក្នុងកញ្ចប់ថវិការាជធានី ខេត្ត
- បង្កើតក្រុមការងារអន្តរមន្ទីរ ស្ថាប័ន មួយចំនួនដើម្បីធ្វើជាយន្តការសម្រាប់ការអនុវត្តជំនាញ
- ដឹកនាំមន្ទីរ ស្ថាប័ន ក្រុង ស្រុក អង្គការដៃគូជាតិ អន្តរជាតិពាក់ព័ន្ធ និងទំនាក់ទំនងសហការជាមួយបណ្តាខេត្តនៃប្រទេសជាប់ព្រំដែន ដើម្បីបង្ការទប់ស្កាត់បទល្មើស និងជួយជនរងគ្រោះទាន់ពេលវេលា

តាមគោលការណ៍កំណត់របស់ថ្នាក់ជាតិ

- ដាក់ចេញវិធានការនានាតាមការចាំបាច់ ដើម្បីជំរុញ និងលើកកម្ពស់ការទទួលខុសត្រូវរបស់មន្ទីរ ស្ថាប័ន អង្គភាពពាក់ព័ន្ធក្រោមឱវាទ ដើម្បីអនុវត្តសកម្មភាព ផែនការ គោលនយោបាយ និងគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល
- សម្របសម្រួល និងជំរុញកម្លាំងសមត្ថកិច្ចឱ្យបង្កើនការស៊ើបអង្កេតបទល្មើស និងស្វែងចាប់ជនល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សដើម្បីផ្តន្ទាទោស
- ប្រជុំសមាជិកទៀងទាត់ប្រចាំត្រីមាស ឆមាស ឆ្នាំ របស់គណៈកម្មាធិការរាជធានី ខេត្ត ។ ក្នុងករណីចាំបាច់ ប្រធានអាចកោះអញ្ជើញសមាជិកជួបប្រជុំវិសាមញ្ញបាន ។
- ពិនិត្យសម្រេចលើរបាយការណ៍ មុននឹងបញ្ជូនទៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ តាមកាលកំណត់
- អនុវត្តភារកិច្ចផ្សេងទៀត តាមការណែនាំចង្អុលទិសពីគណៈកម្មាធិការជាតិ ។

**ប្រការ៧**.-

លេខាធិការដ្ឋាន គ.រ.ប.ជ ឬ គ.ខ.ប.ជ មានភារកិច្ច ៖

- ជាជំនួយការប្រតិបត្តិ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី ខេត្ត ក្នុងការអនុវត្តភារកិច្ចដែលដាក់ចុះដោយគណៈកម្មាធិការជាតិ រាជធានី ខេត្ត លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- រៀបចំកិច្ចប្រជុំរបស់ គ.រ.ប.ជ ឬ គ.ខ.ប.ជ ប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ និងកិច្ចប្រជុំវិសាមញ្ញផ្សេងទៀត តាមការចាំបាច់
- ផ្សព្វផ្សាយទូលំទូលាយអំពីច្បាប់ គោលនយោបាយ បទដ្ឋានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស
- ដឹកនាំ សម្របសម្រួល រៀបចំ ឬចូលរួមកិច្ចប្រជុំ សិក្ខាសាលា ទស្សនកិច្ចសិក្សា និងសន្និសីទពាក់ព័ន្ធផ្សេងៗ
- ពង្រឹង និងពង្រីកទំនាក់ទំនងសហការក្នុងក្រុមការងារជំនាញអន្តរមន្ទីរ ស្ថាប័ន និងអង្គការដៃគូ
- លើកផែនការពង្រឹងសមត្ថភាពមន្ត្រីលេខាធិការដ្ឋាន គ.រ.ប.ជ ឬ គ.ខ.ប.ជ និងមន្ត្រីពាក់ព័ន្ធតាមមន្ទីរ ស្ថាប័នក្រោមឱវាទ និងមន្ត្រីទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្រុង ស្រុក ខណ្ឌ ទៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាល
- គ្រប់គ្រង និងតាមដានលំហូរពលករទេសន្តរប្រវេសន៍ ទប់ស្កាត់ភាពមិនប្រក្រតីនៃចំណាកស្រុក តាមដានកលល្បិចជនខិលខូចទាំងក្នុងប្រព័ន្ធស្របច្បាប់ និងមិនស្របច្បាប់
- តាមដាន និងអប់រំផ្សព្វផ្សាយទូលំទូលាយតាមគ្រប់រូបភាព អំពីល្បិចកលជនល្មើស ដើម្បីបង្ការ ទប់ស្កាត់បទល្មើស
- ជំរុញការស៊ើបអង្កេតតាមដានជនសង្ស័យ ឈានទៅការចាប់ខ្លួនដើម្បីផ្តន្ទាទោស
- គាំទ្រការផ្តល់សេវាជួយជនរងគ្រោះ និងជំរុញការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងភាពរងគ្រោះរបស់ប្រជាពលរដ្ឋដោយអំពើជួញដូរមនុស្ស
- បូកសរុបរបាយការណ៍ដែលប្រមូលបានពីក្រុង ស្រុក ខណ្ឌ មន្ទីរ អង្គភាពពាក់ព័ន្ធ ប្រចាំខែ ត្រីមាស និងឆ្នាំ ស្តីពីសកម្មភាព លទ្ធផល ភាពប្រឈម ជុំវិញការប្រឆាំងអំពើជួញដូរមនុស្ស និងទិសដៅ ដាក់ជូនអភិបាល រាជធានី-ខេត្ត ដែលជាប្រធាន គ.រ.ប.ជ ឬ គ.ខ.ប.ជ ដើម្បីពិនិត្យ និងចុះហត្ថលេខា រួចបញ្ជូនទៅអគ្គលេខា ធិការដ្ឋានថ្នាក់ជាតិ មិនហួសពីថ្ងៃចុងក្រោយ នៃខែនីមួយៗ ។

- បំពេញការងារផ្សេងទៀត តាមការប្រគល់ជូនពី គ.ជ.ប.ជ និង គ.រ.ប.ជ ឬ គ.ខ.ប.ជ ។

**ប្រការ៨**.-

ម.ក្រ.ប.ជ ឬម.ស.ប.ជ ឬម.ខ.ប.ជ របស់ក្រុង ស្រុក ខណ្ឌ មានភារកិច្ច ៖

- ទទួល និងបញ្ជូនលិខិត បទដ្ឋានគតិយុត្តិ ឬគោលការណ៍ណែនាំផ្សេងៗពី គ.រ.ប.ជ ឬ គ.ខ.ប.ជ ទៅឃុំ សង្កាត់ និងទទួលរបាយការណ៍ឬព័ត៌មានផ្សេងៗពីឃុំ សង្កាត់ ដើម្បីបញ្ជូនទៅគ.រ.ប.ជ ឬគ.ខ.ប.ជ វិញ
- ទំនាក់ទំនង សម្របសម្រួលកិច្ចសហការរវាងក្រសួង មន្ទីរ ស្ថាប័ន អង្គការ ដែលធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធ្វើរបាយការណ៍បូកសរុបការងារ និងលទ្ធផលប្រចាំខែ អំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងដែនសមត្ថកិច្ច ក្រុងស្រុក ខណ្ឌ និងដាក់ជូនអភិបាលក្រុង ស្រុក ខណ្ឌ ឬអភិបាលរងទទួលបន្ទុក ពិនិត្យ និងចុះហត្ថលេខាដើម្បីបញ្ជូនទៅលេខាធិការដ្ឋានរាជធានី ខេត្ត មិនហួសពីថ្ងៃទី២៧នៃខែនីមួយៗ ។

**ប្រការ៩**.-

ម.ឃ.ប.ជ របស់ឃុំ ឬម.ស.ប.ជ របស់សង្កាត់ មានភារកិច្ច ៖

- ទទួលភារកិច្ច និងគោលការណ៍ណែនាំពីគណៈកម្មាធិការ ឬលេខាធិការដ្ឋានរាជធានី ខេត្ត តាមរយៈ ម.ក្រ.ប.ជ.ឬ ម.ស.ប.ជ ឬ ម.ខ.ប.ជ
- សម្របសម្រួលសហការ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងសកម្មភាពប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស របស់មន្ត្រីក្រសួង ស្ថាប័ន អាជ្ញាធរ សមត្ថកិច្ច សាលារៀន អង្គការ និងភ្នាក់ងារឯកជននានា ក្នុងឃុំ សង្កាត់របស់ខ្លួន
- ធ្វើបញ្ជីអង្គការសង្គមស៊ីវិលដែលធ្វើសកម្មភាពពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សក្នុងឃុំ សង្កាត់របស់ខ្លួន ដោយផ្តល់កិច្ចសហការល្អ និងជំរុញឲ្យធ្វើរបាយការណ៍សកម្មភាពមក ម.ឃ.ប.ជ ឬម.ស.ប.ជ ជាប្រចាំ
- ជំរុញសមត្ថកិច្ចនគរបាលតាមបណ្តាប៉ុស្តិ៍ និងប្រជាពលរដ្ឋតាមដានករណីសង្ស័យ និងរាយការណ៍ ។
- ធ្វើរបាយការណ៍សកម្មភាព និងលទ្ធផលសរុបប្រចាំខែ ដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ ចុះហត្ថលេខា រួចបញ្ជូនទៅម.ស.ប.ជ ឬម.ស.ប.ជ ដើម្បីបូកសរុបប្រចាំខែ រៀងរាល់ថ្ងៃទី២៥នៃខែនីមួយៗ ។

**ប្រការ១០**.-

គ.រ.ប.ជ ឬ គ.ខ.ប.ជ អាចអនុញ្ញាតឱ្យអង្គការ ស្ថាប័ន ក្នុងស្រុក និងអន្តរជាតិដែលបានចុះបញ្ជីជាផ្លូវការជាមួយរាជរដ្ឋាភិបាល សាកលវិទ្យាល័យ ឬផ្នែកឯកជន ដែលកំពុងធ្វើសកម្មភាពក្នុងទិសដៅរួមចំណែកបង្ការ ទប់ស្កាត់ ឬលុបបំបាត់ការជួញដូរមនុស្ស និងជួយជនរងគ្រោះនៅក្នុងដែនសមត្ថកិច្ចរបស់ រាជធានី ខេត្ត ធ្វើជាដៃគូ ដើម្បីពង្រឹង និងពង្រីកកិច្ចសហការ ឬការគាំទ្រដល់ការអនុវត្តច្បាប់ គោលនយោបាយជាតិ យុទ្ធសាស្ត្រ ផែនការជាតិរបស់ គ.ជ.ប.ជ ព្រមទាំងផែនការរបស់ គ.រ.ប.ជ ឬ គ.ខ.ប.ជ ។

**ប្រការ១១**.-

អង្គការ ឬស្ថាប័នដៃគូជាតិ និងអន្តរជាតិ អាចចូលរួមប្រជុំពិគ្រោះពិភាក្សា ផ្លាស់ប្តូរយោបល់ ផ្តល់ប្រឹក្សា ពង្រឹងកិច្ចសហការជាមួយ គ.រ.ប.ជ និង គ.ខ.ប.ជ ដើម្បីគាំទ្របច្ចេកទេស ធនធាន ថវិកា សម្ភារមធ្យោបាយ សំដៅធ្វើឱ្យសម្រេចគោលដៅតាមការអញ្ជើញរបស់ គ.ខ.ប.ជ ជាទៀងទាត់ប្រចាំត្រីមាស ។ រាល់កិច្ចប្រជុំត្រូវមានរបាយការណ៍សកម្មភាព និងលទ្ធផលរបស់អង្គការនីមួយៗ ។

**ប្រការ១២**.-

គ.រ.ប.ជ ឬ គ.ខ.ប.ជ ត្រូវរៀបចំក្រុមការងារជំនាញអន្តរមន្ទីរ ស្ថាប័ន ដែលបើកទូលាយឲ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ទាំងក្នុងរដ្ឋាភិបាល ទាំងអង្គការមិនមែនរដ្ឋាភិបាល ជាតិ និងអន្តរជាតិ ផ្នែកឯកជន ។ល។ ដែលមានក្រុមមួយចំនួន ដូចខាងក្រោម ៖

១. ក្រុមការងារបង្ការ ទប់ស្កាត់ ដឹកនាំដោយមន្ទីរអប់រំ យុវជន និងកីឡា

២. ក្រុមការងារការពារជនរងគ្រោះ ដឹកនាំដោយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

៣. ក្រុមការងារអនុវត្តន៍ច្បាប់ ដឹកនាំដោយស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត

៤. ក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយអយ្យការអមសាលាដំបូងរាជធានី-ខេត្ត

៥. ក្រុមការងារពង្រឹងកិច្ចសហប្រតិបត្តិការ ដឹកនាំដោយមន្ទីរកិច្ចការនារី (ចំពោះខេត្តជាប់ព្រំដែន)

៦. ក្រុមការងារកិច្ចការទេសន្តរប្រវេសន៍ ដឹកនាំដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

សមាសភាព និងតួនាទីភារកិច្ចរបស់ក្រុមការងារនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរាជធានី ខេត្ត ។

សមាជិកទទួលបន្ទុកការងារបច្ចេកទេសនីមួយៗ ត្រូវសហការអនុវត្តការងាររួមគ្នាតាមជំនាញ សំដៅលើកកម្ពស់ប្រសិទ្ធភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ សកម្មភាពរួមសំខាន់ៗរបស់ក្រុមការងារ ត្រូវបានលើកគម្រោងចំណាយរួម និងស្នើសុំការសម្រេចពីប្រធានគណៈកម្មាធិការរាជធានីដែលជាអភិបាលរាជធានី (សម្រាប់រាជធានី) និងប្រធានគណៈកម្មាធិការខេត្ត ដែលជាអភិបាលខេត្ត (សម្រាប់ខេត្តនីមួយៗ) ដើម្បីដាក់បញ្ចូលក្នុងកញ្ចប់ថវិការាជធានី ខេត្ត ប្រើប្រាស់ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ ក្រុមការងារ ត្រូវជួបប្រជុំទៀងទាត់ប្រចាំខែ ដើម្បីផ្លាស់ប្តូរព័ត៌មាន និងបទពិសោធន៍ ធ្វើរបាយការណ៍ និងលើកទិសដៅបន្ត និងចូលរួមកិច្ចប្រជុំនានាដែលរៀបចំដោយ គ.រ.ប.ជ ឬ គ.ខ.ប.ជ ។

**ប្រការ១៣**.-

គម្រោងថវិការួមប្រចាំឆ្នាំរបស់ គ.រ.ប.ជ ឬ គ.ខ.ប.ជ គឺជាឧបសម្ព័ន្ធនៃថវិកាប្រចាំឆ្នាំរបស់រាជធានី ខេត្ត ដោយដាក់បញ្ចូលថវិកាដែលត្រូវអនុវត្តភារកិច្ចប្រចាំខែរបស់មន្ត្រីទទួលបន្ទុកការងារនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ និង ក្រុមការងារជំនាញអន្តរមន្ទីរ ស្ថាប័ន ដើម្បីធានាថាគ្រប់ផ្នែក មានថវិកាអនុវត្តសកម្មភាពជាប្រចាំ ដើម្បីធ្វើឱ្យសម្រេចទិសដៅក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

គណៈកម្មាធិការ និងលេខាធិការដ្ឋាន គ.ខ.ប.ជ ឬ គ.រ.ប.ជ អាចកៀរគរការចូលរួម ការគាំទ្រធនធាន ថវិកា និងកិច្ចសហការបន្ថែមទៀតពីបណ្តាអង្គការ ស្ថាប័ន និងសប្បុរសជននានាដើម្បីជាកម្លាំងសរុប និងធនធានសរុបក្នុងការអនុវត្ត និងធ្វើរបាយការណ៍ជូនអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ ដើម្បីបានជ្រាប និងសរុបរាយការណ៍ជូនគណៈកម្មាធិការជាតិ គ.ជ.ប.ជ ។

**ប្រការ១៤**.-

គ.ខ.ប.ជ ឬ គ.រ.ប.ជ មានសិទ្ធិប្រើត្រា និងរូបសញ្ញាគណៈកម្មាធិការរាជធានី (សម្រាប់រាជធានី) ឬត្រា និងរូបសញ្ញាគណៈកម្មាធិការខេត្ត (សម្រាប់ខេត្តនីមួយៗ) តាមការកំណត់របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ( គ.ជ.ប.ជ) ។

**ប្រការ១៥**.-

លិខិតបទដ្ឋានទាំងឡាយណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១៦**.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទទួលបន្ទុកជាប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់អង្គភាព ស្ថាប័នដែលពាក់ព័ន្ធ គណៈអភិបាលរាជធានី ខេត្តត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេច តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០១៤

**ឧបនាយករដ្ឋមន្ត្រី**

**ប្រធាន គ.ជ.ប.ជ**

ស ខេង

**ចម្លងជូន**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិគ.ជ.ប.ជ
- ក្រសួងមហាផ្ទៃ
- សាលារាជធានី-ខេត្ត
- ដូចប្រការ ១៦
- ឯកសារ កាលប្បវត្តិ

# កម្រងរូបភាពនៃសកម្មភាពរបស់
# គណៈកម្មាធិការជាតិ

# សកម្មភាពគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស








# ពិធីប្រកាស គណៈកម្មាធិការជាតិ គ.ជ.ប.ជ



















ពិធីប្រគល់ត្រា













# កិច្ចសហប្រតិបត្តិការ របស់អគ្គលេខាធិការដ្ឋាន ជាមួយអ្នកពាក់ព័ន្ធ






















# សកម្មភាព ប្រារព្ធទិវាជាតិ ១២ធ្នូ និងកិច្ចប្រជុំផ្សេងៗ
# ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស




















# ការទទួលជួយដល់ពលករទេសន្តរប្រវេសន៍
# ដែលអាជ្ញាធរថៃ បញ្ជូនមកវិញ ក្នុងខែមិថុនា ឆ្នាំ ២០១៤






















ពិធីប្រកាសគណៈកម្មាធិការជាតិ គ.ជ.ប.ជ រចនាសម្ព័ន្ធ
និងផែនការសកម្មភាពជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (២០១៤-២០១៨)
ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០១៥





ឧបត្ថម្ភដោយ:

USAID FROM THE AMERICAN PEOPLE | WINROCK INTERNATIONAL Putting Ideas to Work | UN-ACT United Nations Action for Cooperation against Trafficking in Persons | Cambodia ACTs | IOM OIM | AAPTIP AUSTRALIA - ASIA PROGRAM TO COMBAT TRAFFICKING IN PERSONS